# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣១ លេខ ៥ ខែឧសភា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

- វេរុបសមកថា របស់ព្រះគ្រូញាណមុនី ឡេង-ភម . . . . . . . ៤៨១
- លោកបាលធម៌ របស់ព្រះមហា មាស-ស៊ុមន៍ . . . . . . . ៤៩៤
- សុរពជាតក ( តមក ) លោក ជង-វង ចម្លងពីសាស្ត្រាស្លឹករឹត . . . ៥០៩

*ផ្នែកអក្សរសាស្ត្រ*

- រឿងសព្វសិទ្ធិ (តមក) របស់ហ្លួនភក្ដីអក្សរ គង់ លោក ប៊ូ-ញ៉ូ ចំឡងពីសាស្ត្រាស្លឹករឹត ៥២១
- រឿងហង្សយន្ត (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត . . . . ៥៤៧
- អំពីល្ខោនស្បែក អ្នកស្រី ពេជ្រ-សល់ រៀបរៀង . . . . . . ៥៥៧
- ការវាងវៃនៃបចក ភិក្ខុ ម៉ែន-រៀម រៀបរៀង . . . . . . . . ៥៦៣
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ៥៦៩

*ផ្នែកកំណត់ទីងប្រវត្តិការណ៍*

- ពិធីប្រគេនព្រហ្មទានចំពោះសមណនិស្សិត លោក ភ័យ-ប៊ុក រៀបរៀង . . ៥៧៤
- បុណ្យនមស្ក ព្រះសក្យមុនីចេតិយ លោក ចាប-ពិន រៀបរៀង . . . . ៥៨៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ ( តមក ) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៦០០



មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០:០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


-Verupasamakatha par Preah kru Nhean Muni LENG-REAM. . 481

-Lokapaladhamma par Preah Moha MEAS-SUM . . . . . 494

-Surabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG . . . . . . . 509


### Partie littéraire :


-Histoire de Sabbasiddhi (suite) par Phakdei Aksar TAN revue et corrigée par M. BOU-PO . . . . . . . . . . . 521

-Histoire de Hang-Yon recueillie du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . . . 547

-Le Théâtre d'Ombre par Mme PICH-SAL . . . . . 557

-La Ruse du Loup par le bonze MEN-REAM . . . . . 563

-Histoire de Sam Kok (suite) par l'Oknha NOU-KAN . . . 569


### Notes et Chroniques :


-Distribution des Prix aux lauréats religieux par M. RAY-BUC. 574

-Cérémonie «Namaskar Preah Sakyamunichedey célébrée à Phnom-Penh» par M. CHAP-PIN. . . . . . 587

-Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . . 600


---


Prix d'abonnement annuel (comprenant 12 numéros): 230$00.

**ផ្នែកសាសនា**

# អៀរុបសមកថា

( ពោលអំពីការរម្ងាប់ពៀរ )

របស់ព្រះគ្រូញាណមុនី ឡៀង-ភម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

លោកនេះ អាត្មាភាពនឹងសម្តែងធម្មកថា ដែលមានក្នុងគម្ពីរធម្មបទខុទ្ទកនិកាយត្រង់យមកវគ្គនៃបុព្វភាគ ពណ៌នាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាដើម្បីជាគ្រឿងប្រតិបត្តិអប់រំនិស្ស័យសន្តាន បណ្តុះសទ្ធាឲ្យកើតសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ដាស់តឿនចិត្តឲ្យលះបង់អកុសលធម៌ គឺសេចក្តីលោភ ក្រោធ វង្វេង រកគួនបៀតបៀន ឲ្យបំពេញកុសលធម៌ គឺសេចក្តីមិនលោភ-ក្រោធ-វង្វេង មិនគិតគុំគួនបៀតបៀនជាដើម តាំងចិត្តប្រតិបត្តិល្អតាមពាក្យប្រដៅរបស់ព្រះសាស្តា ដើម្បីសម្រេចគុណប្រយោជន៍ ទីនឹងសេចក្តីសុខចំរើន ដល់អ្នកគោរពពាប់អានព្រះពុទ្ធសាសនាឲ្យល្អមសមគួរដល់កិត្តិយសជាកុលបុត្រ កុលធីតាក្នុងវង្សព្រះពុទ្ធសាសនា ។

ក្នុងលោកនេះ មានតែដែលជាបដិបក្ខនឹងគ្នាពីរយ៉ាងគឺៈ មិត្រនឹងសត្រូវ, មិត្រជាចំណែកមួយ ជួយទំនុកបម្រុងផ្ដើម ឲ្យកើតសេចក្ដីសុខ សត្រូវជាចំណែកមួយខាងការបំផ្លិចបំផ្លាញ ធ្វើសេចក្ដីវិនាសឲ្យកើតទុក្ខទោសក្ដៅក្រហាយលំបាកចិត្តឈឺផ្សា ។ មិត្រប្រែថា អ្នកប្រាថ្នាល្អ គឺអ្នកដែលមានមេត្រីចិត្តប្រាថ្នាសេចក្ដីសុខចំពោះឲ្យមនុស្សជាមិត្រ, សត្រូវប្រែថា អ្នកប្រាថ្នាសេចក្ដីវិនាស គឺសឹកសត្រូវគិតបំផ្លិចបំផ្លាញធ្វើឲ្យមនុស្សជាមិត្រហិនហោចឲ្យអន្តរាយ ។ មនុស្សយើងគ្រប់គ្នាត្រូវការមិត្រ មិនត្រូវការសត្រូវ តែមិត្រឬសត្រូវ មិនមែនមានមកឯង ១ រមែងកើតមានព្រោះយើងធ្វើឲ្យកើតឡើង ។ មេត្តាចិត្តជាហេតុឲ្យកើតមិត្រ ទោសចិត្ត ជាហេតុឲ្យមានសត្រូវ បុគ្គលអ្នកមានមេត្តានៅក្នុងចិត្តគិតប្រាថ្នាល្អដល់អ្នកដទៃ ដោយផ្សាយមេត្រីចិត្តទៅថា សព្វេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សត្វទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ មិនបៀតបៀនគ្នា មិនមានសេចក្ដីទុក្ខ ចូរជាអ្នកមានសេចក្ដីសុខរក្សាខ្លួនចុះ ។

អ្នកមានមេត្តាចិត្តដូច្នេះ រមែងមិនឃើញមនុស្សដទៃ ដែលជាសត្រូវដល់ខ្លួន រមែងឃើញមនុស្សឬសត្វដទៃសុទ្ធតែជាមិត្រ គឺសម្លាញ់កើតចាស់ឈឺស្លាប់ជាមួយនឹងខ្លួនទាំងអស់ ។ ការធ្វើនិយាយគិត របស់បុគ្គលអ្នកមានមេត្តាចិត្តនោះ រមែងប្រាសចាកទោស ប្រព្រឹត្តទៅដើម្បី

មិនបៀតបៀនប្រទូសរ៉ាយអ្នកដទៃ  រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ទាំង សេចក្តីសុខដោយចំណែកមួយ  ព្រោះអ្នកធ្វើមានចិត្តប្រាសចាកអឃាត ព្យាបាទវិហិង្សា  កាលមានចិត្តមេត្តាប្រាថ្នាល្អ និយាយទាំងធ្វើតែការណា ដែលជាប្រយោជន៍ដល់អ្នកដទៃ  អ្នកណាទាំងក្រោធស្អប់ហ៊ានតាំងខ្លួនជា សត្រូវចាំប្រទូសរ៉ាយ មានតែមនុស្សស្រឡាញ់ប្រាថ្នាល្អជំនួសវិញ ព្រោះ មនុស្សយើងមានចិត្តប្រាថ្នាល្អ ធ្វើល្អច្រើនជាងនឹងគិតធ្វើប្រទូសរ៉ាយ កាល ម្នាក់ធ្វើល្អ ម្នាក់ទៀតក៏កើតសេចក្តីស្រឡាញ់ធ្វើតបខ្លះ មេត្តាជាគុណធម៌ ប្រសើរ ជាអាវុធពិសេសសម្រាប់ការពារសត្រូវ មិនឲ្យធ្វើអន្តរាយដល់អ្នក ដែលមានមេត្តាបាន ទាំងជាហេតុឲ្យកើតមិត្តភក្តិទាំងពួង ។ សម្តេច ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សរសើរមេត្តាថា  មានគុណានិសង្ស ច្រើនដល់ទៅ ១១ ប្រការ មានបទថា សុខំ សុបតិ ជាដើម ប្រែថា "អ្នកចំរើនមេត្តានេះ ដេកក៏ស្រួល ភ្ញាក់ឡើងក៏ស្រួល មិនឃើញសុបិន អាក្រក់  ជាទីស្រឡាញ់របស់មនុស្សនិងអមនុស្សទាំងឡាយ  ពួក ទេវតារមែងរក្សា ភ្លើងឬថ្នាំពិសឬគ្រឿងសស្ត្រាមិនញាំញីធ្វើអន្តរាយបាន ចិត្ត របស់អ្នកចំរើនមេត្តារមែងតាំងទៅស៊ប់ជាសមាធិយ៉ាងឆាប់រហ័ស  មាន ពណ៌សម្បុរនៃមុខមាត់ដ៏ផូរផង់  មិនវង្វេងស្មារតីក្នុងវេលាធ្វើមរណកាល កាលបើមិនទាន់បានសម្រេចព្រះអរហត្ត  ដែលជាធម៌ខ្ពង់ខ្ពស់  រមែង ជាអ្នកចូលដល់ព្រហ្មលោកដូច្នេះ" ។ ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នា

ដើម្បីឲ្យផុតពីសត្រូវ ទាំងប្រាថ្នាជាអ្នកមានមិត្តជុំវិញហែហម ទាំងដោយមនុស្សស្រឡាញ់ប្រាថ្នាល្អហើយ គប្បីចំរើនមេត្តាឲ្យជាគុណធម៌ប្រចាំចិត្តរបស់ខ្លួននៅជានិច្ចកាល, ចំរើនមេត្តានោះ បានដល់ការនឹកដល់ខ្លួនធៀបនឹងមនុស្សសត្វដទៃថា "យើងស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងណា មនុស្សសត្វដទៃ ក៏ស្រឡាញ់សុខ ស្អប់ទុក្ខដូច្នោះដែរ" ។

ដូច្នេះ យើងមិនបៀតបៀនប្រទូស្តរ៉ាយមនុស្សសត្វដទៃ ឲ្យបានសេចក្ដីក្ដៅក្រហាយលំបាកព្រោះយើងជាហេតុ ទាំងគប្បីផ្សាយតែសេចក្ដីល្អទៅដល់មនុស្សទាំងសត្វទាំងអស់នោះថា "មនុស្សទាំងសត្វទាំងពួងសុទ្ធតែប្រាថ្នាសុខដូចគ្នា ចូរជាអ្នកបានសេចក្ដីសុខសមតាមសេចក្ដីប្រាថ្នារបស់ខ្លួនចុះ កុំមានពៀរនឹងគ្នា កុំបៀតបៀនគ្នា កុំមានសេចក្ដីទុក្ខកាយលំបាកចិត្តឡើយ ចូរជាអ្នកមានសុខគ្រប់គ្រងរក្សាខ្លួនដូច្នេះ" ។ ការផ្សាយមេត្តាតាមន័យដូចពោលមកនេះ ជាត់ថាមិនមានពៀរ មិនមានភ័យដល់មនុស្សទាំងសត្វទាំងឡាយ ដោយចិត្តមេត្តារបស់ខ្លួន ឈ្មោះថាធ្វើសមភាពគឺភាពជាអ្នកស្មើមុខគ្នាដល់មនុស្សទាំងសត្វទាំងឡាយ ចំណែកការគិតបៀតបៀនប៉ុនប៉ងឲ្យគេបានទទួលសេចក្ដីទុក្ខលំបាក ឈ្មោះថាធ្វើភាពមិនឲ្យស្មើមុខគ្នា ព្រោះហេតុនោះ ការផ្សាយមេត្តាចិត្តគិតប្រាថ្នាល្អដល់គ្នានឹងគ្នាទើបឈ្មោះថា ឲ្យសមភាពដល់គ្នានឹងគ្នា ដោយទឹកចិត្ត ព្រោះមនុស្សយើងត្រូវកើតចាស់ឈឺស្លាប់ដូចគ្នា ចង់បានសេចក្ដីសុខ

មិនចង់បានទុក្ខ កាលៈយើងបង្អោនចិត្តគិតឲ្យគេបានផុតពីទុក្ខហើយ ឈ្មោះថា យើងឲ្យអភ័យ ឲ្យសមភាពដល់គេ ឲ្យសេរីភាព សូមសុខដូច ៗ គ្នា ៗ

ម្យ៉ាងទៀត ការផ្សាយមេត្តានេះ លោកប្រដៅឲ្យផ្សាយទៅក្នុងមនុស្សដែលខ្លួនស្រឡាញ់រាប់អានជាមុន តាំងពីមាតាបិតា ស្វាមី ភរិយា បុត្រធីតា នឹងលោកដែលជាទីគោរព ដូចឧបជ្ឈាយ៍អាចារ្យជាដើម រួចសឹមផ្សាយដល់មនុស្សដែលខ្លួនតាំងជាកណ្តាល ៗ ទីបំផុតទើបផ្សាយដល់មនុស្សដែលយើងស្អប់ ដើម្បីឲ្យចិត្តស្ទាត់ជំនាញក្នុងការចំរើនមេត្តា ការផ្សាយមេត្តាដល់មនុស្សដែលខ្លួនស្រឡាញ់នោះ មិនជាការអស្ចារ្យទេ អ្នកណា ក៏អាចធ្វើបាន ប្រៀបដូចអុំទូកបណ្តោយទឹក ៗ ចំណែកការផ្សាយមេត្តាដល់មនុស្សដែលខ្លួនស្អប់ លោកប្រៀបដូចអុំទូកច្រាសទឹក កម្រនឹងសម្រេចបានតាមប្រាថ្នា ត្រូវប្រើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ទើបចំរើនមេត្តានេះបានផលល្អ ៗ

សេចក្តីពិត ការផ្សាយមេត្តាក្នុងមនុស្សដែលខ្លួនស្អប់នោះ មនុស្សសាមញ្ញធ្វើបានដោយក្រ តែលោកអ្នកប្រាជ្ញធ្វើបានដោយងាយ ព្រោះមានឧបាយប្រសើរដែលធ្វើឲ្យបាត់សេចក្តីស្អប់ គឺធ្វើចិត្តឲ្យត្រូវផ្លូវ បានដល់លើកសេចក្តីល្អរបស់គេឡើង នឹកពិចារណាតាមដែលយើងលើកមកបាន ការប្រព្រឹត្តផ្លូវកាយក៏ដោយ វាចាក៏ដោយ ចិត្តក៏ដោយ ដូចមនុស្សច្រើននិយាយជំពាស់គេបៀតអ្នកដទៃ តែមិនមែនមនុស្សអាចដល់

ទៅធ្វើអន្តរាយ មនុស្សច្រើនជាយសេចក្តីក្រោធតែមិនធ្វើពិត ៗ មនុស្ស ភាព តែមានចិត្តអើពើជួយអនុគ្រោះដល់អ្នកដទៃ ទាំងនេះ ជា គួយ៉ាង គប្បីនឹកសេចក្តីល្អដែលមាននៅក្នុងខ្លួនរបស់គេ ដូចកាលពី រម្ងាប់សេចក្តីស្អប់ឲ្យស្រាលបានខ្លះ ឬយូរ ៗ ទៅអាចដាច់តែម្តងក៏មាន ។ បើនឹកសេចក្តីល្អរបស់គេមិនឃើញ គប្បីញ៉ាំងករុណាចិត្ត គឺសេចក្តី អាណិតអាសូរឲ្យកើត មនុស្សគោកយ៉ាកខ្វត់ទ្រព្យ មិនមានកម្លាំងជា គ្រឿងទំនុកបម្រុងជីវិត ទីពឹងកាយឲ្យសុខ មិនមានឱកាសអនុគ្រោះ មនុស្សដទៃដោយកម្លាំងទ្រព្យ ជាអ្នកគួរបានទទួលសេចក្តីករុណារបស់ មនុស្សដែលមានទ្រព្យយ៉ាងណា មនុស្សមិនមានគុណធម៌សេចក្តីល្អជា គ្រឿងបម្រុងចិត្តឲ្យជាសុខ មិនមានឱកាសនឹងដឹកនាំខ្លួនអ្នកដទៃក្នុង សេចក្តីល្អ មិនតែប៉ុណ្ណោះត្រឡប់បៀតបៀនមនុស្សឲ្យបានទទួលសេចក្តី ក្តៅក្រហាយទៀត ។ រមែងជាអ្នកសមគួរបានទទួលសេចក្តីករុណារបស់ មនុស្សអ្នកប្រព្រឹត្តធម៌ មានសតិសម្បជញ្ញៈក៏ដូច្នោះ ការដែលស្អប់ មនុស្សដូច្នេះក៏គេប្រយោជន៍ដល់ខ្លួនមិនមាន ការដែលនឹកយ៉ាងនេះអាច ញ៉ាំងករុណាឲ្យកើតឡើងបាន បើបង្អោនចិត្តនឹកទៅដោយមិនចុះសម្រុង ដោយឧបាយយ៉ាងនេះ គប្បីនឹកដល់ភាពនៃសត្វមានកម្មជារបស់ខ្លួន អ្នក ណាធ្វើល្អ ឬធ្វើអាក្រក់ អ្នកនោះនឹងប្រាកដដោយកម្មរបស់ខ្លួនឯង គប្បីតាំងចិត្តជាឧបេក្ខា សូម្បីយ៉ាងនេះ ក៏ទៅមិនសម្រេច កុំប្រារព្ធ

ដល់អ្នកនោះឲ្យសោះ បើគេស្អប់ខ្លួន ក៏គប្បីកេនកាសសម្តែងសេចក្តីពិតសេចក្តីល្អដោយកាយវាចាចិត្ត ឬក៏ជួយអនុគ្រោះដើម្បីចងមេត្រីភាព កាលប្រព្រឹត្តប្រតិបត្តិដោយមេត្តាចិត្តដូច្នេះ ក៏នឹងនៅជាសុខស្រួល មិនខ្លាចដល់ពៀរនឹងភ័យដែលនឹងមានមកអំពីទីណា ៗ ឈ្មោះថានៅដោយមិនមានភ័យ មិនមានពៀរនឹងអ្នកដទៃ មានសេចក្តីស្ងប់ស្ងាប់ មិនឈ្មោះប្រកែកវិវាទនឹងអ្នកណា នៅទីណាក៏នៅបាន មិនក្តៅក្រហាយចិត្ត គិតតក់ស្លុតដល់សត្រូវដែលនឹងមកបៀតបៀន ព្រោះជាអ្នកមានមិត្រជាទីស្រឡាញ់នៅជុំវិញ មានតែសេចក្តីកក់ក្តៅចិត្ត លែងរន្ធត់ស្ញើបពីទីជុំវិញ មានតែគេជួយការពារសុខ ទុក្ខឲ្យទៀតផង ។

ចំណែកទោសចិត្ត ដែលជាហេតុឲ្យកើតសត្រូវនោះ អធិប្បាយថា ទោសចិត្តបានដល់ចិត្តប្រទូសរ៉ាយ មនុស្សអ្នកមានចិត្តប្រទូសរ៉ាយរមែងដឹងខ្លួនថា មានសត្រូវជុំវិញ ព្រោះខ្លួនប្រទូសរ៉ាយអ្នកណា គិតបំផ្លិចបំផ្លាញបៀតបៀនធ្វើសេចក្តីអន្តរាយដល់អ្នកណា ក៏រមែងឃើញអ្នកនោះ ៗ ជាសត្រូវធំរបស់ខ្លួន, នេះបញ្ជាក់ឲ្យឃើញថា សត្រូវកើតឡើង ព្រោះការគិតរបស់ខ្លួន កាលបើលុះក្នុងអំណាចនៃសេចក្តីក្រោធដកបហ៊ានធ្វើប្រទូសរ៉ាយគេ ឬនិយាយរកអាក្រក់ពីគេ ឲ្យបានទទួលសេចក្តីលំបាកឈឺចាប់ក្តៅក្រហល់ក្រហាយ ក៏ជាហេតុឲ្យគេក្រោធធ្វើអន្តរាយតបដល់ខ្លួនវិញខ្លះ, ត្រង់នេះ សត្រូវកើតឡើងព្រោះការធ្វើរបស់

ខ្លួន បុគ្គលអ្នកមានសត្រូវជុំវិញ រមែងតក់ស្លុតព្រឺស្បើរន្ធត់ដេកដើរឈរ អង្គុយក៏មិនប្រក្រតី ព្រោះខ្លួនជាអ្នកមានពៀរ មានភ័យជុំវិញ បើអាចធ្វើបាន ទំនងព្យាយាមបៀតបៀនបង់កម្ចង់ពៀរឬប្រហារអ្នកដែលឃើញថាជាសត្រូវរបស់ខ្លួនប៉ុន្មាន ៗ នាក់ នោះគេចប់ផុតមិនមាន បើចង់ចាំបាន ច្រើនក៏គេតែមានច្រើន ព្រោះការធ្វើដូច្នេះជាការកះពៀរឲ្យយឺតវែងមិនមានពេលស្រាកស្រាន្ត កាលបើពៀរមិនស្ងប់រម្ងាប់ដោយបែបណា ទុក្ខភ័យសេចក្ដីក្ដៅក្រហាយចិត្ត រមែងមិនស្ងប់រម្ងាប់ដោយបែបនោះ ។

ព្រោះហេតុនោះ ព្រះបរមសាស្ដាចារ្យ កាលទ្រង់ពន្យល់ផ្លូវផុះដាលនៃពៀរ និងផ្លូវដែលស្ងប់រម្ងាប់នៃពៀរ ឲ្យឃើញច្បាស់ប្រចក្ស ហើយឲ្យខំបដិបត្តិតាមផ្លូវដែលស្ងប់រម្ងាប់នៃពៀរ ទើបត្រាស់ព្រះពុទ្ធភាសិតដាស់តឿនចិត្តយ៉ាងនេះថា :

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

ជនពួកណា ចងសេចក្ដីក្រោធទុកក្នុងចិត្តថា គេបានជេរយើង គេបានធ្វើប្រទូស្តរាយយើង គេបានផ្ចាញ់យើង គេបានលួចទ្រព្យយើងដូច្នេះ ពៀររបស់ជនពួកនោះ រមែងមិនស្ងប់រម្ងាប់បាន ។

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

ជនពួកណា មិនចងសេចក្តីក្រោធទុកក្នុងចិត្តថា គេបានជេរយើង គេបានធ្វើប្រទូសរ៉ាយយើង គេបានផ្ចាញ់យើង គេបានលួចទ្រព្យរបស់យើងដូច្នេះ ពៀររបស់ជនពួកនោះ រមែងស្ងប់រម្ងាប់ផុត ។

ទោសទុក្ខដែលកើតពីសេចក្តីប្រាថ្នាអាក្រក់ដល់គ្នាហៅថាពៀរ ពៀរនេះ រមែងមិនស្ងប់រម្ងាប់បានដោយពៀរ ម្នាក់ធ្វើសេចក្តីអាក្រក់ដល់គេមុន ម្នាក់ទៀតធ្វើសេចក្តីអាក្រក់នោះតបមកវិញ ដោយប្រាថ្នាឲ្យជាការសងសឹកដល់គ្នា ចង់បានឲ្យតែឈ្នះដៃរៀងៗខ្លួន ការធ្វើអាក្រក់ដល់គ្នាក៏រឹងរឹតតែមានកម្លាំងខ្លាំងច្រើនឡើង ព្រោះធ្វើអាក្រក់ដល់គ្នានឹងគ្នាច្រើនដងប៉ុណ្ណា ចិត្តគំនិតក៏រឹងរឹតតែអាក្រក់ពេញពោរទៅដោយអឃាតព្យាបាទវិហិង្សាដកប៉ុណ្ណោះ ប្រៀបដូចបុគ្គលប្រាថ្នានឹងលាងទីដែលមិនស្អាតឲ្យស្អាត តែបើយកទឹកស្មោកគ្រោកទៅលាង ក៏នាំឲ្យប្រឡាក់ស្មោកគ្រោករឹងរឹតតែខ្លាំងឡើង ឬប្រៀបដូចបុគ្គលប្រាថ្នានឹងលត់ភ្លើង ហើយយកកំញាមភ្លើង មានចំបើងឬឧសជាដើមទៅថែមក្នុងភ្លើងនោះទៀត ភ្លើងរមែងមិនរលត់ ត្រឡប់ជាឆេះកាន់តែខ្លាំងឡើង, ខនេះយ៉ាងណា ការធ្វើសេចក្តីអាក្រក់តបគ្នា ធ្វើការសងសឹកដល់គ្នាក៏ដូច្នោះដែរ រមែងជាការកៈពៀរឲ្យយឺតវែងទៅមិនមានទីបំផុត ត្រូវតាមពុទ្ធភាសិតដែលបានលើកមកតាំងទុកក្នុងខាងដើមថា :

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ប្រែថា ក្នុងកាលណាៗ ក៏ដោយ ពៀរទាំងឡាយរមែងមិនស្ងប់រម្ងាប់ ដោយពៀរទេ តែថាពៀរទាំងឡាយ រមែងស្ងប់រម្ងាប់បានដោយភាព ជាអ្នកមិនមានពៀរ ធម៌នេះ ជាធម៌មានយូរមកហើយ ។

ការបន្តពៀរ តបនឹងពៀរទៅវិញទៅមកដូច្នេះ ផលទីបំផុតក៏រមែង ដល់នូវការអន្តរធានទាំងអស់គ្នា ខនេះ គប្បីឃើញគួយ៉ាងភិក្ខុអ្នកនៅស្រុក កោសម្ពិក: អាស្រ័យហេតុអាងលេសបន្តិចបន្តួចធ្វើសេចក្តីអន្តរាយរវាង គ្នា មិនព្រមចុះចាញ់គ្នា សូម្បីព្រះបរមសាស្តាទ្រង់ហាមប្រាមពន្យល់ ណែនាំ ក៏មិនព្រមជឿស្តាប់ធ្វើតាម ព្រះអង្គក៏ទ្រង់រអាព្រះទ័យ ទើប ស្តេចគេចចេញចាកទីនោះ ទៅប្រថាប់នៅនាព្រៃរក្ខិតវ័នតែមួយព្រះអង្គ ឯង ភិក្ខុទាំងអស់នោះ មិនមានអ្នកណាជាទីពឹងបាន ក៏ទទួលសេចក្តី ទុក្ខលំបាកជាច្រើន ចំណេរតមកខាងក្រោយ ក៏ត្រឡប់បានជាសះ ស្បើយនឹងគ្នាវិញ ព្រះបរមសាស្តាទ្រង់ត្រាស់ប្រដៅឱ្យឃើញទោស នៃសេចក្តីប្រាថ្នាអាក្រក់ យកឈ្នះគ្នាដោយទោសចិត្តដូចពុទ្ធភាសិតថា ៖

បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ

យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ប្រែថា ពួកជនដទៃមិនដឹងថា ពួកយើងនាំគ្នាលំបាកក្នុងពួករបស់

យើងនេះឯង ក្នុងពួកដែលកំពៀតគ្នានេះ ពួកណាដឹងថា សេចក្ដីប្រកួតប្រកាន់គ្នា រមែងស្ងប់រម្ងាប់បានព្រោះជនពួកនោះ ៗ

អធិប្បាយថា ក្នុងបណ្ដាពួកជនដែលទាស់ទែងវិវាទគ្នា ពោលអាក្រក់ នឹងធ្វើអាក្រក់ដល់គ្នានោះ គ្រប់ៗខ្លួនក៏រមែងមិនដឹងថា យើងនាំគ្នាធ្វើសេចក្ដីលំបាកក្នុងពួកក្រុមជាមួយគ្នា តែលោកអ្នកដែលមានប្រាជ្ញាញាណឆ្លាតវាងវៃក្រៅពីពួកដែលបង្កពៀរធ្វើសឹកសត្រូវនឹងគ្នានោះ រមែងដឹងបានដោយល្អថា សេចក្ដីប្រាថ្នាអាក្រក់ដល់គ្នានឹងគ្នានឹងស្ងប់រម្ងាប់បាន ព្រោះលោកអ្នកដែលប្រកបដោយប្រាជ្ញាញាណ ភាសិតអម្បាលនេះឯង ៗ អវេរេន ច សម្មន្តិ តែថាពៀរ រមែងស្ងប់រម្ងាប់ដោយភាពជាអ្នកមិនមានពៀរ គឺម្នាក់ចងពៀរ តែម្នាក់ទៀតមិនបង្កពៀរតប ពៀរក៏នឹងរម្ងាប់បាន មិនដុះដាលតទៅទៀត គប្បីឃើញតួយ៉ាងតាមគោដកៈធ្វើសេចក្ដីប្រទូសរ៉ាយនឹងមឃមាណព តែមឃមាណពមិនបង្កពៀរតប ត្រឡប់ជាមានមេត្តាចិត្តផ្សាយសេចក្ដីល្អតបវិញ នឹងចោរដែលប្រទូសរ៉ាយសុមង្គលសេដ្ឋី តែសេដ្ឋីមិនប្រកាន់ទោស ត្រឡប់ជាឧទ្ទិសចំណែកកុសលដែលកើតអំពីការកសាងព្រះសុគន្ធកុដិថ្វាយព្រះពុទ្ធជាម្ចាស់ ឲ្យដល់ចោរអ្នកធ្វើសេចក្ដីប្រទូសរ៉ាយ នឹងរឿងព្រះសារីបុត្តដែលត្រូវព្រាហ្មណ៍ម្នាក់ប្រហារ ហើយលោកមិនប្រហារតបត្រឡប់មានមេត្តាតបវិញ ព្រាហ្មណ៍នោះ

ក៏ត្រឡប់មានចិត្តជ្រះថ្លា យ៉ាងនេះហៅថា ពៀរមែងស្ងប់រម្ងាប់បានដោយភាពជាអ្នកមិនមានពៀរ ។

ការប្រតិបត្តិក្នុងព្រះពុទ្ធសាសនានេះ និយមថា អ្នកដែលធ្វើសេចក្តីល្អតបឈ្មោះថា ជាអ្នកឈ្នះ អ្នកដែលធ្វើសេចក្តីអាក្រក់ឈ្មោះថា ជាអ្នកចាញ់ ព្រោះមនុស្សដែលធ្វើល្អ រមែងមានប្រៀបជាដរាប ព្រោះមិនបានធ្វើសេចក្តីអន្តរាយឲ្យកើតឡើងដល់អ្នកណា នឹងគួរបានទទួលសេចក្តីសរ-សើរថាជាអ្នកមានគុណធម៌ក្នុងចិត្ត មានខន្តីជាដើម ទើបរក្សាសេចក្តីល្អទុកបាន មិនធ្វើអាក្រក់ សូម្បីក្នុងខណៈដែលត្រូវធ្វើសេចក្តីអាក្រក់ការស្ងប់រម្ងាប់ពៀរបាន ដោយភាពជាអ្នកមិនមានពៀរនេះ ជាធម៌បរមបុរាណមានមកយូរយារណាស់ហើយ ។

បណ្ឌិតទាំងឡាយ ក្នុងបុរាណសម័យ បាននិយមគោរពរាប់អានប្រតិបត្តិធម៌នេះតៗមក ដរាបដល់សព្វថ្ងៃនេះ ព្រោះហេតុនោះ ព្រះមហាមុនីជាម្ចាស់ទើបត្រាស់ថា ឯស ធម្មោ សនន្តនោ ការស្ងប់រម្ងាប់ពៀរដោយភាពជាអ្នកមិនមានពៀរនេះ ជាធម៌ចាស់, ជាធម៌មានយូរយារណាស់មកហើយ ។

ព្រោះហេតុនោះ បុគ្គលអ្នកត្រូវការមិត្រ គប្បីអប់រំមេត្តាចិត្តឲ្យបានបរិបូណ៌ក្នុងខ្លួន នឹងការនាំលើកសេចក្តីល្អឲ្យបានរឿយៗ អ្នកមិនត្រូវការ

សត្រូវ គប្បីហាមប្រាមទោសចិត្ត គឺសេចក្ដីក្រេវក្រោធអឃាតព្យាបាទ រំហឹងសាឲ្យអស់ទៅ បើប្រាថ្នាជាអ្នកមិនមានពៀរ មិនមានភ័យក្នុងទិសទាំងពួងគួរព្យាយាមបដិបត្តិធម៌ពិត ៗ កុំឲ្យឃ្លៀងឃ្លាតអំពីពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាថា ៖

« ក្នុងកាលណា ៗ ក៏ដោយ ពៀរទាំងឡាយ រមែងមិនស្ងប់រម្ងាប់បានដោយពៀរ តែថា ពៀរទាំងឡាយ រមែងស្ងប់រម្ងាប់បានដោយភាពជាអ្នកមិនមានពៀរ ការស្ងប់រម្ងាប់ពៀរដោយការមិនចងពៀរនេះ ជាធម៌ចាស់ » ។

សាធុជន បពិត្រលោកអ្នកសប្បុរសទាំងឡាយ កាលបើប្រាថ្នាសេចក្ដីសុខចំរើន ទឹងប្រាថ្នាធ្វើខ្លួនឲ្យផុតពីសត្រូវ ទឹងប្រាថ្នាឲ្យជាអ្នកមានមិត្តភក្តិជុំវិញ ហែហមទៅមកដោយមនុស្សស្រឡាញ់ប្រាថ្នាល្អហើយ គប្បីចំរើនមេត្តាឲ្យជាគុណធម៌ប្រចាំចិត្តរបស់ខ្លួន នៅជិតជាមជាប់ជានិច្ចនិរន្តរ៍ ។

អាត្មាភាព សំដែងវេរុបសមកថា ពណ៌នាអំពីធម៌ចូលទៅស្ងប់រម្ងាប់ពៀរ ដូចបរិយាយដោយសង្ខេបខ្លី ៗ ខាងលើនេះ ក៏ល្មមសមគួរដល់ពេលវេលា សន្មតថាចប់ត្រឹមប៉ុណ្ណេះ ។

# លោកបាលធម៌

របស់ព្រះមហាមាស–ស៊ុមង់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ ចំពោះព្រះភគវន្តមានីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ ទាំងព្រះអរិយសង្ឃ ដោយសេចក្តីគោរព)

វេលានេះ អាត្មាភាពសូមសំដែងអំពី លោកបាលធម៌ ដើម្បីសវនាការដូចតទៅនេះ

ពាក្យថា «លោកបាលធម៌» ប្រែថា "ធម៌រក្សាលោក" ឬហៅថា "ទេវធម៌"

ដូចមានក្នុងខុទ្ទកនិកាយធម្មបទថា

ហិរិ ឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា
សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។

សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិនិង ឱត្តប្បៈ ជាអ្នកមានចិត្តដំកល់នៅក្នុងធម៌ស អ្នកប្រាជ្ញពោលថា ជាបុគ្គលមានទេវធម៌ក្នុងលោក ។

ក្នុងទីឃនិកាយត្រង់សង្គីតិសូត្រនៃពួកធម៌ពីរ មានបាលីថា

អហិរិកញ្ច អនោត្តប្បញ្ច ។ ហិរិ ច ឱត្តប្បញ្ច ។

សេចក្តីមិនខ្មាសបាប ១ សេចក្តីមិនក្តៅនឹងបាប ឬមិនខ្លាចបាប ១ ។-

សេចក្តីខ្មាសបាប ១ សេចក្តីក្តៅនឹងបាប ១ ។

ហិរិ នឹង ឱត្តប្បៈ ក្នុងអាគតដ្ឋានផ្សេង ៗ ហៅថា “ទេវធម៌” ខ្លះ, ហៅថា “អរិយទ្រព្យ” ខ្លះ, ហៅថា “លោកបាលធម៌” ខ្លះ ។

សូមអធិប្បាយអំពីពាក្យថា “លោក” ជាខាងដើម

“លោក” នេះ បានដល់សភាវៈដែលកើតមានឡើងហើយមិនតាំងនៅដោយទៀងទាត់ តែងតែប្រែឈមមុខទៅរកសេចក្តីវិនាសបាត់បង់សូន្យវិញ ក្នុងពេលណាមួយ ហៅថា “លោក” ។ លោកមានច្រើន តែបើបំព្រួញឲ្យខ្លីចុះមក មានត្រឹមតែ ៣ យ៉ាងគឺ សង្ខារលោក១, សត្តលោក ១, ឱកាសលោក ១ ។

សេចក្តីអធិប្បាយ

រូបធម៌ នឹងអរូបធម៌ទាំងឡាយដែលកើតមានឡើង ដូចជាពួកសត្វទាំងអស់ដែលមានអត្តភាពតាំងនៅបានដោយសារអាហារក្តី នាមនឹងរូបក្តី វេទនា៣យ៉ាង មានសុខវេទនាជាដើមក្តី អាហារ៤យ៉ាង មានកវឡិង្ការាហារជាដើមក្តី អាយតនៈខាងក្នុង ៦ យ៉ាង មានចក្ខាយតនៈជាដើមក្តី វិញ្ញាណដ្ឋិតិ ៧ យ៉ាង មាននានត្តកាយ នានត្តសញ្ញីគឺ (ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាក៏ផ្សេងគ្នា ) ជាដើមក្តី លោកធម៌៨យ៉ាង មានលាភៈនឹងអលាភៈជាដើមក្តី សត្តាវាសៈ៩ យ៉ាង មានវិញ្ញាណដ្ឋិតិជាដើមក្តី អាយតនៈ ១២ មានចក្ខាយតនៈនឹងរូបាយតនៈជាដើមក្តី ធាតុ ១៨យ៉ាង

មានចក្ខុធាតុជាដើមក្តី ប៉ុណ្ណេះជាដើម ហៅថា "សង្ខារលោក" ប្រែថា លោកគឺសង្ខារ ដែលជាភ្នាក់ងារខាងការតាក់តែងឲ្យចំរើនឲ្យវិនាស ។

ពួកមនុស្ស ទាំងប្រុស ទាំងស្រី ទោះមានបុណ្យ ឬឥតបុណ្យ, មានកិលេស ឬឥតកិលេស, មានប្រាជ្ញា ឬឥតប្រាជ្ញា, ល្អ ឬអាក្រក់ក្តី ; ពួកអមនុស្ស គឺទេវតា, មារព្រហ្ម, យក្ស ទាំងគន្ធព្វជាដើមក្តី តែងអាស្រ័យនៅក្នុងលោកទាំងបី ។ ប្រភេទសត្វទាំងអស់នេះ រួមមកតែពាក្យមួយហៅថា "សត្តលោក" ប្រែថា លោកគឺពួកសត្ត ។

លោកទាំងមូលដូចគាផ្ទះសម្រាប់ទ្រទ្រួតគ ៗ គ្នា គឺខ្យល់ទ្រទឹក ទឹកទ្រដី ៗ ទ្រឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណមានមនុស្សជាដើម និងអនុបាទិន្នកសង្ខារ គឺសង្ខារដែលឥតវិញ្ញាណ មានរុក្ខជាតិ, តិណជាតិ និងភ្នំ ថ្ម ជាដើម ឬសំដៅយកផ្ទៃក្រៅឡទាំងមូល ឬសំដៅយកឱកាស ដែលព្រះអាទិត្យនិងព្រះចន្ទដើរបំភ្លឺលោកអស់ទីត្រឹមណា ទីត្រឹមនោះហៅថា "ឱកាសលោក" ប្រែថា លោក គឺឱកាស (ដែលមិនមែនជាមនុស្សសត្វ) ។

ឯពាក្យថា លោកនេះ ខេមរជនយើងច្រើននិយមរាប់អានថាជាពាក្យថ្លៃថ្នូរ, ពាក្យគួរសម សម្រាប់ប្រើហៅមនុស្សអ្នកមានបុណ្យយសស័ក្តិ-អំណាច ឬហៅព្រះសង្ឃទូទៅ តែបើតាមពិតវិញ ពាក្យថា លោកនេះ ជាពាក្យសាធារណៈ អាចហៅបានគ្រប់សព្វសត្វនិងសង្ខារ

ទាំងអស់ ៗ អ្នកប្រាជ្ញខាងធម្មសាស្ត្រទាំងឡាយ មានព្រះពុទ្ធជាដើម តែងប្រមូលយកសង្ខារទាំងមានវិញ្ញាណទាំងឥតវិញ្ញាណ ហៅថា "លោក" ព្រោះយល់ថា លោកនេះ ដែលកើតឡើងចុះនជារូបរាងហើយ មិនដែលតាំងនៅទៀងទាត់ទេ តែងចំរើនក្នុងខាងដើម ប្រែប្រួលក្នុងវេលាកណ្តាល ហើយត្រូវបាត់បង់ទៅវិញនៅទីបំផុត ៗ

ន័យមួយទៀត ពាក្យដែលយើងនិយមប្រើហៅឈ្មោះ សត្វ និងសង្ខារ សព្វថ្ងៃនេះ ដូចពាក្យថា មនុស្ស សត្វ ប្រុស ស្រី ឈើ ភ្នំ ថ្ម ជាដើម សុទ្ធតែជាពាក្យលោកវោហារទាំងអស់ គឺជាសំដីនិយាយហៅដោយការសន្មតិទៅតាមភេទ លក្ខណៈ អាការៈ លំនាំរបស់សត្វនិងសង្ខារ ដែលផ្សេងគ្នាប៉ុណ្ណោះ មិនមែនជាសំដីពិតទៅតាមផ្លូវបរមត្ថ-សាស្ត្រទេ, បើហៅតាមផ្លូវបរមត្ថសាស្ត្រវិញ ទើបជាពាក្យពិត ៗ

ឧទាហរណ៍ដូចជា មនុស្សម្នាក់ ដែលយើងយកមកឲ្យឈរនៅក្នុងទីចំពោះមុខ ហើយពិចារណាវែករកពាក្យដែលគេហៅថា "មនុស្ស" នោះ គឺមុខជានឹងរកពុំឃើញឡើយ គឺឃើញតែធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ទាំងអស់ ៗ បើដូច្នេះ តើពាក្យថា មនុស្សប្រុសស្រីនេះនៅត្រង់ណា ? ឯសង្ខារទាំងពួងក៏ដូច្នោះដែរ ,

ម្យ៉ាងវិញទៀត ដូចពាក្យដែលយើងធ្លាប់ហៅថា ផ្ទះ ជា សាលា បើពិចារណាវែករកទៅក៏ឃើញតែសសរ ធ្នឹម ផ្ទាំង បង្អួច ដៃរណែង ៗល។

មានឈ្មោះដោយឡែកៗពីគ្នាទាំងអស់, បើដូច្នេះ ពាក្យថា ផ្ទះថាសាលានោះ លុះតែគ្រប់សម្ភារៈ, ហេតុនោះ ពាក្យថា មនុស្សប្រុសស្រីថាផ្ទះសាលាប៉ុណ្ណោះជាដើម សុទ្ធតែហៅដោយសន្មតិតាមលោកវោហារ មិនមែនជាពាក្យពិតតាមផ្លូវបរមត្ថសាស្ត្រឡើយ ។

វត្ថុធាតុ ដែលមានឈ្មោះគេហៅដោយពាក្យ ជាលោកវោហារក្តី ដោយពាក្យជាបរមត្ថក្តី រួមមកហៅថា លោកៗដូចគ្នាទាំងអស់ ។

បណ្តាលោកទាំងនោះ ក្នុងទីនេះ សំដៅយកសត្វលោក គឺមនុស្សៗ មនុស្សនេះឯង តែងមានសេចក្តីវិនាសអន្តរាយទៅដោយប្រការផ្សេងៗ ឯធម៌ដែលគ្រប់គ្រងរក្សាមនុស្សឲ្យបានសេចក្តីសុខ ចំរើន នឹងសន្តិភាព ហៅថា "លោកបាលធម៌ ។ លោកបាលធម៌នេះ មាន២ យ៉ាងគឺ: ហិរិ១ ឱត្តប្បៈ១ ។

ហិរិ ប្រែថា "សេចក្តីខ្មាសបាប" គឺ (ធម្មជាតិ) ខ្មាសព្រើម អំពើទុច្ចរិត មានកាយទុច្ចរិតជាដើម ។

ឱត្តប្បៈ ប្រែថា "សេចក្តីខ្លាចបាប" គឺ (ធម្មជាត) តក់ស្លុត ឬខ្លាចអំពើទុច្ចរិតមានកាយទុច្ចរិតជាដើម ។

## សេចក្តីអធិប្បាយ

១-ហិរិ សេចក្តីខ្មាសបាប ជាអជ្ឈត្តសមុដ្ឋាន (មានហេតុខាង

ក្នុងជាសមុដ្ឋាន) បានសេចក្តីថា ហិរិ កើតឡើងព្រោះពិចារណាហេតុ ៤ យ៉ាងគឺ :

១-ជាតឹ បច្ចវេក្ខិត្វា ព្រោះពិចារណាជាតិ;

២-វយំ បច្ចវេក្ខិត្វា ព្រោះពិចារណាវ័យ;

៣-សូរភាវំ បច្ចវេក្ខិត្វា ព្រោះពិចារណាសូរភាព;

៤-ពាហុសច្ចំ បច្ចវេក្ខិត្វា ព្រោះពិចារណាពាហុសច្ចៈ ។

ពាក្យថា "ព្រោះពិចារណាជាតិ" បានសេចក្តីថា ជាតិមានពីរ. យ៉ាងគឺ ជាតិខ្ពង់ខ្ពស់ ១ ជាតិថោកទាប ១ ។

បុគ្គលអ្នកមានជាតិខ្ពង់ខ្ពស់ កាលបើជួបប្រទះនឹងអំពើបាប មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ក៏ពិចារណាថា អាត្មាអញមានជាតិខ្ពង់ខ្ពស់ ដោយមហាកុសល ដែលខ្លួនបានធ្វើអំពីអតីតមកពិតៗ បើប្រសិនជាខ្លួនប្រព្រឹត្តធ្វើនូវអំពើបាបនេះ មុខជានឹងបាននូវជាតិដ៏ថោកទាប ក្នុងកាលអនាគតជាពុំខាន លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្តីខ្មាសបាបឲ្យកើតឡើង លែងធ្វើអំពើបាបមានបាណាតិបាតជាដើម ។

ចំណែកបុគ្គលមានជាតិដ៏ថោកទាបវិញ កាលបើជួបប្រទះនឹងបាបកម្ម មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបានហើយពិចារណាថា អាត្មាអញដែលមានជាតិដ៏ថោកទាបយ៉ាងនេះ ក៏ព្រោះតែបាននូវអំពើ

អាក្រក់មានបាណាតិបាតជាដើម អំពីអតីតជាតិដោយពិត ប្រសិនបើអាត្មាអញធ្វើនូវអំពើដ៏លាមកនេះ ទៅអនាគតជាតិ អាត្មាអញមុខជានឹងមានជាតិជាកតាបជាងនេះទៀតមិនខាន លុះពិចារណាដូច្នេះហើយ ក៏ញាំងហិរិសេចក្ដីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្មមានបាណាតិបាតជាដើម ។

ហិរិ កើតឡើង ព្រោះពិចារណាជាតិដូច្នេះ ឈ្មោះថា "ព្រោះពិចារណាជាតិ" ។

ពាក្យថា "ព្រោះពិចារណាវ័យ" សេចក្ដីថា វ័យមាន ៣ យ៉ាងគឺៈ បឋមវ័យ ១ មជ្ឈិមវ័យ ១ បច្ឆិមវ័យ ១ ។

វ័យគឺជំនាន់ ឬ រយៈកាលនៃអាយុដែលនៅក្មេងហៅថា បឋមវ័យ, ជំនាន់កណ្ដាល ហៅថា មជ្ឈិមវ័យ, ជំនាន់ដែលចាស់ ហៅថា បច្ឆិមវ័យ ។

បុគ្គលដែលស្ថិតនៅក្នុងបឋមវ័យ, កាលជួបប្រទះនឹងបាបកម្ម មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបានហើយពិចារណាថា អំពើដ៏លាមកនេះ អាត្មាអញមិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញាំងហិរិសេចក្ដីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្ម មានបាណាតិបាតជាដើម ។

បុគ្គលតាំងនៅក្នុងមជ្ឈិមវ័យ, កាលជួបប្រទះនូវបាបកម្មមានបាណាតិ-បាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើអាក្រក់នេះ

អាត្មាអញជាមនុស្សធំ ដឹងគុណ-ទោស-ខុស-ត្រូវ-ល្អ-អាក្រក់-បុណ្យបាបសព្វគ្រប់ហើយ មិនគួរបើធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្ដីខ្មាសបាបឲ្យកើតឡើងមិនធ្វើនូវបាបកម្មមានបាណាតិបាតជាដើម ។

បុគ្គលដែលតាំងនៅក្នុងបឋមវ័យ, កាលជួបប្រទះនូវអំពើអាក្រក់ដែលខ្លួនល្មមធ្វើបាន ក៏ពិចារណាថា អាត្មាអញនេះ ជាមនុស្សចាស់ទ្រេមទ្រមយ៉ាងនេះ មិនគួរធ្វើនូវអំពើដ៏លាមកទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្ដីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្មមានបាណាតិបាតជាដើម ។

ហិរិ កើតឡើងព្រោះបុគ្គលពិចារណាវ័យ ៣ យ៉ាង ដូច្នេះឈ្មោះថា "ព្រោះពិចារណាវ័យ" ។

ពាក្យថា "ព្រោះពិចារណាសូរភាព" សេចក្ដីថា ភាពនៃបុគ្គលអ្នកមានកម្លាំងក្លៀវក្លាអង់អាច ហៅថា សូរភាព ។ បុគ្គលអ្នកមានសូរភាពនោះ គ្រហស្ថក្ដី បព្វជិតក្ដី កាលជួបប្រទះនឹងបាបកម្ម មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើអាក្រក់នេះ អាត្មាអញជាមនុស្សក្លៀវក្លាក្នុងទីប្រជុំ មិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិ សេចក្ដីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្ម ដូច្នេះឈ្មោះថា "ព្រោះពិចារណាសូរភាព" ។

ពាក្យថា «ព្រោះពិចារណាពាហុសច្ចៈ» សេចក្ដីថា ភាពនៃបុគ្គល

អ្នកចេះដឹងច្រើន, អ្នកស្ដាប់ជំនាញច្រើន ហៅថាពាហុសច្ចៈ ។ បុគ្គលអ្នកមានពាហុសច្ចៈ កាលបើជួបប្រទះនឹងបាបកម្មដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើដ៏លាមកនេះ អាត្មាអញជាអ្នកចេះដឹងច្រើន, ជាអ្នកស្ដាប់ជំនាញច្រើន មិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្ដីខ្មាសបាបឲ្យកើតមានឡើង ដូច្នេះឈ្មោះថា "ព្រោះពិចារណាពាហុសច្ចៈ" ។

ហិរិ សេចក្ដីខ្មាសបាបជាអជ្ឈត្តសមុដ្ឋាន ( មានហេតុខាងក្នុងជាសមុដ្ឋាន ) ព្រោះពិចារណាហេតុ៤យ៉ាង ដោយប្រការដូច្នេះ ។

ហិរិ ឈ្មោះថា ជិគុច្ឆនលក្ខណៈ( មានការខ្ពើមបាបជាលក្ខណៈ) ឬជា សប្បតិស្សវលក្ខណៈ ( មានការជឿស្ដាប់ជាលក្ខណៈ ) ដោយប្រការដូច្នេះ ។

ហិរិ ជាអករណរសៈ (មានការមិនធ្វើបាបជាកិច្ច)

ហិរិ ជាសង្កោចនប្បច្ចុបដ្ឋាន មានការរួញរាអង្គការធ្វើបាបមានបាណាតិបាតជាដើមជាផល ។

ហិរិ ជាអត្តគារវបដ្ឋាន (មានការគោរពខ្លួន) គឺប្រារព្ធយកខ្លួនជាធំ ហើយមិនធ្វើនូវបាបទាំងឡាយជាហេតុ ។

២ ឱត្តប្បៈ សេចក្ដីខ្លាចបាប ជាពហិទ្ធាសមុដ្ឋាន ( មានហេតុខាងក្រៅជាសមុដ្ឋាន ), សេចក្ដីថា បុគ្គលកាលជួបប្រទះនឹងបាបកម្មដែល

ខ្លួនល្មមធ្វើបាន ហើយគិតក្រែងតែងហេតុខាងក្រោយថា បើអ្នកនឹងធ្វើនូវបាបកម្ម អ្នកមុខជានឹងដល់នូវសេចក្ដីតិះដៀល គង់ចំណោមបរិសទ្យទាំងបួនចំពូកជាពុំខាន ហើយពិចារណាថា: អ្នកចេះដឹងទាំងឡាយនឹងតិះដៀលអ្នក ដូចជាបុគ្គលមានអនាម័យមែងស្អប់ខ្ពើមនូវគូថមិនស្អាតស្មោកគ្រោកដូច្នោះ អ្នកឯងត្រូវលោក អ្នកមានសីលទាំងឡាយចៀសវាងហើយ នឹងធ្វើដូចម្ដេចកើត ? លុះពិចារណាដូច្នេះហើយ ក៏មិនហ៊ានធ្វើបាបកម្ម មានបាណាតិបាតជាដើម ។

ឱត្តប្បៈ ជាលោកាធិបតេយ្យ ( មានលោកជាធំ ) សេចក្ដីថា កុលបុត្រខ្លះ គង់លោកនេះ ប្រារព្ធយកលោកជាអធិបតី គឺយកអ្នកដទៃឲ្យជាធំថា លោកសន្និវាសនេះ ធំណាស់, សមណព្រាហ្មណ៍ទាំងឡាយអ្នកមានឫទ្ធិ មានចក្ខុទិព្វ ដឹងចិត្តរបស់អ្នកដទៃ តែងមាននៅក្នុងលោកសន្និវាសដ៏ធំនេះឯង ។ ពួកលោកទាំងនោះមើលឆ្ងាយក៏បាន , ជិតក៏បាន , ដឹងចិត្តដោយចិត្តបាន ។ បើពួកលោកដឹងអញហើយ មុខជានិយាយនឹងគ្នាលោក យ៉ាងនេះថា: " នែលោក ដ៏ចំរើនទាំងឡាយ ! លោកចូរមើលកុលបុត្រនេះ ចេញចាកផ្ទះមកបួសដោយសទ្ធា ហើយនៅតែប្រឡាក់ប្រឡូសដោយអកុសលធំលាមកទាំងឡាយទៀត " ។ ពួកទេវតាអ្នកមានឫទ្ធិ មានចក្ខុទិព្វ ដឹងចិត្តរបស់អ្នកដទៃតែងមាននៅប្រាកដគង់លោក ពួកទេវតាទាំងនោះមើលឆ្ងាយក៏បាន , ជិតក៏បាន , ដឹងចិត្ត

ដោយចិត្តក៏បាន , បើពួកលោកនឹងឃើញហើយ មុខជានិយាយនឹងគ្នាលោកយ៉ាងនេះថា: «នែលោកដ៏ចំរើនទាំងឡាយ ! លោកចូរមើលកុលបុត្រនេះចេញចាកផ្ទះមកបួសដោយសទ្ធា ហើយនៅតែប្រឡូកប្រឡាក់ដោយអកុសលដ៏លាមកទាំងឡាយទៀត» ។ លុះពិចារណាដូច្នេះហើយកំចាត់កិលេសអកុសលចេញ ហើយចំរើននូវកុសលឲ្យកើតឡើង លះកម្មមានទោសចេញ ញុំាងកម្មមិនមានទោសឲ្យចំរើនឡើង យ៉ាងនេះឈ្មោះថារក្សាខ្លួនឲ្យបរិសុទ្ធ ។

ឱត្តប្បៈ ឈ្មោះថា ជាលោកាធិបតេយ្យ (មានលោកជាធំ) ដោយប្រការដូច្នេះឯង ។

ឱត្តប្បៈ ឈ្មោះថា ភយសភាវសណ្ឋិតៈ (តាំងនៅដោយសភាពគឺសេចក្តីតក់ស្លុតភ័យក្នុងអបាយ) ហើយមិនហ៊ានធ្វើបាប ព្រោះខ្លាចអបាយនោះ ដូចជាបុគ្គលអ្នកមានប្រាជ្ញាមិនហ៊ានចាប់ដុំដែកក្តៅ ដែលភ្លើងកំពុងឆេះរន្ទាលប្រាលឆ្អៅ ព្រោះខ្លាចរលាកដូច្នោះ ។

ឱត្តប្បៈ តាំងនៅដោយសភាពគឺសេចក្តីខ្លាចបាប ដោយប្រការដូច្នេះ ។

ឱត្តប្បៈ ជាឧត្តាសលក្ខណៈ (មានសេចក្តីតក់ស្លុត) ចំពោះអំពើបាបជាលក្ខណៈ ឬជា វជ្ជភីរុកភយទស្សាវីលក្ខណៈ (មានការខ្លាចទោសនឹងឃើញភ័យជាលក្ខណៈ) មាន ៤ យ៉ាងគឺ:

១-អត្តានុវាទភ័យ ខ្លាចខ្លួនឯង តិះដៀលខ្លួនឯងបាន,

២-បរានុវាទភ័យ ខ្លាចបុគ្គលដទៃ តិះដៀលខ្លួនឯងបាន,

៣-ទណ្ឌភ័យ ខ្លាចព្រះរាជអាជ្ញា,

៤-ទុគ្គតិភ័យ ខ្លាចភ័យក្នុងទុគ្គតិ ។

ឱត្តប្បៈ ឈ្មោះថា ឧត្តាសលក្ខណៈ (មានការតក់ស្លុតខ្លាចបាបជាលក្ខណៈ) ឬជា វជ្ជភិរុកភយទស្សាវិលក្ខណៈ (មានការខ្លាចទោសឬឃើញភ័យ) ក្នុងហេតុខាងក្រៅ ៤ យ៉ាង មិនហ៊ានធ្វើបាបជាលក្ខណៈ ដោយប្រការដូច្នេះ ។

ឱត្តប្បៈ ជាអករណរសៈ មានការមិនធ្វើបាបជាកិច្ច ។

ឱត្តប្បៈ ជាសង្កោចនបច្ចុបដ្ឋាន មានអាការអាក្រែងរអែងក្នុងការធ្វើបាបជាផល ។

ឱត្តប្បៈ ជាបរគារវបទដ្ឋាន (មានការគោរពកោតក្រែងបុគ្គលដទៃ) ហើយមិនហ៊ានធ្វើបាបជាហេតុ ។

ហិរិនិង ឱត្តប្បៈ ទាំងពីរនេះ ជាធម៌គ្រប់គ្រងរក្សាបុគ្គលអ្នកប្រព្រឹត្តសុចរិតធម៌ ឲ្យបានទទួលនូវសេចក្ដីសុខ-ចំរើន មិនឲ្យមានសេចក្ដីទុក្ខ វិនាស អន្តរាយ ។ ជាធម៌មានគុណប្រាកដក្នុងការវៀរចាកបាប រីឯបុគ្គលអ្នកប្រព្រឹត្តធម៌ទាំងពីរប្រការនេះ ទើបបានឈ្មោះថា ជាអ្នកមានអំពើល្អ ទើបឈ្មោះថា ជាមនុស្សធម៌ ជាអំពើឲ្យអភ័យដល់ជីវិត,

ទ្រព្យសម្បត្តិ, ទឹកខ្មៅនិងទឹកដីរបស់អ្នកដទៃ ឈ្មោះថា ជាអំពើនាំមកនូវសេចក្តីសុខចំរើន ដល់អ្នកដទៃផង ដល់ខ្លួនឯងផង កាលពីមានជីវិតរស់នៅ លុះស្លាប់ទៅរមែងមិនទៅកាន់ទុគ្គតិឡើយ ។

ហេតុនេះហើយ បានជាព្រះមានព្រះភាគទ្រង់ត្រាស់សរសើរអំពីអានិសង្សនៃបុគ្គលអ្នកប្រព្រឹត្តធម៌ ដូចមានក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយ ត្រង់យមកវគ្គថា :

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ធម៌ហ្នឹងឯង រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ កាលបើបុគ្គលសន្សំធម៌ដោយប្រពៃហើយ រមែងបាននូវអានិសង្សបែបនេះមិនខាន, បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិឡើយ ។

ធម៌ទាំងពីរប្រការគឺ: ហិរិនិងឱត្តប្បៈនេះ រមែងឃុំគ្រងរក្សាលោក (គឺពួកសត្វ) អ្នកប្រព្រឹត្ត ឲ្យជាគណៈជាក្រុម នៅជាសុខសប្បាយ ដូចជាមាតាបិតារក្សាបុត្តធីតាឲ្យបានសេចក្តីសុខ វៀរមិនឲ្យបៀតបៀនគ្នានឹងគ្នាដូច្នោះ ។

មែនពិត មនុស្សក្នុងលោកនេះ ដែលហ៊ានប្រព្រឹត្តឈ្លានពាន

មានការកាប់សម្លាប់គ្នា លួចប្លន់ឆក់ដណ្ដើមទ្រព្យសម្បត្តិទឹកដៃនឹងទឹកដីគ្នា ធ្វើគ្នានឹងគ្នាឲ្យវិនាសអន្តរាយដោយប្រការផ្សេងៗ ជាច្រើនបែបច្រើនយ៉ាងនោះ ក៏ព្រោះតែគ្មានធម៌ពីរប្រការនេះ សំរាប់គ្រប់គ្រងថែរក្សា ។ ដូច្នេះ បើជនទាំងឡាយក្នុងលោកសន្និវាស មានធម៌ពីរប្រការនេះ គ្រប់គ្រងរក្សាហើយ មុខជាមិនមានការបៀតៈបៀនគ្នាឡើយ ។ អាស្រ័យការមិនបៀតបៀនគ្នានេះ សេចក្ដីសុខ ក៏នឹងកើតមានឡើងជាប្រាកដ សមនឹងពុទ្ធដីកាថា អព្យាបជ្ជំ សុខំ លោកេ ការមិនបៀតបៀនគ្នា ជាសុខ ក្នុងលោក ។

អ្នកប្រាជ្ញទាំងឡាយតែងឃើញធម៌ខ្មៅ គឺ អហិរិកៈ នឹងអនោត្តប្បៈ ថាជា ( អំពើដ៏លាមក ) ទើបមានធម៌ស គឺ ហិរិនឹងឱត្តប្បៈ ស្អប់ខ្ពើមអំពើទាំងនេះ ដូចជាគេខ្ពើមខ្លាចពស់អសិរពិសដែលពេនត្រាំក្នុងលាមក ។

មួយវិញទៀត លោកទាំងឡាយមានមាតា-ម្ដាយមីង-ម្ដាយធំ នឹងភរិយារបស់អាចារ្យជាដើម បើធម៌សទាំងពីរនេះ មិនរក្សានូវលោកទេ លោកទាំងឡាយនោះ ក៏មិនប្រាកដជាជាអ្វី ក្នុងលោកនេះដែរ គឺ មុខជានឹងដល់នូវសម្ភេទ ដូចសត្វតិរច្ឆានជាពុំខាន ។

សមដូចពុទ្ធភាសិតថា:

ទ្វេមេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ ។
កតមេ ទ្វេ ។ ហិរិ ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ
ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ ន យិធ បញ្ញា.

យេថ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា សម្ភេទំ លោកោ អគមិស្ស យថា អជេឡកា កុក្កុដសូករា សោណសិ គាលា ។

“ ម្នាលភិក្ខុទាំងឡាយ ធម៌សទាំងពីរនេះ តែងរក្សានូវលោក ។ ធម៌សទាំងពីរនេះ តើដូចម្តេច ? ធម៌សទាំងពីរនោះគឺ: ហិរិ១ ឱត្តប្បៈ១ ។ ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌សទាំងពីរនេះមិនរក្សានូវលោកទេ, លោកគឺមាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ភរិយារបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី ក៏មិនប្រាកដក្នុងលោកដែរ មុខជាដល់នូវសម្ភេទ (ការច្របូកច្របល់) ដូចជាសត្វតិរច្ឆានគឺ ពពែ, ចៀម, មាន់, ជ្រូក, ឆ្កែនិងចចកជាដើមពុំខាន ” ។

ធម៌សពីរយ៉ាងគឺ ហិរិ និង ឱត្តប្បៈនេះ ជាឫសគល់នៃកុសលធម៌ទាំងពួង ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មានកាមាវចរភូមិជាដើម ជាធម៌ឃុំគ្រងរក្សាលោកឲ្យបានសន្តិភាព មិនឲ្យប្រព្រឹត្តទុច្ចរិតមានការកាប់សម្លាប់គ្នាជាដើម ទើបឈ្មោះថា “ លោកបាលធម៌ ” ដូច្នេះ ។

ក្នុងទេវធម្មជាតកថា: សាធុជនទាំងឡាយអ្នកប្រកបដោយហិរិនិងឱត្តប្បៈ អ្នកដំកល់នៅមាំក្នុងធម៌ស អ្នកស្ងប់រម្ងាប់ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ហៅថា “ អ្នកទ្រទ្រង់នូវទេវធម៌ក្នុងលោក ” ។

ពណ៌នា អំពីលោកបាលធម៌ ចប់តែប៉ុណ្ណេះ ឯង ។

# សុរពជាតក

(តមក)

លោក ចង-វង ចម្លងពីសាស្ត្រាស្លឹករឹត

---

ប្រាជ្ញាអ្វី ៗ ក៏នឹងថ្វាយតាមសព្វព្រះរាជហឫទ័យ ។ រាជទូតទទួលព្រះរាជសារនាំចូលទៅដល់ទ្វារព្រះរាជវាំង ហើយប្រាប់ដល់អាមាត្យឲ្យនាំសេចក្ដីនេះទៅក្រាបទូលដល់ព្រះបរមក្សត្រាធិរាជ ។ លុះទ្រង់ជ្រាបហើយព្រះមហាក្សត្រ ក៏ទ្រង់ឲ្យរាជទូតនោះចូលទៅក្រាបបង្គំគាល់ ហើយត្រាស់សួរថា កុតោ អាគតោសិ ម្នាលរាជទូត! អ្នកមកពីប្រទេសណា ? ។ រាជទូតក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំមកពីនគរឈ្មោះដូច្នេះៗ ។ កស្មា អាគតោសិ ស្ដេចមានព្រះរាជឱង្ការត្រាស់ដណ្ដឹងសួរថា ចៅមកតើមានប្រាជ្ញាអ្វី? ។ រាជទូតក្រាបទូលតាមដំណើរហើយថ្វាយព្រះរាជសារចំពោះព្រះមហាក្សត្រ ។ ស្ដេចឲ្យអាមាត្យម្នាក់មើលជ្រាបសេចក្ដីសព្វគ្រប់ហើយ មានព្រះបន្ទូលថា ភោ រាជទូត ម្នាលរាជទូតដ៏ចំរើន! យោ ច រីកុមារណា បេះប្រលោមលួងលោមព្រះរាជធីតានៃយើងឲ្យសោមនស្សក្ដី ឲ្យចរចាជាមួយក្ដី យើងនឹងអភិ-សេកជាឧត្ដមហេសីនៃព្រះរាជកុមារនោះ ព្រមទាំងឲ្យសោយរាជសម្បត្តិជាក្សត្រប្រសើរស្នងនៃយើងហោង, ហៃរាជទូត ! ចូរទៅនាំពាក្យនៃយើងទៅទូលព្រះរាជកុមារជាម្ចាស់ចៅហោង។ រាជទូតទទួលព្រះរាជឱង្ការស្រេច

ហើយ, ត្រឡប់មកក្រាបទូលព្រះរាជកុមារវិញ ។ ឯព្រះរាជកុមារក៏ទ្រង់គ្រឿងប្រដាប់លីលា យាត្រាចូលទៅគាល់ព្រះបាទវេច្ចមារជិតរាជ អង្គុយទៅក្នុងទីដ៏សមគួរ ។ ក្សណនោះ ព្រះបាទវេច្ចមារជិតរាជ ស្តេចទតទៅយល់ព្រះរាជកុមារ មានព្រះកាយល្អប្រពៃ ទ្រង់ពិចារណាថា អហោនុ! ព្រះរាជកុមារនេះ គួរពិតពិលរមិលមើល ប្រកបដោយលក្ខណាសួស្តី មានឧកាសដំរុងរឿង ដូចជាទេវបុត្តច្យុតពីមានទេវលោកនាយ ស្តេចទ្រង់ព្រះពិត្តាដូច្នោះហើយ មានព្រះបន្ទូលទៅតាមអធ្យាស្រ័យ ហើយត្រាស់ប្រើឲ្យទៅស្ថាននាប្រាសាទព្រះរាជធីតា ។ ព្រះរាជកុមារក៏បង្គំលាចូលទៅកាន់ប្រាសាទព្រះរាជធីតា ទ្រង់ព្រះដំរិះថា អាត្មាអញស្រដីនឹងរបស់អ្វីជាមុន លុះទតទៅយល់ចំពៀនព្រះទំរង់ ដែលព្រះរាជធីតាកំពុងទ្រង់ ក៏រាយមន្តបែងប័ត្តដាក់ក្នុងចំពៀនព្រះទំរង់ ដាស់គាថាផ្ញុំបញ្ចូលទៅ ទើបព្រះរាជកុមារហៅចំពៀនព្រះទំរង់ថា ម្នាលចំពៀន ! ។ ចំពៀនព្រះទំរង់ ក៏ឆ្លើយថា គឺ សាមិ បពិត្រអ្នកជាម្ចាស់ ! ហៅខ្ញុំម្ចាស់មានហេតុអ្វី ? ។ ព្រះរាជកុមារត្រាស់ថា ម្នាលចំពៀន! យើងប្រាថ្នាចង់ស្រដីនឹងព្រះនាងកល្យាណី តែព្រះនាងកល្យាណីពុំស្រដីនឹងយើង ទើបយើងស្រដីនឹងចៅ តើចៅស្រដីនឹងយើងឬទេ? ។ – បពិត្រព្រះរាជកុមារ ! បើអម្ចាស់ត្រាស់នឹងខ្ញុំ ៗ ស្រដីហោង ។ – បើដូច្នោះយើងនឹងដណ្តឹងសួរចៅ ។ – គឺ បុច្ឆសិ ព្រះអង្គដណ្តឹងអ្វី ? ។ – អើបើដូច្នោះ ចៅចាំស្តាប់

យើង ៗ នឹងនិទានរឿងមួយ ចូរតាំងចិត្តស្តាប់ គិតឲ្យយល់ គ្រាប់តែប៉ុណ្ណោះ ក៏នាំនិទានពីព្រេងនាយមកត្រាស់ថា:

ក្នុងបុរាណ មាននិទានពីបុរាណមកថា មានមាណព ៤ នាក់ទៅរៀនសិល្បសាស្ត្រនៅនគរតក្កសិលា, មាណពម្នាក់រៀនជប់ជីវិតមនុស្សឲ្យរស់, មាណពម្នាក់រៀនខាងហោរទាយ, មាណពម្នាក់រៀនខាងសិល្បធ្នូ, មាណពម្នាក់ទៀតរៀនខាងវិជ្ជាមុជទឹក; មាណពទាំង ៤ នាក់លុះរៀនចប់សព្វគ្រប់ហើយ ក៏លាអាចារ្យទិសាបាមោក្ខ វិលមកស្រុក ដើរតាមមាគ៌ាកួន វេលាល្ងាច ក៏នាំគ្នាចូលទៅអាស្រ័យនៅក្រោមដើមឈើធំ ១ ទៀបឆ្នេរមហានទី, ឯ[illegible] មាន[illegible] មាណពម្នាក់ដែលចេះហោរា ប្រាប់ទៅមាណពទាំង ៣ ថា អម្ភោ ម្នាលគ្នាយើងអើយ ; បន្តិចទៀតនឹងមានសត្វឥន្ទ្រីពាំព្រះរាជធីតាម្នាក់មកត្រង់យើងឥឡូវហើយ, ឯមាណពចេះសិល្បធ្នូស្រដីថា បើដូច្នោះ, ខ្ញុំនឹងបាញ់សត្វឥន្ទ្រីនោះ ៗ មាណពទាំងនោះនិយាយគ្នា មិនទាន់ចប់ផង, ក្សណៈនោះ សត្វឥន្ទ្រីពាំយកព្រះរាជធីតាហើរសៀមកតាមអាកាសមែន ៗ មាណពចេះសិល្បធ្នូបាញ់សំដៅទៅសត្វឥន្ទ្រី ក៏ធ្លាក់ព្រះរាជធីតាមកក្នុងមហានទី រលត់ព្រះជន្មលិចបាត់ទៅ ៗ មាណពចេះមន្តមុជទឹក ក៏លោតចុះមុជរាវរក លុះឃើញហើយថ្មមចបីត្រកងយកឡើងមក ៗ មាណពចេះមន្តជប់ ក៏កាយមន្តជប់ជីវិតព្រះរាជធីតាឲ្យរស់ក្រោកឡើងគង់អង្គុយនៅហោង ៗ មាណពទាំង ៤ នាក់

គន់មើលទៅព្រះរាជធីតានោះ មានរូបស្រស់បំព្រង ដូចកល់ទេវតា ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់គ្រប់គ្នា, វេជ្ជកុមារោ តំ អនាសំ ឧច្ចិ ទើបព្រះចៅវេជ្ជកុមារ សួរទៅចិញ្ចៀនព្រះទំរង់ថា កោ លក្ខិតុំ វដ្ដតិ តើមាណពណា គួរបានព្រះរាជធីតានោះជាប្រពន្ធ? ។ ចិញ្ចៀនឆ្លើយថា បពិត្រព្រះរាជកុមារ ! នាង:នោះគួរបានជាភរិយានៃមាណពអ្នកប្រោះឲ្យរស់នោះហោង ។ ព្រះរាជកុមារត្រាស់ថា ម្នាលចិញ្ចៀន ! អ្នកស្រដីនេះពុំគួរឡើយៗ ថ្វីនពិព្រះនាងកល្យាណី ទ្រង់ព្រះសណ្ដាប់ចិញ្ចៀនព្រះទំរង់ដូច្នោះ ទ្រង់ពាស់ព្រះទ័យ ហើយចាប់ចិញ្ចៀនស្ដីឲ្យថា ម្នាលចិញ្ចៀន ! ប្រស្ពន់ស្រដីដូច្នេះ ពុំត្រឹមត្រូវឡើយ យោ អាកាស-ឆត្វាតុំ មាណពដែលចេះមើលនក្សត្រឫក្សព្ធ័អាកាស គួរចាត់ទុកជាបិតា, មាណពចេះសិល្បធ្នូ គួរចាត់ទុកជាបង, មាណពដែលប្រោះឲ្យរស់ជីវិត គួរចាត់ទុកជាម្ដាយ, ឯមាណពចេះសិល្បមុជទឹក គួរបានជាស្វាមីនៃនាងនោះ ព្រោះបានឱបត្រសោបថ្នមប៉ះពាល់សព្វសព៌ាង្គកាយនៃនាង ។ ព្រះរាជធីតាទ្រង់មានព្រះរាជសវនីយ៍តែប៉ុណ្ណោះ ក៏ទ្រង់ស្ងៀមស្ងាត់ទៅវិញ ។ ឯមហាជនទាំងឡាយព្វស័ព្ទសម្មេននៃព្រះនាងកល្យាណីចរចា ក៏នាំគ្នាប្រគំនូវដូរ្យតន្ត្រីពួកនរ៉ពន់ពេញទាំងព្រះបរមរាជវាំង ។ ទើបព្រះរាជកុមារ យកចិត្តចេញពីចិញ្ចៀនព្រះទំរង់ទៅដាក់នឹងផ្តិលមាស

ហើយត្រាស់នឹងផ្តិលថា ម្នាលផ្តិលមាស ! យើងត្រូវចរចារនឹងចៅតទៅទៀត ។ ផ្តិលមាសទូលថា បពិត្រព្រះរាជបុត្រ ! ព្រះអង្គចង់សួរអ្វី សូមសួរចុះ ។ ព្រះរាជកុមារក៏នាំមក នូវនិទានដូចតទៅនេះ :

ក្នុងកាលដែលកន្លងទៅហើយ មានមាណព ៤ នាក់ចេញទៅរៀនសិល្បសាស្ត្រនៅនគរតក្កសិលា លុះរៀនត្រឡប់មកស្រុកវិញដល់ពាក់កណ្តាលផ្លូវចួនជាដល់វេលាល្ងាច នាំគ្នាដេកនៅក្នុងព្រៃ ។ មានខ្លាមួយយ៉ាងធំដើរចូលមកប្រុងខាំមាណពទាំងនោះស៊ី ។ មាណពទាំង ៤ ឃើញខ្លាដូច្នោះ ពុំហ៊ានដេកឡើយ នាំគ្នាដុតភ្លើងឡើងអង្គុយ ។ ឯគ្រា [illegible] មាណពម្នាក់ដែលចេះសិល្បៈខាងឆ្លាក់ ក៏យកឈើមកឆ្លាក់ជារូបស្រីមួយយ៉ាងល្អឯក, មាណពដែលរៀនសិល្បៈខាងជាស់ ក៏ជាស់បង្កើតអស់អាការៈតូច-ធំគឺ សក់ រោម ក្រចក ព្រមទាំងអវយវៈដទៃទៀតនៃស្រីនោះ, មាណពចេះសិល្បៈប្រោះជីវិតមនុស្សឲ្យរស់ ក៏ជប់ធ្វើជីវិតស្រីនោះឲ្យរស់ឡើង, ឯមាណពម្នាក់ទៀតក៏យកមន្តបង្កើតជាសំលៀកបំពាក់ សំពុងជាគ្រឿងប្រើប្រាស់នៃស្ត្រីនោះ ។ ទើបព្រះវេទ្ធកុមារសួរផ្តិលមាសថា ម្នាលផ្តិលមាស ! ឥឡូវ បុរសទាំង ៤ នាក់ឃើញរូបនាងនោះល្អដូចទេវតា ចង់បានជាភរិយារបស់ខ្លួនរៀងៗ តើគួរបានទៅបុរសណា ? ។ ផ្តិលមាសទូលថា បពិត្រព្រះរាជកុមារ ! នាងនោះគួរបានទៅបុរសដែលឲ្យជីវិតនោះហោង ។ ព្រះរាជធីតា ទ្រង់ឮ

ផ្តិលមាសទូលដូច្នោះ ក៏ពាស់ក្នុងព្រះរាជហឫទ័យ ស្តេចត្រាស់ផ្តិលមាសថា ម្នាលប្រស្តន! ហេតុអ្វីក៏ប្រស្តងទូលព្រះរាជកុមារដោយសេចក្តីវង្វេងវង្វាន់ដូច្នេះ! គួរបុរសដែលចាំងឈើធ្វើរូបនោះជាបិតា, បុរសអ្នកធ្វើត្រចៀក ច្រមុះ មុខ មាត់ គួរបានជាបង, បុរសអ្នកព្រោះឲ្យរស់ គួរបានជាម្តាយ, បុរសអ្នកឲ្យគ្រឿងស្លៀកពាក់និងគ្រឿងតែងប្រាណគួរបានជាស្វាមីនាងនោះហោង; ព្រះនាងទ្រង់មានព្រះរាជសវនីយ៍តែប៉ុណ្ណោះក៏គង់ស្ងៀមទៅវិញ ។ ឯមហាជននាំគ្នាប្រគំដូរ្យតន្ត្រីឡើង ព្រួសូរទ្រហឹងអឹងកង ។ ឯព្រះរាជកុមារក៏ដកចិត្តចេញពីផ្តិលមាស យកទៅដាក់ក្នុងខ្នើយហើយហៅថា ពិម្ពាយាន ម្នាលខ្នើយ! យើងត្រូវដណ្តឹងប្រស្នាទីងទៅ ចូរទៅឆ្លើយហោង ។ ខ្នើយឆ្លើយថា បើព្រះអង្គចង់ដណ្តឹងប្រស្នាអ្វី សូមទ្រង់ដណ្តឹងចុះ ។ ទើបព្រះរាជកុមារនាំយកនូវនិទានថា:

ក្នុងកាលដែលកន្លងទៅហើយ មានបុរសម្នាក់បានធ្វើកម្មដ៏ធ្ងន់ ៗ ព្រះមហាក្សត្រ ទ្រង់បញ្ជាឲ្យគេដោតក្តាងបុរសនោះទាំងរស់ នៅក្បែរទ្វារព្រះនគរ ។ បុរសនោះរងនូវសេចក្តីទុក្ខដ៏ខ្លាំងក្លា ។ ក្បែរនោះមានស្ត្រី៤នាក់ ដើរមកឃើញបុរសនោះមានរូបល្អ ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់គ្រប់គ្នា ។ ស្រីម្នាក់យកមាស ១.០០០ ដំឡឹង ទៅថ្វាយព្រះមហាក្សត្រ សូមដោះជីវិតនៃបុរសនោះ. ស្រីម្នាក់ឲ្យបាយ ទឹក នំ ចំណី,

ស្រីម្នាក់ឲ្យឱសថគឺថ្នាំ លាប ផឹក, ស្រីម្នាក់ទៀត បំរើទឹកក្តៅ ទឹកត្រជាក់ ស្លំ លាងខ្ទុះ លាងដំបៅ រក្សាថែទាំពេលយប់ថ្ងៃ ព្រមទាំងឲ្យកន្ទេលខ្នើយ ទីដំណេក លាងសំលៀកបំពាក់របស់បុរសនោះ ម្នាលខ្នើយ! ស្រីណាបានជាភរិយានៃបុរសនោះ? ។ ខ្នើយទូលថា បពិត្រព្រះរាជកុមារ! ស្ត្រីដែលយកមាសទៅដោះជីវិត ត្រូវបានជាភរិយាហោង ។ ឯព្រះនាងកល្យាណីស្តាប់ហើយ ពុំត្រូវព្រះរាជហឫទ័យឡើយ ហើយមានព្រះរាជសវនីយ៍ថា: ម្នាលខ្នើយ! ប្រស្ដែងស្រដីនោះពុំគួរទេ, ប្រស្ដែងនៅទីនេះយើងពុំចេះដឹងអ្វីសោះ ប្រស្ដែងស្តាប់យើងៗនឹងប្រាប់: រីនាងដែលដោះជីវិតបុរសនោះ គួរបានជាបិតា ព្រោះបិតាតែងទទួលទុក្ខកូន, យា ន ភោជ ជា ហារំ រីនាងដែលឲ្យអាហារបរិភោគគួរបានជាមាតា, រីនាងដែលស្ទះស្ទូនរកឱសថមកឲ្យបុរសនោះលាបផឹកគួរបានជាបង, រីនាងដែលប្រតិបត្តិដោយទឹកក្តៅទឹកត្រជាក់ បោសពូកកន្ទេលខ្នើយ គួរបានជាភរិយាបុរសនោះ ។ ព្រះនាងកល្យាណីស្រដីតែប៉ុណ្ណោះក៏ស្ងៀមទៅ ។ អស់មហាជនក៏ប្រគំភ្លេងម្តងទៀត ។ ក្សណៈនោះព្រះរាជកុមារក៏ដកចិត្តចេញពីខ្នើយ យកទៅដាក់ក្នុងព្រះភូសារបស់ព្រះនាងហើយត្រាស់ដណ្តឹងថា ម្នាលព្រះភូសា! ចូរស្តាប់នូវនិទានដូចតទៅ:

ក្នុងកាលដែលកន្លងទៅហើយ មានស្រី៤នាក់ នាំគ្នាស្ទះស្ទូនរកប្តីដើម្បីឲ្យបានគាប់ចិត្ត បានទៅជួបនឹងបុរស៤នាក់ កំពុងស្ទះស្ទូនរក

ប្រពន្ធដែរ ក៏សន្ទនាគ្នាទៅវិញទៅមក ។ បុរសម្នាក់ដណ្ដឹងសួរស្រីថា កតរស្មឹ វសសិ កន្ទេ ម្នាលប្អូន! ប្អូននៅភូមិណា? ។ សា គីវំ បរាមសិត្វា ស្រីនោះបកដៃអង្អែលក ហើយឆ្លើយថា ផ្ទះខ្ញុំនៅត្រង់នោះ ៗ ឯគោ ឯតំ បុដ្ឋិ បុរសម្នាក់ទៀត សួរស្រីម្នាក់ទៀតថា ផ្ទះនាងនៅត្រង់ណា? ។ ស្រីនោះយកដៃស្ទាបសិរសា ហើយថា ផ្ទះខ្ញុំនៅត្រង់នេះ ។ បុរសម្នាក់ទៀតសួរទៅស្រីមួយទៀតថា ផ្ទះនាងនៅត្រង់ណា? ។ ស្រីនោះយកដៃស្ទាបថ្ពាល់ ហើយថា ផ្ទះខ្ញុំនៅត្រង់នោះ ។ បុរសទី ៤ សួរទៅស្រីម្នាក់ទៀតថា ផ្ទះនាងនៅត្រង់ណា? ។ ស្រីនោះយកដៃស្ទាបពោះហើយថា ផ្ទះខ្ញុំនៅត្រង់នោះ ។ ស្រីទាំង៤នាក់លុះប្រាប់ដូច្នេះហើយ ក៏លាបុរសទាំង៤នាក់ទៅ ។ ឯបុរសទាំង៤ ជំទុំពិចារណាគ្នាអំពីប្រស្នារបស់ស្រីទាំង ៤ នាក់ សួរគ្នាទៅវិញទៅមក មិនអាចបុរសណាមួយដឹងបាន គក្កដ្ឋា គក្កដ្ឋា ទើបបបួលគ្នាដើរទៅតាមផ្លូវ បានជួបនឹងបុរសម្នាក់ត្រូវទោស ព្រះមហាក្សត្រឲ្យដោតគាំងរស់នៅនឹងបន្ទា ក៏សួរទៅបុរសត្រូវទោសនោះ ។ បុរសនោះឆ្លើយថា ម្នាលសំឡាញ់! ប្រស្នានេះ មិនក្រឡើយ តែសូមសំឡាញ់រកទឹកឲ្យយើងបានបន្តិចផឹកសិន យើងនឹងអធិប្បាយប្រាប់ ។ បុរសទាំង៤ទៅរកទឹកមកឲ្យបុរសនោះផឹកហើយ ក៏សួរប្រស្នានោះតាមដំណើររៀងៗខ្លួន ។ បុរសជាប់ទោសប្រាប់ទៅបុរសទី១ថា អ្នកបុរកនាងនោះនៅទិសឧត្តរ

មានផ្លែឃ្លោកជាសំគាល់នៅខាងជើងផ្ទះ, ឯស្រីដែលយកដៃស្ទាបក្បាល គឺផ្ទះស្រីនោះនៅទិសបូព៌ា ខាងកើតផ្ទះមានចម្ការស្រូវគោជសាលី ជាសំ-គាល់, ស្រីដែលយកដៃស្ទាបថ្ពាល់ គឺផ្ទះស្រីនោះនៅទិសបស្ចិម មានដើមចាន់នៅខាងលិចផ្ទះជាសំគាល់, ចំណែកខាងស្រីដែលយកដៃស្ទាបដោះ គឺផ្ទះស្រីនោះនៅទិសទក្សិណ មានដើមក្រូចឆ្មា នៅខាងជើងផ្ទះជាសំគាល់ ។ បុរស ៤ នាក់ ក៏ដើរទៅរកស្រីនោះ ឃើញត្រូវគងដូចពាក្យអ្នកទោលប្រាប់ ។ ស្រីទាំង ៤ សួរថា អ្នកមកនេះ ដោយរកឃើញខ្ញុំឯងឬមានអ្នកណាប្រាប់? ។ បុរស ៤ នាក់ប្រាប់ថា យើងមកនេះតាមពាក្យបុរសម្នាក់ ដែលគេដាក់ទាំងរស់នៅក្នុងព្រៃប្រាប់យើង ។ ស្រីទាំង ៤ លុះដឹងសេចក្តីហើយ ក៏លះបង់បុរសទាំងនោះ នាំគ្នាត្រាច់ទៅរកបុរសទោស លុះឃើញហើយ ក៏ដាក់ចេញពីឈើអណ្តាត នាំយកមកប្រតិបត្តិៈ ម្នាក់ឲ្យសំពត់ស្លៀកពាក់, ម្នាក់ឲ្យទឹកផ្ងូតជម្រះកាយ, ម្នាក់ឲ្យបាយចំណី, ម្នាក់ឲ្យកន្ទេលខ្នើយដេក, ម្នាលព្រះកុសា ! បណ្តាស្រីទាំង៤នាក់នោះ ស្រីណាបានជាធំលើសស្រីទាំងបី ?, ម្យ៉ាងទៀតស្រីណាបានជាប្រពន្ធទីពីរ? ណាបានជាប្រពន្ធទី ៣ ? ណាបានជាប្រពន្ធទី ៤ ។ ទើបព្រះកុសាទូលថា ស្រីដែលឲ្យទឹកផ្ងូតជម្រះកាយ ស្រីនោះបានជាធំលើសស្រីទាំងពីរ ។ ព្រះនាងកល្យាណីពុំគាប់ព្រះរាជហឫទ័យ ទ្រង់យកព្រះហស្តចាប់ព្រះកុសា ហើយមានព្រះរាជសវនីយ៍ថា ម្នាលព្រះ

កូសា ! វីពាក្យប្រស្នែងពោលនេះ ពុំគួរឡើយ យា ឥត្ថី ស្ត្រីណា ដែលឲ្យសំលៀកបំពាក់ជាគ្រឿងបិទបាំងកេរខ្មាស ធ្វើឲ្យមានសិរីសួស្ដី ឡើងវិញ សា ឥត្ថី ស្ត្រីនោះ គួរបានជាធំលើសស្រីទាំង ៣, ស្រី អ្នកឲ្យគ្រឿងទ្រូលហើយគួរបានជាប្រពន្ធទី២, ស្រីអ្នកឲ្យភោជនាហារ គួរបាន ជាប្រពន្ធទី៣, ស្រីអ្នកឲ្យទឹកផ្លឹក គួរបានជាប្រពន្ធទី ៤ ។ ឯមហាជន លុះឮព្រះនាងមានព្រះរាជសវនីយ៍ដូច្នោះ ក៏ប្រគំដេញជំនូវឲ្យជទ្រព្យ ស្ងូរស្ងើរគគ្រឹកគមហាប្រាសាទ ។ ព្រះវេច្ចកុមារ មានព្រះបន្ទូលថា “ម្នាលព្រះកូសា ! ព្រះនាងកល្យាណីជាអម្ចាស់ប្រស្នែងឯង ជាស្ត្រីឆ្កួត ឬជាស្រីកាឡកិណ្ណី ? ឥតអៀនខ្មាស មាយាធ្វើជាមិនស្រដី, ចំណែកបុរស ដទៃក៏ជាហើយចុះ ឯបុរសយ៉ាងយើង ហេតុអ្វីក៏មិនស្រដីផង ? ចិត្តញៀន ឆ្កួល ហើយ ជាតែឥតចិត្ត ឥតវិញ្ញាណ នៅកោតក្រែងយើង ស្រដី មកកាន់យើងដោយសភាពទន់ភ្លន់, ឯព្រះនាងកល្យាណីនេះ មានចិត្ត មានវិញ្ញាណ ធ្វើហាក់ដូចជាគ្មានចិត្ត គ្មានវិញ្ញាណ ពុំស្គាល់យើងថាជា បុរសដ៏ប្រសើរ ឬមួយនាងនឹងទៅរកបុរសឯណាធ្វើជាប្ដីឲ្យវិសេសជាង យើងទៅទៀត ចូរព្រះនាងនៅឲ្យសុខសប្បាយចុះ យើងសូមលាព្រះ នាងត្រឡប់ទៅវិញ ” ព្រះអង្គត្រាស់តែប៉ុណ្ណោះ ក៏ធ្វើហាក់ដូចជា ក្រោកឡើងយាងទៅ ។ ឯព្រះនាងកល្យាណីដឹងថា ព្រះរាជកុមារ អាក់អន់ព្រះរាជហឫទ័យដូច្នោះ ទ្រង់ព្រះចិន្តាថា ព្រះរាជកុមារនេះ មាន

បុណ្យ មានប្រាជ្ញាច្រើនណាស់ ទាំងព្រះរូបក៏ល្អ ឯព្រះសូរសៀង
ទៀតសោតក៏ពីរោះ, ចំពៀន ឆ្ងល់ ឡើយ ព្រះកុសា ឥតចិត្តឥតវិញ្ញាណ
ពុំហ៊ានរើសស្រូបានឡើយ ៗ រីអាត្មាអញនេះទើងទៅរកស្នាមឯណាឲ្យប្រសើរ
ជាងព្រះរាជកុមារនេះក៏គ្មានសោះឡើយ ព្រះនាងគិតដូច្នោះហើយ ក៏
ដោះឡើង ម្ជុលមាសកនុបព្រះបាទព្រះវេស្សកុមារក្រាបទូលថា បពិត្រ-ព្រ
ថ្លៃប្រសើរអើយ ! អំពើដែលខ្ញុំម្ចាស់ឧហាតសង្កាត់ធ្ងន់នេះ អស់កាលយូរ
ណាស់មកហើយ មិនដែលបានជួបពះប្រទះនឹងព្រះរាជកុមារណាមួយ
ជាទីគាប់ចិត្តខ្ញុំម្ចាស់សោះ ទើបតែបានយល់ព្រះអង្គ, ដូច្នេះ សូមអញ្ជើញ
ស្តេចគង់លើកបនៈដ៏ប្រសើរហោង ៗ កាលនោះ អស់ពួកនារីទាំង
ឡាយ នាំយកសេចក្តីនោះ ទៅក្រាបទូលសម្តេចព្រះរាជបិតាតាំងពីដើម
រហូតដល់ចុង ៗ ព្រះបាទវេស្សមារជិតរាជទ្រង់ព្រះសណ្តាប់ហើយ មាន
ព្រះរាជហឫទ័យសោមនស្ស ត្រាស់សរសើរព្រះរាជកុមារដោយប្រការ
ផ្សេង ៗ ហើយស្តេចអភិសេកព្រះវេស្សកុមារជាមួយព្រះនាងកល្យាណី
ជាអគ្គមហេសី ស្តេចប្រដាប់ទូលស្រី ១ ហ្មឺន៦ពាន់ជាយសបរិវារ រួចទ្រង់
តាំងព្រះរាជកុមារជាព្រះបាទវេស្សរាជទីពីរ ៗ ព្រះបាទវេស្សរាជទីពីរ លុះ
បានគ្រងរាជ្យហើយ ក៏ព្រះរាជទានការជាសេនាបតីដល់បុត្រអាមាត្យ ដែល
បានទៅរៀនសិល្បសាស្ត្រជាមួយគ្នា ហើយព្រះអង្គទ្រង់កាន់ទូវសីល៥
សីល៨ និង១ឧបោសថសីល ចាយរាយព្រះរាជទ្រព្យឲ្យដល់ស្មូមយាចក

ទីងអ្នកកំសត់សត្វថ្ងៃពុំដែលដាច់ឡើយ, មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់រក្សា នូវទសពិធរាជធម៌ សម្រាប់ជាទីពឹងពុំនាក់ នៃអាណាប្រជានុរាស្ត្រទាំងឡាយ ៗ ឯអ្នកនគរទាំងមូល តែងមានសេចក្តីស្វាមីភក្តិ នាំយកបណ្ណាការមកថ្វាយព្រះបាទវេច្ចកដទិពារ ទីងព្រះនាងកល្យាណីជានិច្ច ៗ ព្រះមហាក្សត្របានរួមរាសនាជាអមុងយូរទៅ, ថ្ងៃមួយ ស្តេចមានព្រះរាជហឫទ័យនឹកក្នុងបងទៅប្រពាតព្រៃ ទើបទ្រង់ឲ្យរៀបប្រដាប់ចតុរង្គសេនា មានសេនាបតីជាប្រធាន ចេញពីព្រះនគរទៅដល់លង្វែកព្រៃមួយ ទ្រង់មតព្រះនេត្រទៅឃើញម្រឹគមួយស្លាប់ថ្មីៗ នៅនាព្រៃនោះ ទើបសូត្រសែកមន្តបន្ទយចិត្រចេញពីព្រះអង្គ ហើយចូលក្នុងរូបនៃម្រឹគនោះ, រីព្រះកាយព្រះមហាក្សត្រ ក៏ដួលដេកនៅលើព្រះធរណី ៗ ឯម្រឹគដែលស្លាប់ ក្រោកឡើងរត់ផ្លោះស្ទុះបោលចូលទៅក្នុងដងព្រៃ ៗ ថ្ងៃពីសេនាបតី កើតចិត្តបាបមួយរំពេច, លុះដឹងថា ព្រះកាយព្រះមហាក្សត្រដួលដេកដូច្នោះ ក៏សូត្រសែកមន្តបន្ទយចិត្រចេញពីរូបខ្លួន មកចូលក្នុងព្រះរូបព្រះមហាក្សត្រត្រាស់បង្គាប់ឲ្យចតុរង្គសេនាវិលមកព្រះនគរវិញយ៉ាងប្រញាប់, ឯរូបរបស់ខ្លួនក៏បោលទៅក្នុងព្រៃពុំស្តាយឡើយ, ចូលទៅក្នុងព្រះនគរ ៗ សព្វជនា វីមប៉ាជនទាំងអស់ ពុំដឹងថាជាសេនាបតីឡើយ សំគាល់ថាជាព្រះមហាក្សត្រពិតមែន ៗ ឯសេនាបតី ចិត្តអបលក្ខណ៍នេះ លុះដល់

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងសព្វសិទ្ធិ

(ភមក)

របស់ហ្វឹនកវីអក្សរគន់ លោកប៊ូ-ប៊ី ចំឡងពីសាស្ត្រាស្លឹករឹត

ចូរឆ្លើយប្រាប់បងកុំចង់ចិង ឲ្យបងបានដឹងកិច្ចកលទៀត ប្អូនមាសកន្ទេង នេះចះផ្អៀត ចូរបែរមកបៀតជិតបងពី ៗ អូនអើយអូនសមឈ្មោះកេសរ សាច់ល្អិតជិតល្អដូចល្អងផ្កា មើលល្អះគ្មានល្អក់តក់ត្រង់ណា ស្រៀវល្អិល ស្រិលថ្លាស្រស់ឥតល្អៀង ៗ បានឃើញតែមុខទុក្ខបងបាត់ កុំតែវគិត កាត់គេចកែកៀង បែរបៀតបងបីបមបាយបៀង លូកលាត់លោម លៀងលេងលងល ៗ ព្រះវងប្រលោមថ្នមយកចិត្ត ព្រះនាងក៏ស្និត ឥតសាទរ អៀនខុនព្រះភ័ក្ត្រធ្វើហាក់គ ទ្រង់លើកបីតហើយពោលថា ៗ ខុគ្គកទិដ្ឋាជីវិតបង ម្ដេចពុំឆ្លើយធ្វើសងបញ្ហា ឲ្យរៀមអង្វរជាច្រើនសា ប្ដូរមិនមេត្តាទៃកែវថ្លៃ ៗ ថាហើយព្រះអង្គទ្រង់សញ្ជប់ ព្រះភ័ក្ត្រខុន ជ្រប់ជ្រួលជួនថៃ ធ្វើកលហាក់ខ្វល់ក្រោធក្រំក្រៃ ទើបត្រាស់ថាហៃ ចៅជួនចន្ទ ៗ ឃើញគ្មាននិស្ស័យនឹងគ្នាហើយ កែវអើយនៅថ្វីឲ្យ សាន់ពន់ បងសុំលាចៅទៅបួសកាន់ ព្រឹទ្ធព្រតព្រហ្មចរ្យសាងសីលា ៗ នៅថ្វីអប្រិយប្រុសឥតភ័ព្វ គេកាត់មិនពបចាប់ចេតនា ព្រឹកនេះសូមលា

ថែរគន្ធា ចូរនៅរក្សាខ្លួនឲ្យគង់ ៗ គិតថ្លៃថ្នើយដូចរូបបង អូនកាត់មិនបង់ចិត្តពិសវង់ បងសូមលាអូនស្ងួនឆោមយង់ ទៅបួសលុះលង់អស់ជន្មា ៗ ប្រាថ្នាមគ្គផលដល់ផុតទុក្ខ ប្រែមុខចំរើនធម៌ភាវនា លះលាភបាក់លោកកាមឆន្ទា សោះសូន្យពុំនាំអំពល់ចិត្ត ៗ ត្រាស់ហើយព្រះអង្គគង់ទ្រមឹង ធ្វើហាក់ជាខឹងពុំស្នេហ៍ស្និទ្ធ ចង់ដឹងយោបល់គលចរិត ព្រះនាងទឹងគិតបងយ៉ាងណា ៗ កាលនោះខ្លួននាងនាថវរលក្ខណ៍ បានស្តាប់សព្ទជាក់ហាក់អស្ចារ្យ ស្រយុតស្លុតស្លន់អន់ខ្ញុក គិតដល់កស្តភាណ៍ភ័តក្រៃ ៗ ស្មានជាព្រះអង្គនឹកខ្នាសពិត ចេញទ្រង់បព្វជិតការកាត់កាល័យ ព្រោះខ្លួនអញមិញមិនប្រស្រ័យ រួមរួមពិស្ម័យក្តីស្នាគម ៗ ប្រសិនទ្រង់ចេញទៅកាលណា ដ្រាបដល់បិតាកើតទុក្ខធំ គិតភ្ញាប់ទើបនាងកើតមនោមៀ លើកករបង្គំគ្រែងទូលថា ៗ ព្រះអើយព្រះអង្គទ្រង់វង់ភ័ក្ត្រ ស្តេចស្នាគ្រងស្ងួនលះប្រាថ្នា ចេញទ្រង់បព្វជិតកាត់សង្សារ សាងសីលាចារជាថ្មីៗ គន់លោកនេះគ្មានដូចព្រះអង្គ អាចកាត់លះបង់ពីប្រិយ ទ្រង់គិតយ៉ាងនេះគួរគប្បី ត្រូវនឹងលោកិយលោកុត្តរ ៗ ថាបើទ្រង់យាងទៅកាលណា អូនសូមយាត្រាត្រាច់សព្វារ ជូនទៅជាគ្នាការក្រែងក្រកំដរសោះស្ងាត់គន់ហិមវា ៗ ថ្វាយខ្លួនជាញោមសូមឧបត្ថម្ភ ព្យាបាលថែទាំចាំរក្សា បំរុងបង្អាន់បាវស្មា លុះត្រាតែអស់ជន្មជីវិត ៗ បើទ្រង់បួសហើយចូរផ្ចិតផ្ចង់ កាន់ចិត្តឲ្យត្រង់តាមព្រឹត្តព្រឹទ្ធ កុំប្រាជ្ញតែមាត់ចិត្ត

មិនគិត ឲ្យខុសចារិតគ្រោធម្នា ៗ ព្រះអង្គទ្រង់ស្តាប់ស័ព្ទសវនីយ៍ ព្រះនាងស្រដីពាក្យនាំពា សម្ដេចចាប់ចុះថ្កុះទ័យា ព្រះអង្គាកើតបេតី ៗ ទើបមានតម្រាស់ត្រាស់ទៅថា ហៃកែវកល្យាណ៍ជាឆ្នើមស្រី អ្នកបង់តាមបងទៅធ្វើអ្វី ក្រែងមិនគប្បីនឹងសិក្ខា ៗ វិស័យនាក់ដែលចេញទៅបួស ព្រោះចង់ឲ្យហួសបាតសង្សារ ឯស្រីជាទោសនឹងគាត្នា ពុំដែលនរណាបួសនឹងស្រី ៗ ប្រសិនបើអ្នកតាមបងទៅ នឹងនៅចាំស្តាប់ពាក្យបងស្តី យ៉ាងដូចរូបអ្នកសូនពិសី មុខជាខូចសក្តិវិន័យច្បាប់ ៗ ទ្រាំម្ដេចឲ្យបាននឹងបរិសុទ្ធ ស្រីនៅក្នុងកុដិស្រស់ស្រួលស្រាប់ ពុំជាទេរីថ្ងៃបំណាច់ ត្រាស់ក្ដាងកៀកចាប់ព្រះកាយា ៗ ព្រះនាងទឹកអៀនសែនខ្មាសលន់ ទំផទំសង្កត់អត់ហើយថា ព្រះអើយព្រះអង្គកុំខាំងខាលែងខ្ញុំមិនពិណ៌ក្សត្រថ្លៃ ៗ ព្រះរីងក្រសោបឱបកៀកកិត នាសិតផិតភាត់គេពិស្នេហ៍ អង្អែលសុដនដួងវិល័យ ក្សត្រថ្ងៃត្រីព្រូចកួចស្នេ-ហា ៗ ហើយត្រាស់ប្រលោមនោមព្រាលិង ថាអ្នកកុំទឹងណាកែវណា អញ្ចើញមកផ្ទុំទឹងជេដ្ឋា លើទីសយនាសុខសម្រាន្ត ៗ ព្រះអើយព្រះអង្គកុំបន្ទិ ទ្រង់អាសូរខ្ញុំសិនក្សត្រក្សាន្ត នាងក្តិបនាងខ្ទាំក្រចៅប្រាណ ប្រែប្រាណប្រះថ្ពុំសម្ងំនៅ ៗ ទ្រង់រិទ្ធិពិមិត្យពិសាង គន់ទ្រង់អនង្គអនុជពៅ យល់ល្អត្របះដ្រុះសន្ដៅ ហោមហៅត្រេកត្រាសសរសើរថា ៗ ទៅល្អកេសដូចស្វាបគង្គ ល្អក្រែហាក់វង់ចន្ទ

ក៏ថា ចៅល្អនេត្រដូចទិលគេនា ចៅល្អនាសាឧត្តមថ្លៃ ៗ ចៅ
ល្អព្រៀងយ៉ាំងមាត់ប្រាំងមាស ល្អឱស្ឋឱភាសស្រស់ប៉ប្រៃ ល្អកាណិ
ដូចកលផាន់ចរណៃ ល្អហត្ថហាក់ដៃនៃព្វក ៗ ចៅល្អកដូច
សុវណ្ណហង្ស ល្អអង្សាសមនឹងកាយោ ចៅល្អរាងរៀវដូចកិន្នរ
ឆវីវណ្ណាលឿងអន្ទង ៗ ទ្រង់ទតសព្វគ្រប់ទប់ពុំបាន ក្សត្រក្សាន្ត
បើកព្រះសុភ័គគ្គង ព្រះនាងដឹងកលដល់ទំនង ស្រស់ឈ្នងរះទាត់
ព្រះហត្ថា ៗ ទ្រង់រែកជ្ជញដឹកប្រវាឱប ក្រសោមថៃថើបព្រះកក្រា
ស្រៀវស្រើបសំរើបក្តីស្នេហា បង្កើតអស្ចារ្យកាលគ្រានោះ ៗ កុដង្គទ្រង់
រិទ្ធិនិម្មិតខ្លួន ក្រអួនក្រអើតស្មើតស្មាញស្មុះ យង់យល់បទុមធំសស្គុះ
ទំព្រុះចុះស្រង់ក្នុងវារី ៗ កព្រ្ញោកឡោកហោចសាចទឹកលេង ដោយ
ល្បែងសប្បាយកាយិន្ទ្រិយ បុស្បង្ករើយរំសាយភ្ញ នាគីព្រួសពិស
ព្រួញអាត្មា ៗ សម្រេចសម្រាន្តក្សាន្តភិរម្យ ទើបនាងបង្គំក្រាបទូលថា
ទោះអូនខុសធ្គង់ធ្ងន់ម្តេចម្តា មេត្តាសន្តោសប្រោសប្រណី ៗ អូនអើយមាស
អូនមានទេវល័ក្ខណ៍ ស្ងួនសក្តិសមជាឆ្នើមបូរី វៃកុំភ័យភិតក្នុងចិត្តថ្វី ធម្មតា
ជាតិស្រីក្នុងលោកា ៗ ពុំដែលនះណាព្រមតែម្តង គង់គិតធ្វើយធ្ងងសង
ដោះសា ត្រាស់ហើយល្ងួងលោមថ្នមធីតា សោយក្សាលទល់លក់សុខ
សម្រាន្ត ៗ លង់លុះព្រឹកព្រាងស្វាងក្តីជ្រះ អរុណរៀងរៃព្រះសុរដ្ឋាន
ទាំងពីរតើនចាកទៃនសុរិកាន្ត ក្សត្រក្សាន្តនាំនាងទៅពៃថ្ងៃ ៗ ចូលស្រង់

ភរិនសុគន្ធរស អប់អស់ក្លិនក្លីតីជោរក្រៃ ស្រង់ស្រេចសម្តេចព្រះគូវន័យ វិលវៃឡើងគង់លើអាសនា ៗ តីពាន្យទ្រង់យសយល់ល្អក្រៃ ហាក់អង្គសហស្សន័យន៍នៃបសុជាតា ពួកស្រីព្រះស្នំក្រមបរិវារ គង់គាល់គ្រៀបគ្រាក្នុងប្រាង្គស្រី ៗ វេលាព្រាហាមព្រះសុរិយង្គ បមពាន្យនាំអង្គអគ្គ-មហេសី ឡើងគាល់បិតុរង្គទ្រង់ប្តារមី ដោយក្តីគោរពស័ព្ទប្រញ្ញា ៗ ព្រះបាទព្រហ្មទត្តខត្តិយោត ឈ្មៀងនេត្រយល់បុត្រតីអេង្គា កបទ្រង់ផង់ក័ក្រ្តហាក់បន្ទ្រា ម្ចាស់មាតៅពៅហៅមហេសី ៗ នាងអើយកូនយើងទាំងពីរពាន្យ ល្អអង្គទ្រង់ឯកប្លែកលោកិយ ទេពញ្ញាព្រះស្នំមកឱ្យ ដឹកដៃក្សត្រិរត្នធីតា ៗ ព្រហ្មទត្តចាប់ហត្ថបក្រពាន្យ នាំឡើងទៅគង់លើអាសនា ទើបមានគម្រាស់ត្រាស់ប្រាប់ថា កូនអើយបិតាកំចាស់ហើយ ៗ សព្វថ្ងៃព្រាធិបេតប៉ន្ទា ជូនឈឺជូនជាមិនត្រាស្បើយ សង្ឃឹមនរណាមិនបានឡើយ កូនអើយកុំឆ្ងល់ប្រហែសការ ៗ ទុកបកដនេះជាសម្រេចផុតកលើកជ្តាច់ទុកឲ្យបា ចូរត្រិះរិះរៀបប្រៀបរាជការ ត្រួតត្រាក្សាប្រជា-ជន ៗ ទួទាំងអាណាចក្រមណ្ឌល ឲ្យក្សាន្តសុខលពលំតំបន់ អាករសួយសារណាមើជូន បន្ទុំបន្ទាបឲ្យពបស្មើ ៗ មន្ត្រីតូចធំខំរាជការ ចូរមើលត្រួតត្រាការសារពើ ថែទាំឲ្យសព្វគ្រប់អន្ទើ គួរប្រើសឹមប្រើឲ្យគួរការ ៗ នឹងកាត់សេចក្តីប្រជាកស្ត្រ ចូរឈ្លាសឆ្លៀតឆ្នុះដោយប្រាជ្ញា ឲ្យត្រឹមត្រង់ត្រូវផ្លូវមាត្រា តាមព្រះធម៌ថាជាបញ្ញត្តិ ៗ ធម្មតាអ្នកធ្វើ

ជាចៅក្រុំ ត្រូវខំផ្ចិតផ្ចង់បំរុងសត្វ តាំងខ្លួនទុកជាអព្យាក័ត ប្រយ័ត្នកុំ
ឲ្យធ្លោយសេចក្តី ។ តែលុះអំណាចធម៌ទាំង ៤ នឹងថ្លស់ធ្លាក់ខ្លួនទៅ
អវិចី ពោះទាំងនិទ្ទានាលោកិយ ផែនដីវិបរិតឥតមានសុខ ។ ធម៌ជាប្រ-
ទេសចំរើនណា បើមានក្សត្រាបេះដោះទុក្ខ ឲ្យរាស្ត្រគេរួមក្សាន្តមិន
វើសមុខ ស្រុកនោះទើបបានសុខា ។ បើក្សត្រនឹងអស់មន្ត្រីធំ ជំនុំ
មិនតាមធម៌សម្មា យល់ដោយអាមិសលាភសក្ការ អាណារាស្ត្រនឹងក្តៅ
ក្រហាយ ។ មួយទៀតតាមវែត្រតាមនិគម គួបផ្សំកងក្រៅនៅជិត
ឆ្ងាយ ប៉ូវកូនត្រិះរិះគិតខ្វល់ខ្វាយ ចាត់ចាយគយល្បាតឆ្មាតរក្សា ។
សម្តេចសុនិសាសព្វសិទ្ធ ក្រាបក្រញ្ជួញជិតស្តាប់ឧង្ការ លុះចប់តម្រាស់
ព្រះបរិហារ ក្សត្រាទូលតបសបនសេចក្តី ។ បពិត្រសម្តេចព្រះបិតុរង្គ
សូមទ្រង់កុំព្រួយព្រះហឫទ័យ ខ្លួនខ្ញុំជាខ្ញុំព្រះចក្រី កិច្ចការផែនដីសុម
ធានា ។ អញ្ជើញព្រះអង្គគង់សំរាន្ត ឲ្យក្សាន្តសប្បាយព្រះទ័យា ទូល
ក្សាន្តប្រណម្យបង្គំលា នាំពជជីតាអគ្គមហេសី ។ វិលវិលកាត់ប្រាង្គ
ប្រាសាទសម ស្រីង្គារព្រះស្នំពួកសាវស្រី គាល់ហៅបំរើជាប្រក្រតី
ឥតបីមានទុក្ខជាសុខា ។ ទ្រង់តាំងព្រះទ័យដោយទសពិធ រិះគិតប្រុង
ប្រៀបរៀបពងការ គ្រប់ក្រុមតំណែងតែងទសព្វហ៍ យានចេញត្រួត
ត្រាតែកល់ថ្ងៃ ។ អាណាប្រជារាស្ត្រទាំងឡាយ សឹងសុខសប្បាយ
ពាទពេកក្រៃ រន្ទឺព្ទល្បីឮរមីថ្ងៃ ប្រទេសដទៃគោរពបេក្ខា ។ ពុំអាចគ

ភាន់ប្រណាំងរឹទ្ធិ នឹងព្រះបពិត្រមហាស្សេក ។ ស្តេចទាំងរយមួយនាំសួយ
សារ មកថ្វាយព្រះមហាក្សត្រថ្កើងថ្កាន ។ ឯពជកីលៀងដែលជាមិត្រ
ព្រះអគ្គីរឹតែទ្រង់កប់អាន ប្រទានឲ្យមានលំនៅស្ថាន ប្រោសប្រាណ
ទុកដូចព្រះជេដ្ឋា ។

សម័យថ្ងៃមួយព្រះទ្រង់រឹទ្ធិ ក្អកព្រះទ័យគិតចង់យាត្រា ចេញទៅ
ប្រពាតព្រៃហិមវ៉ា ទតសត្វបក្សាបក្សីផង ។ ទើបថ្មូរពោមលាទេពីថ្លៃ
ជាថៃហាមាសស្ងួនទីមខ្លួនល្អ ចូរនៅឲ្យសុខកុំទុក្ខហ្មង ព្រឹកឡើងខ្ញូនបង
សូមលាស្រី ។ ទៅលេងព្រឹក្សាទីងកីលៀង រសៀលជ្រៀលជ្រៀង
ព្រះសុរិយ បងនឹងត្រឡប់វិលធាប់ខ្ញុំ កុំអួនប្រិមប្រិយអាល័យគិត ។
កាលនោះក្សត្រីស្រីរូបល្អ សុវណ្ណកេសរបវរមិត្រ ស្តាប់ផាក់ផ្អួលក្តួល
កន្ធិចិត្ត ទូលថាបពិត្រព្រះភស្តា ។ បើសព្វព្រះទ័យទៅហិមពាន្ត
ពួកពលពាហានមានត្រៀបត្រា ល្មមរៀបជាក្បួនឲ្យផ្លួនការ តាមយស
ស័ក្តាព្រះមហាក្សត្រ ។ លើគួរទៅជាពួកបែកឆ្វេងស្តាំ ប្រចាំរក្សាការ
ប្រយ័ត្ន ទៅម្តេចតិចគ្នាយល់ជាស្ងាត់ ក្រែងកើតវិបត្តិសត្វហិង្សា ។
មួយអួនសូមតាមទៅលុងផង ត្បិតចិត្តប៉ុនប៉ងកេបេះផ្កា ពោធិ៍ស្តាប់
ហើយឆ្លើយតបថា ក្រោយសឹមយាត្រាណាមាសថ្លៃ ។ ម្តងនេះបង
ទៅជាយ៉ាងស្ងាត់ ចាំចាត់រេហ៍ពលយល់យូរក្រៃ កុំអួនព្រួយចិត្តគិត
អាល័យ កុំរែចង់តាមបង់យាត្រា ។ ត្រាស់ស្រេចសម្តេចព្រះកូមី

នាំកជនារីកែវកេខិដ្ឋា ចូលផ្ទុំលើគ្រែសុវណ្ណា លង់លុះសុរិយារៀងរឿង ។ ទ្រង់តើនចាកទីវៃនសយនា ចូលស្រង់គង្គាដូចប្រក្រតី ស្រង់ស្រេច ស្តេចទ្រង់ព្រះពស្ត្រថ្មី បក្រើឡើងគង់លើអាសនា ។ ពិសេសរៀបតាំង គ្រឿងព្រះស្ងោយ ថ្វាយព្រះអង្គសោយក្រយាហារ សោយស្រេចទ្រង់ គ្រឿងអលង្ការ សៀតព្រះខ័នថ្វាំពេចខ្ញី ។ ត្រាស់ហៅគិលៀងជា ជេដ្ឋា យាត្រាចុះចាកប្រាសាទស្រី សីហនាទគគាតដូចកជសីហ៍ ឥតបី មានក្តុកខឹកកយា ។ ស្តេងស្តេចត្រាច់ត្រង់តម្រង់ទៅ សំដៅផល់ដែនពនា ល់ ទ្រង់ទតព្រៃព្រឹក្សទីងម្រឹគា ពណ៌នាប្រើនលន់ពន់ប្រមាណ ។ មាន តាំងបក្សីបក្សាសត្វ ហិចហើរប្រវាត់ក្នុងស្ថាន ព្រះអង្គទ្រង់ទតសព្វ ដែនដាន ក្សត្រក្សត្រគ្រាន្តត្រេកត្រាស់សរសើរថា ។

ខ ដើមតាពេលសត្វពពូល ទំមូលលើមែកបែកសាខា ពពូលពពាំ នាំបុប្ផា ហើរឆ្មារទៅទំពពូលផង ។ តាពេចពង់នៅតាពាលខែ ហើយ ហិចហើរហែគ្នាត្រសង ពាំផ្កាពពាយពាយរុះល្អង ពពូលអឺងកង់បុំកង ។ ដូចកាលបងបានប្រាណមូលមិត្រ នៃបទិត្យពពៅនៅប្រាង្គស្រី ស្រី ស្រស់ស្រួលស្រេចដាច់លោកិយ បានបងមកបីហើយបែកបែរ ។ មើលដើមពេគពក់រង្គពិងក្នុ មានវៃចុះទំយំពៀរ រៀមរកស្រមៃដូចហាក់ ស្នេហ៍ សាកាយប្រាយប្រែបែរពោបង ។ ដើមព្រីងសត្វព្រាបបន្ទាប ទំ ចាប់ជាទ្រទំយំផ្ទើយធ្ងង ដូចកល់បងព្រាត់បាត់ខ្លួនល្អង ព្រោះត្បិត

បំណានបំផុតមើលព្រៃ ។ មានដើមបេកទេសជាទ្រទំ ចាមបេកទុំទំហើយ
ហើរហើរ ដូចបងចាកខេទទីវាំងជ័យ ពោលទាំងមាសមៃថ្លៃថ្កើងថ្កាន ។
គ្រលេងគ្រលោងហើរបោកខ្នាញ់ ទំដើមក្រឡាញ់ក្នុងស្នាសាន ខ្លះ
ហើរក្រឡាប់ឈប់សំពន្ធ ដូចប្រាណបងស្ទះក្រឡេះរាំង ។ មាន
ព្រៃស៊ីវាងមាក់ប្រាងព្រាត ខ្លះក្តតអតខ្វាតក្រោមដើមខ្វឹន ដូចបងខ្វាស់
ចិត្តមិត្តព្រលឹង ម៉្លោះហើយសមទឹងអូនទឹងខ្ញុំ ។ ខ្ទួងស្រាកស្រប់
ធ្វើសំបុកពង លើទងលផ្ទែកមែកខ្ទងពារ ខ្លះក្ងារស្រៀវស្រែកសំរែកញ៉ែរ
ខ្លះទំលើវល្លិ៍ខ្លួតពន្ទៃយ ។ ដូចខ្លួនបងបានប្រាណផ្តេកផ្តិត ទីងអូនខ្ញុំ
ចិត្តឥតមោះមៃ គ្រោះនេះឃ្លាឃ្លាតវាកវៃ ព្រាត់ឆ្ងាយដោយព្រៃព្រះហិម-
វាន្ត ។ ដើមគ្រាំងវល្លិ៍គ្រៀលគ្លៀលព័ទ្ធរុំ សត្វត្រំពាំត្រីទគ្រៀបគ្រា
ដូចបងគ្រេកគ្រេះសំណោះថា ទីងកែវកល្យាណ៍លាត្រាច់មក ។ ដើម
ជ្រៃត្រែលបត្តុលគ្រឈឹង មានពស់សន្ធឹងជ្រឹងប្រឹងជ្រេក ដូចបងជ្រែង
ជ្រោមថ្នមពន្ទុក ជ្រើសរកត្រូវចិត្តផិតផ្តេកប្រាណ ។ ក្រសារពេហើរ
សំកាំង ទំដើមក្រសាំងយ៉ាងក្បេមក្បាន្ត ដូចបងក្រសោបឧបកល្យាណ
ក្រសាលក្នុងស្ថានខ្ទេនចរណៃ ។ មានដើមទទឹមទទាំ ហើយយំ
រនៅវត្ថុព្រៀវព្រៃ ខ្លះហើរទទេះចុះទំញ ទៀបឆ្នេរជលស័យទទឹកស្ទាប ។
ដូចអូនទទួលស្រួលពាក់ពឹង ពុំមានទទឹងតាស់ជពប ថ្ងៃនេះខ្ញុំមលើម
ដាប ទទឹកស្រឡាបសន្ទឹកឈើ ។ ពព្វាក់ចុះទំចុងពព្វា ហើយ

ហើររេកទៅតាត្វី សម្បុរពព្វក់មុខនេនើ ហើយហើរពាត្វីទៅតាមវាល ៗ ព្រៃព្រឹក្សបន់ប្រៀបដូចបន់ព្រាត់ រង្គាត់រង្គៀសចិត្តរង្គាល មេឃមីរដូច មិត្រនឹកមមាល បន់ប្រៀបពេលពលដាលនុក ៗ ទុកហើយទើបព្រោស ព្រាប់កំលៀន បន់អើយប្ញូរធៀនមើលរុក្ខា ដើមដុះខ្ពស់ស្រានទានបព្វតា ផ្កាស្គាយស្គុះរុះរេយពាយ ៗ អង្កាញ់អង្កោលអង្គាដី ស្តៅស្តីស្ពុក-ស្រុកគុលក្តាំងបាយ សង្សបសង្ស័រគរគ្រួចក្រាយ ឃ្មៃឃ្លាយខ្លួតខ្លុងខ្នែង គង់គោត ៗ កាកោកាកីស្តីស្នាច់ស្នៃ ប្រេសព្រៃត្រាន់ទ្រាំងលាំងជ័យរជាគ វល្លិវើកវាវណ្ណព័ន្ធនិគ្រោធ លៀបលោតលាយលេចប៉ុចប្អូ ៗ លំពាត់លំពស់លស់លំពង់ គ្រើលគ្រង់នេកពេគរកា សុក្រំសក្រាបត្រាចទ្រៀល ស្វា ក្រឹស្នាខ្នុរខ្នាសម្បុរល្វែង ៗ ដក់ពាដក់ពាយវាយពោធពួច ទ្រមូង ទ្រមូបមៀនទ្រមែង ត្រឡូកត្រឡាតស័ក្យាក្បែង បេកបែងអំបែងថ្ងៃថ្ងៃ ថ្កាន់ ៗ មាក់ប្រេងមាក់ប្រាង់មាក់សាង់សោក មាក់ដោកប្រដាក់មាក់ប្រាខ ច័ន្ទ អំពិលអំពៅស្បូវស្បាតស្បាទ់ ក្រវ៉ាន់វាវល័ណ្ណព័ន្ធព័ទ្ធព័ង ៗ ស្រឡៅ ស្រឡីស្រឡិតលាស់ គ្រៀកគ្រស់តាត្រៅត្រាចទ្រយឹង អង្ក្រមអង្គ្រែងកូង កំភួង វាន់ក្ទុំខ្នុំខ្នឹងឲ្យជ្រឹងព្រៃ ៗ ស្តែង់ស្តេចត្រាច់ក្ខង់ពនាវែក ខបខ្ទេត្រ ហិមពាន្តស្ថានព្រឹក្សព្រៃ ក្រលាលសប្បាយព្រះហឫទ័យ ហើយព្រះជៀស្ន ជ័យចេញចាកចរ ៗ ដល់វាលក្បែរភ្នំព្រះហិមពាន្ត មើលមានហ្វូងម្រឹគមីរ កុះករ កៀង់គ្នាញ៉ីឈ្មោលបោលស៊ីអរ ខ្នះឈរខ្ទះឈប់ស្រប់អង្គា ៗ ឈ្មុស

ក្តាន់រមាសរមាំងព្រាយ ស៊ីដោយខ្សែកណាយកនគ្ង៉ ទន្សាយទន្សោង
រាយរ៉ាត់គ្នា លីលាទៅឈប់ម្ដប់ទន្សៃ ៗ ចចកចូលជ្រកដើមក្រពៅ
លលកទុំនៅដើមលទ្ធ ក្រពៅកប្បាសក្របីបែរ ប្រាណព្រៃឈរឈប់
ម្ដប់ក្រពៅ ៗ ជ្រូកព្រៃជ្រកជ្រប់ម្ដប់ព្រៃធំ ខ្លាឃ្មុំក្រាបក្រោមដើមខ្ញែខ្មៅ
មានឃ្មុំទុំខ្ពលទន្លេលនៅ ខ្លាឃ្មុំឡើងទៅបេះឃ្មុំស៊ី ៗ ខ្លាត្រីស៊ីត្រីក្ងងគុម្ព
ក្រស់ ខ្លាធំលោតផ្លោះកៀងកាល់ញី គយឃ្មុំចាំចាប់អស់ម្រឹគ កាប់
កខ្វេចខ្វីស៊ីតាមប្រាន ៗ ស្វាព្រាមទន្ទ្រាមលើស្វាព្រៃ ស្ទេងគេចំណីប្រឹង
ទន្ទ្រាន លោតលោពារពុះទៅចំពាន តើបតោះបេះបានផ្លែត្រៀលស្វា ៗ
ស្វាក្រេះក្រញឹងខឹងក្រញើន លោតឡើងក្រញាំចាំផលា បេះបានស្វាយស
បរិភោគ្គា ខ្វះគ្ជិចគ្ជិបរ៉ាក្តាប់នៅដៃ ៗ ព្រះពោធិវង្សពង្សមហាក្សត្រ ទត
ស្រេចស្រួតកាត់ដោយដងព្រៃ នឿយព្រួយដោយត្រូវកំដៅថ្ងៃ ក្សត្រថ្ងៃ
ឈ្មៀងទេត្រទតស្រេះស្រង់ ៗ ទើបនាំកំលៀងឈៀងចូលឈប់ ក្រោម
ម្ដប់ព្រឹក្សព្រៃប្របកំពង់ មើលមានកំពីងពួយហោង់ ព្រះអង្គទ្រង់ទតសរ-
សើរថា ៗ នុះដើមកំពីងពួយដុះពន្ធ រាវណ្ឌវិលរង់កំពុងផ្កា ដូចរៀមកំ-
ពុងម្ទេស្នេហា ទីងគែកលម្ព្រាណ៍អនង្គនួន ៗ ព្រលិតដូចបងប្រឡែង
លោម ព្រលឹមលាធោមព្រលឹងស្ងួន ព្រលប់បងវិលទៅឲ្យជួន ឲ្យ
ជួបទីងនួនព្រលឹងបង ៗ ត្រកៀតដុះបៀតដើមត្រកួន ត្រកាលដូច
ស្ងួនទឹមនួនល្អង ត្រកូលស័ក្តិយសខ្ពស់កន្ទង មាសបុប្ផមកបងត្រកងបី ៗ

ត្រាស់ក្មានទ្រង់ផ្លាស់ព្រះពស្ត្រទ្រង់ ស្រេចស្តេចចុះស្រង់ក្នុងស្រះស្រី គីលៀនវៃបទិត្យជិតចក្រី ទើបទតយល់ត្រីក្នុងស្រះស្រង់ ៗ ត្រីក្រាញ់ លលេញដេញត្រីក្រុះ ត្រីក្រឹមក្រាបចុះឈប់បង្អង់ ត្រីក្រាយហែល ក្រោយបណ្តោយគ្រង់ ត្រីក្រឹមវិលវង់ក្រោមត្រីក្រាយ ៗ កញ្ចុះសុះ ចឹកកញ្ចាក់ស្មា ត្រីឆ្តាំងហែលផ្ទាការត់ឆ្ងាយ អណ្តែងអណ្តើកអណ្តែតកាយ ក្ដាំងហាយហែលលាយទឹងក្ដាំងឃាត ៗ ព្រលព្រាធ្វេផ្ទាក្បែរគុម្ពកក់ ត្រីស្លឹញស្ទើតស្ទក់ដេញត្រីស្លាត ពាំស្លែបរស្នឹងប្រឹងសង្វាត ក្ដាំងហាត់ទំ ហែលលឿនឆ្ងៀលឆ្ងាត់ ៗ បង្វារម្ជុលម៉ៃដេជោសដិត គគ្គីគកែកគ្គុក ចឹកកូខក្អាត់ កំភ្លៀវកំភ្លាញស្លាញស្ទុះស្លាត់ អណ្តែតប្រាក់ប្រាព្រួសទឹក ឆ្ងាយ ៗ កំពឹសគោងបុសកំពីងពួយ កំពាត់ស្ទុះស្ទួយស្ទាក់ពីឆ្ងាយ តើប ពះពាននលើកំភ្លួបប្លាយ កំពុងវាត់វាយកំពឹសពង ៗ ផ្កាឈូកវ័កដាស ពាសពេញឈូង ព្រលូងលោលោតលេចរំលង ត្រៃសទុលផែលហែល ក្រសង ព្រលូងហែលធ្វង់តាមប្រឡាយ ៗ ត្រីដៀបតម្រៀបក្នុងត្រីបក្រាច់ ខ្លះគេចចូលបករកសាពយ ខ្លះមុជខ្លះងើបស្រេចស្រុះស្រាយ សប្បាយ ពាសពេញទាំងស្រះស្រី ៗ ស្តេចទតមច្ឆាក្នុងស្រះស្រង់ ស្រេចហើយ ព្រះអង្គស្ទួតឃ្មាតខ្ទី រួសរៀបទ្រង់គ្រឿងរឿងរង្សី ចក្រីនានាំគំលៀន ចរ ៗ ត្រាចតាមធ្មៀរធ្មេរក្បែរមាត់បឹង គិតទឹងវិលវឹងទៅឧត្តរ ជួន ជួបឃើញប្រើសព្រៃមួយមរណ៍ ស្តេចឈរឈប់ឈឹងរំពឹងថា ៗ អញ

បង់ដក់យកដួងហឫទ័យ ចូលរូបប្រើសព្រៃនេះមើលពី ទើបបានពោល
លេងក្នុងព្រឹក្សា យល់ជាសប្បាយពន់ពេកក្រៃ ៗ គិតស្រេចស្តេច
ប្រាប់កំលៀងថា បងចូលរក្សារូបខ្ញុំនៃ ខ្ញុំនឹងដកយកដួងហឫទ័យ ចូល
រូបប្រើសព្រៃលង់រង្គា ៗ កំលៀងស្តាប់ហើយទូលតបស្នង រូបបងនេះ
ហោងសូមធានា ថែរាំប្រយត្ន័ឲ្យល្អជា កុំប្អូនពុំរាព្រួយព្រះទ័យ ៗ
ស្តេចក៏កំលៀងទូលះបង់ហើយ ក្សត្រាត្រាណត្រើយត្រេកអរក្រៃ ទើប
សេពទិព្វមន្តសិល្បសាស្ត្រសេយ្យ ដកយកដួងថៃដួចបំណង ៗ ហើយ
ចូលទៅក្នុងរូបម្រឹគា រូបរស់មានពុំផ្សេង ពោលផ្ទោះលោតផ្លោតតាម
ដោយជង ដែនដានជ្រលងពាលល័យ ៗ ជាកម្មនាំកើតឲ្យគិតខុស
បំពោះក្មេចក្មាំងទាំងសញ្ញា ប្រើសនោះចំត្រាច់សព្វទូលទី ប្រែបដើងគិរី
ទីបព្វតា ៗ យក់ហ្វូងប្រើសព្រៃច្រើនពន្លឹក គគឹកក្នុងដែនអរពោញ
ពុំលង់ពោលចូលហ្វូងនោះណា កៀងការឈ្មោលញីស៊ីសប្បាយ ៗ
ប្រើសព្រៃទីទៃក្នុងហ្វូងនោះ ឥតលុះដំណឹងដឹងលែបខាយ ស្មានជា
ប្រើសស្ទុមិនក្លែងក្លាយ ស៊ីស្មៅប្រញាប់ពាយរៀងគ្នា ៗ

រឿងនេះស្ទុះ បិនមិនទាន់ថែង ទីងបាច់សំដែងទៅកាលគ្រា កាល
ក្រោយស្តេចចូលរូបម្រឹគា ពោលក្នុងអធ្យាស្មសានគ្រោះ ៗ កំលៀង
ដែលនៅចាំរូបស្តេច វាគេចប្រែចិត្តគិតទុច្ចរិត ថាគ្រានេះអញពេញ
បុណ្យខ្ពស់ ពីព្រោះសព្វសិទ្ធកុមារ ៗ ដឿអញឲ្យនៅចាំរូបទ្រង់ នេះ

ចំជាល្ងង់ឥតប្រាជ្ញា សុវណ្ណកេសរល្អថ្លៃថ្លា មិនរួចទៅណាគង់បានដៃ ៗ តាំងពីទុបកាដកដបុរី ស្រីឆ្គារសាវស្រើច្រើនក្រាសក្រៃ បានអញអស់ហើយកុំសង្ស័យ នរណានឹងថ្លៃជាម្តេចបាន ៗ អញនឹងដកយកជូនជីវិតចូលរូបសព្វសិទ្ធិជាក្សត្រក្សាន្ត ហើយវិលវិញទៅលំនៅស្ថាន គង់បានសម្រេចដូចបំណង ៗ គិតភ្លាមទើបសែកមន្តប្រសិទ្ធិ ដកយកជូនចិត្តពុំឆ្ងរឆ្ងន ចូលរូបព្រះមហាសត្វប្រាសប្បុន រស់ឡើងដូចបីនំពេចទី ៗ ទើបថាទុរូបអង្គអញឯង ទុកនៅកន្លែងនេះធ្វើអ្វី សព្វសិទ្ធិមកឃើញដឹងសេចក្តី នឹងកើតអប្រិយដល់ខ្លួនប្រាណ ៗ ត្បិតគេមានវិទ្ធិសក្តិសិទ្ធិណាស់ គង់ផ្លាស់ចូលរូបអញវិញបាន នឹងតាមប្រកិតជិតដោយដានទៅដល់ពជហានត្រូវគាក ៗ គង់កើតហេតុទោសធាស់ទុក្ខម្នេញ គួរផុតចោលចេញនេះទើបជា គិតហើយបង្ហាត់កើងម្នា កំផុតរូបវានេះប្រាត់បង់ ៗ ស្រេបស្រូតរូតរះដើរស្ទើររត់ អញ្ចេញទន្ទេញដោយចិត្តបង់ កាត់ព្រៃជ្រោះជ្រៅសំដៅត្រង់ ពុំលង់បានដល់មណ្ឌលស្ថាន ៗ ទើបឡើងចរចូលគន្ធប្រាង្គម្នី អង្គុយនៅពីខែមស្ពុះកាន្ត ស្រីស្នំក្រមការតាំងប៉ុន្មាន ពុំបានដឹងដើមជានព្រះអង្គ ៗ នាងខ្លះចូលថ្វាយសុគន្ធរស ខ្លះថ្វាយព្រះពស្ត្រប្រពៃធូន់ ខ្លះខែសាពយថ្វាយទឹកស្រង់ ហើយគាល់រហន់នៅត្រៀបត្រា ៗ សុវណ្ណកេសរវត្ថុតាមយង់ គន់ទ្រង់ជាអង្គព្រះភស្តា តែស្តាប់សំដីដែលចរចា កិរិយាឫកនោះពុំទំនង ៗ ព្រះនាងរឹងរឹតគិតពិភាល់ ថែមឆ្ងល់

ទីងបាត់គីលៀនផង នាងរឹងព្រួយព្រះទ័យកន្លង នួនល្អងត្រិះរិះដោយ
ប្រាជ្ញា ៗ យល់ហេតុប្រហែលអាគីលៀន បញ្ឆោតបញ្ឆៀនព្រះកស្ត
ព្រោះផ្សិតវាចេះសិល្បសាស្ត្រា បានជាអស្ចារ្យថ្លៃកអម្បាយ ៗ ទព្រះ
សំឡាញ់ពេញចិត្តប្អូន ម៉្លេះហើយសមសួនឲ្យបោលរូបកាយ គិតក្តាន់ទើប
នាងនាថឆោមឆាយ កែកលទបាយសួរទៅថា ៗ គីលៀនដែលទៅជាមួយ
នោះ ឥឡូវបាត់សោះទៅឯណា អាណិតប្រាប់ខ្ញុំកុំមុសា ត្បិតខ្ញុំសង្កា
ពន់ពេកក្រៃ ៗ ដូនថៃគីលៀវក្នុងរូបស្តេច ឆ្លើយគេចដោះសាទៅថាហៃ
ម្ចាស់មិត្តមាសមុំកុំអាល័យ បងផ្តាញវាក្បែរក្នុងព្រៃជ្រៅ ៗ ត្បិតវាចេះវិទ្ធ
មន្តអាគម បើខំចិញ្ចឹមទុកឲ្យនៅ ក្រែងវាទ្រុចរិតចិត្តយោរយៅ តទៅ
គង់កើតហេតុពុំខាន ៗ ឆោមយង់ទ្រង់ស្តាប់ស័ព្ទសម័យ រំងរឹតសង្ស័យ
ពន់ប្រមាណ តែនាងធ្វើបកហាក់ស្មោះស្មាន កល្យាណឆ្លើយតបទៅ
វិញថា ៗ គីលៀនចេះសិល្បស្មើគ្នានោះ ផ្តាញវាទៅចុះទុកធ្វើអ្វី ក្រែង
តទៅមុខកើតអប្រិយ ថាហើយក្សត្រីគង់ស្ងៀមស្ងាត់ ៗ គីលៀនបាន
ស្តាប់សព្វវាទី នៃនាងនារីឆ្លើយតបថ្វាត់ វាយល់ថានាងពុំជ្រាបអត្ថ
រឹងត្រេកអរក្តាត់ផតទបទា ៗ ថាអេះខ្លួនអញពេញឈានភ័ព្វ មកកប់
ជួបជាប់ជាវាសនា ទាំងទីទបកដកជបរិវារ បានអញត្រួតត្រាជាប្រា-
កដ ៗ សម័យថ្ងៃនោះលុះវេលា ព្រលប់សន្ធ្យាជាកំណត់ គីលៀន
ដែលវាចិត្តចោរក្បត់ ចរចូលទៅនរគ្គក្សត្រីថ្ងៃ ៗ តែដោយអំណាច

បុណ្យបារមី នៃព្រះចក្រីមកពៃត្រ ទឹងនាងនារីមានទិស្ស័យ បាន សាងព្រេងត្រៃតែពល់ជាតិ ៗ ពុំដែលប្រព្រឹត្តគិតកាមេ បុណ្យនោះ បន្ទៃប្រែឲ្យឃ្លាត ភីលៀងបោរចិត្តគិតវិពទ ចូលដល់នាងនាថបង់ រួមរ័ក្ស ៗ បណ្តាលចិត្តនោះឲ្យក្តៅក្លួល ដូចភ្លើងឆេះឆួលជ្រួលញ័រ ញាក់ តែពំចំលោមដោមរល័ក្ខណ៍ តាមដោយស្មោះស្ម័គ្រក្តីស្នេហា ៗ នាងនាថក្អែងគលព្រោះយល់ប្លែក ពោលពាក្យប្រកែកដោះសាថា ខ្ញុំ ខ្ញុំថ្ងៃនេះឈឺទុក ក្តៅផ្សាក្នុងទ្រូងគ្មានសប្បាយ ៗ អញ្ជើញទៅផ្ទំទីង ស្នំស្នំទ តាមតែចូលចិត្តផ្តេកផ្តិតកាយ ថាហើយនាងក្រោកចាកចេញ ឆ្ងាយ ព្រះក័ក្ត្រពុំស្រាយពុំស្រស់ស្រួល ៗ តែងតែជញ្ជាំងរំពឹងគិត ខ្លោច ផ្សាក្នុងចិត្តរិតអាក់អួល ទុកសៀតបុកគុកក្តៅក្លួល រំជួលចំបែងតែងទុក្ខា ៗ ភីលៀងពាយល់អធ្យាស្រ័យ ថានាងស្រីថ្ងៃពុំស្នេហា ទើបពាចេញចាក ទីសយនា ទៅរួមពាសនាទីងសាវស្រី ៗ អស់ពួកស្រីស្នំក្រមបរិចារ ត្រេកអរពល់គ្នាជាមេត្រី ហេតុពុំដឹងដល់កលសេចក្តី ស្មានព្រះចក្រីទ្រង់ ពបគាន ៗ សុវណ្ណកេសរដោមពីសី នាគ្គីងពត្រីនោះកល្យាណ ទ្រង់ព្រះ កន្សែងសោករខាន ប្រះព្រាណសញ្ជប់ជ្រប់ភ័ក្ត្រា ៗ ទ្រង់ថ្ងៃនទំនួញ ទួញរៀបរាប់ ថាទុអូនធ្លាប់យល់កស្តា ពេលផ្ទំចូលផ្ទំជាសុខា ពេល សោយក្រយាសព្វចំណី ៗ ធ្លាប់គាល់ធ្លាប់ផិតព្រះបាទបង ពុំដែលឲ្យហ្មង ចិត្តប្អូនស្រី ពេលស្រង់ចូលស្រង់ពីអេង្គខី សព្វទិនពត្រីពុំខាតខាន ៗ

រូបរសចំពោះទៅតិចថ្ងៃ ជាកម្មបច្ច័យពីបុរាណ ទ្រង់ចង់ប្រពាតព្រៃស្មសាន ប្អូនបានសូមខ្លួនជូនស្ដេចទៅ ។ ទ្រង់ឃាត់ខាំងខាថាមិនព្រម តែកីលៀងអមអង្គនៃបនៅ គ្រាទេះវិបរិតចិត្តអូនទៅ ព្រោះរូបបមយៅប្លែកអស្ចារ្យ ។ គន់រូបគឺរូបស្ដេចប្រាកដ មកខុសតែបទបែបកិរិយា យល់ជាកីលៀងចោរមោហា វាផ្ចាញដីវមែនដឹងអើយ ។ ឱ ព្រះរៀមរក្សអ្នកមាសថ្លៃ ជាក្ស័យឬក្សត្ររស់នៅឡើយ ប្អូនសែនទុក្ខធ្ងន់ព្រះគុណអើយ ម៉្លេះហើយសមនឹងក្ស័យជីពជន្ម ។ អនិច្ចាក្សត្រីស្រីទ្រង់លំក្ខណ៍ តែងសោកអួលអាក់ក្រៃស្រពន់ ស្រពោនតាំងពីព្រលប់លន់ លុះដល់អរុណរៀងរង្សី ។ ពុំបានបន្ទុំក្រំបំបែង សោយសោកថ្ងាថ្ងូងទំនួញស្ដី មុខគួរអាណិតគិតប្រណី គឺកម្មក្សត្រីនឹងក្សត្រា ។

ទើបបែរនិយាយបទទៅត្រង់ ពីអង្គសព្វសិទ្ធិកុមារ ដែលអ្នកដកយកដួងចិន្ដា ចូលរូបម្រឹគានៅនាព្រៃ ។ ចេះតែតម្រេកត្រេកសប្បាយនឹងប្រើសទាំងឡាយក្មេងព្រះទ័យ ត្រាច់ក្នុងព្រឹក្សាពនាល័យ ទាល់ថ្ងៃរសៀលព្រះសុរិយា ។ សុរិយេជ្រៀងជ្រេទេរជ្រៀតជ្រក ព្រះអង្គភ្ញាក់ក្នុងព្រះចិន្ដា ផ្ទោះចាកផ្ទាកបោលហ្វូងម្រឹគា ម្នីម្នាសំដៅទៅស្រះស្រី ។ លុះដល់វសព្វលប្រឹងទតឈ្មៀង រកមើលកីលៀងពុំឃើញអ្វី យល់តែក្អកក្អែងនៅថ្មីៗ ទាំងរូបបក្រីពុំឃើញសោះ ។ ទ្រង់ស្ទុតរន្ធត់ព្រះទ័យា យល់ជាកីលៀងគិតទុយិស វាដកដួងវៃចនៃវានោះ

ចូលរូបអញស្មោះដោយអញស្មាន ៗ ហើយក៏វិលវិញទៅក្រុងក្រៃ ទុសមស្រីថ្លៃពុំដឹងប្រាណ ប្ដីមួយមានស្នេហ៍តែខ្លួនបាន ដោយបុណ្យបុរាណជួយកំរើក ៗ អានេះហៅពេញបច្ចាមិត្រ ក៏គិតឲ្យអញក្ស័យជន្មា គុនព្រៃម្នាក់ឯងឥតមានគ្នា ព្រោះស្រឡាញ់ក៏ស្មើជីវិត ៗ ទុកចិត្តក៏ណាស់ផ្លាស់រូបកាយ ហើយបេញចោលឆ្ងាយទៅមិនគិត បានជាផ្កាយថ្មស់ពាស់គំនិត នេះពិតពុំស្គាល់គុណមាយា ៗ ចុះចុងអង្គអញពេញហោល្ងង់ ព្រោះខ្លួនធ្លាប់ត្រង់ធ្លាប់ចិត្តជា ជាតិមនុស្សជឿមនុស្សពាលពាលា ជឿណាស់គង់ក៏ឲ្យទោសពៃរ៍ ៗ

សព្វស្រស្រីប្រុសពាំងអស់គ្នា ចូរចាំទុកជាច្បាប់ប្រពៃ កុំទុកចិត្តមនុស្សអសប្បុរ័យ ឲ្យដឹងដោយន័យរឿងនេះណា ៗ មួយទំពីងនឹងដែលពឹងនោះ ចំពោះបានតែអង្គអាត្មា ទីពឹងគេក្រៅពុំត្រូវការ លោកថាតែខ្លួនពឹងខ្លួនឯង ៗ

ព្រះពោធិ៍វង្សពង្សពុទ្ធរ័តន៍ អ្នកតែងសោកក្ដាត់ក្ដៅចំបែង រឹងក្លួលវិជ្ជលទូញក្ដង ១ ថ្លាថ្លៃនកប់រៀបក្រំព្រះទ័យ ៗ អនិច្ចាខ្លួនអើយមកមានកម្ម ពីះព្រាងបងចាំនាំជូនវៃ ឲ្យកើតវិបរិតគិតខុសក្រៃ តែអង្គអញព្វឥតមានគ្នា ៗ ខ្លួនស្លាប់តាមភ័ព្វមិនគួរស្ដាយ គិតតែទោមទោយពៅពុំរា ម៉្ញើះសមទុំងនគុនភាព ស្មានជាបងបានប្រាណវិលទៅ ៗ គ្រានេះគ្រោះថ្នាក់អកុសល មកផ្ដល់ឲ្យឃ្លាតពីស្រីពៅ ប្រែព្រាត់និកស

ប្រាសលំនៅ ដោយព្រៃប្រកជ្រៅជ្រោះបព្វតា ។ ទើបតែបានភព
ប្រសព្វប្រាណ មិនយូរប៉ុន្មានមានទុក្ខផ្សា ព្រោះជឿចិត្តគេឥតសង្កា
ពុំដឹងអាត្មាជួបច្នេះឡើយ ។ ទុប្បាបបុព្វេពៀរវេរគុណ ជាតិមុនពង្រាត់សត្វ
ដឹងហើយ ជាតិនេះទើបខ្លួនសូន្យឥតគ្រើយ មានទុក្ខពុំស្បើយល្ហើយ
ពីប្រាណ ។ ទុះទ្រូមរក៏ក្រិសរង់ ចាំទ្រង់អនង្គអនុជគ្រាន ភ្ជាប់ផ្ញើបើ
ទីទេនសុរិកាន្ត ផ្ទំផ្ញើមពីប្រាណសំពន្ធចិត្ត ។ ពេលដែលនិទ្រានាសុខ
សោយអ្នកដេកកើយដៃបងគៀកកិត ត្រកងកាយពៅទៅចមស្និទ្ធ គង់
ស្ថានស្នេហ៍ស្និតឥតមានហ្មង ។ ឥឡូវបងទៅជាព្រើសព្រៃ ទងវិលវង
វៃរកខ្លួនល្អង ពុំដឹងដំបងដៃខងខានដង ខ្លួនសោកសត្វផងទៅធ្វើអ្វី ។
ម្នេះហើយថ្ងៃអើយរៀមស៊ូស្លាប់ ផ្លាស់ជាតិវិលចាប់កំណើតថ្មី ជាតិ
ក្រោយសូមឲ្យជួបអូនស្រី ជាគូប្ដីពាល់អស់ជន្ម ។ បើអូនទៅកើតភព
ណា ។ ជាទេពទេវតាស្ថិតលើម- ណ្ឌលនៃទិព្វពេជ្រវេជយន្ត រៀម
សូមបងពន្លមជីវ ។ ឬកើតជាមនុស្សស្មុះសព្វស្ថាន ជាសត្វតិរច្ឆានអ្វី
ក្ដីណា ជាគ្រុឌកុជង្គក្រុងអសុរ គ្រប់សព្វកាសាក្នុងក្រុងក្រៃ ។ បង
សូមចាប់ជាតិកើតជួបពៅ ជាគូនៃបនៅរួមពិស្ម័យ កុំឲ្យឃ្លាឃ្លាតទាន់
នាថថ្លៃ លង់លុះដល់ព្រះស្ថាននិព្វាន ។ សព្វសិទ្ធិទិទ្ធិវង្គពូជពង្សព្រះ អ្នក
សោកស្ដាំងស្មុគបាត់វិញ្ញាណ ដួលទាំងដំហរដែលឈរឈាន ពុំមាន
ដឹងអង្គលង់សន្ធិយា ។ សន្សៀមពេយរុះចុះដោកស្ថាន ទើបបានភ្ញាក់

ទៀនឈររេក ញ័រញាក់ក្នុងកាយនៃម្រឹគា រើទនាឈើផ្លួលជ្រួល
ឥន្ទ្រីយ ៗ ទ្រង់ទួញថាឱដួងកែវអើយ គ្រានេះម៉្លេះហើយរៀមចាកចេ
ចោលថៃ្ទនសយនាប្រាសាទមណី ចោលអស់នារីស្រីគ្គាស្នំ ៗ
ប្រសិនបើបងស្លាប់អសារ ឥតមាននរណាបានដឹងដំណើរនៃរៀមស្មោះ
សោះសូន្យសម ចោលគន្ធឥតអំពល់ដល់ស្រី ៗ គ្រានេះទីងពៅទាំង
ខ្លួនសត្វ ចូលក្នុងមេប្រដ្ឋកដបូរ ក្រែងអស់មនុស្សម្នាមិនប្រណី បៀត
បៀនដើម្បីជាអាហារ ៗ ឥឡូវបើទៅតែក្នុងព្រៃ មុខជានឹងក្ស័យ
ជន្មជីវ៉ា ព្រះអង្គរង់រំពឹងគិតថប់ថា ទើបត្រាច់យាត្រាទាំងរាត្រី ៗ ម្នាក់
ឯងកណ្តៀងកណ្តោចសល់ ងងឹតពុំយល់ទិសទីអ្វី តាំងពីព្រលប់យប់
យាមបី ចក្រីយាត្រាត្រាច់កម្រង់ ៗ យាងព្រះបាទាក្បែរដើមក្ទុំ លង់
លុះដាស់ចំត្រជាក់អង្គ ព្រះទ័យស្រយុតស្លុតឡើងឡង់ ចំផ្លូងសណ្តាប់
ស្តាប់បក្សី ៗ សូរសៀងចចាតរន្ទាន់ធ្ងួន យំគងស្រងាត់ក្នុងរាត្រី ហាក់
ដូចសំឡេងព្រះប្អូនស្រី ចក្រីស្តាប់ដាក់អាក់អួលផ្សា ៗ ទ្រង់ព្រះកន្សែង
សោកសញ្ជប់ ឱបោចមកតដួងជីវ៉ា ម៉េះសមក្រំខ្ទួនផ្ទួនទុក្ខា ប្ដីកែវ
កល្យាណីពុំទីកបង ៗ សត្វរៃកណ្តឹងកណ្តាលក្មុំ ឮសូរគងំយំធ្ងើយធ្ងួន
លទ្ធោចលទ្ធង់ក្នុងដែនដង ដូចពាក្យទូនល្អងសងចរចា ៗ ស្តែងស្តេច
ត្រាច់ត្រង់ក្នុងរាត្រី ឥតបីឈររេចប់ស្រប់គាត្នា អាសូរស្តេចពុំដឹងទិសា
ទាល់តែសុរិយាឡើងរះថ្កាន ៗ ចំត្រាច់លុះដល់យល់ចំការ យាយតា

ដកទាំងពីរប្រាណ សង់ខ្ទមប្រថព្រាំព្រៃស្មសាន ចិញ្ចឹមតែបានសត្វសារិ-
កា ។ ហេតុបុណ្យបារមីពង្សពោធិ បានសាងអំពីជាតិអតីតា ដូនពេល
ថ្ងៃនោះជាអស្ចារ្យ សារិកាក្សិណក្ស័យប្រល័យជន្ម ។ យាយតាដក
ទាំងពីរនាក់ គាត់បានយល់ជាក់ទឹកស្តាយលន់ ទើបបបួលគ្នាប្តីប្រពន្ធ
ដើរចេញពីមណ្ឌលគ្រឹហា ។ យួរខ្មោចសារិកាទៅបោះចោល ខាង
ក្រៅមាត់ក្រោលបេង្គា ហើយវិលមកផ្ទះវិញម្នីម្នា នាក្នុងវេលាព្រហាម
នោះ ។ សត្វសិទ្ធិដែលចូលរូបប្រើសព្រៃ ដៀស្ថជ័យទតយល់ទ្រង់
បរព្ញោះ ទៅទៀបសារិកាទឹកពីគ្រោះ ថានេះគឺមោះបុណ្យបុពណ៌ ។
ទ្រង់ព្រះអំណរអរពេកក្រៃ សុគ្រៃសែកសិល្បសេយ្យវិជ្ជាការ ដកដូង
ចិន្តាពីប្រើសបាន ទើបចូលក្នុងប្រាណសត្វសារិកា ។ រួបរស់រូបឡើង
រំពេចខ្ទី បក្សីសោមនស្សស្រស់ប្រីតា សសិតស្មោមស្មាបហើយហើរទៅ
តាមអាកាសានកាល័យ ។ ស្រូតកាត់តម្រង់ត្រង់បូរី ហេតុះដោយបារមី
ក្សត្របមក្រៃ ហើយដល់មណ្ឌលយល់ក្រុងក្រៃ កូវន័យស្គាល់ជាក់ជា
រាជស្ថាន ។ ទ្រង់ទតព្រះនេត្រឃើញប្រាសាទ ប្រឹងហើរសង្វាតចូល
ទៅបាន ទំនៅគៅ តាមហាក្សត្រក្សត្រ យល់នាងកល្យាណកំពុងក្រំ ។
ទ្រង់ព្រះវិយោគសោកប្រះប្រាណ លើវែនទិព្វស្ថានប្រសើរសេម សា-
រិកាក៏រះគិតបារម្ភ ប្រឹងខំបន្ទីសព្ទរាំចា ។ ថាយើងកំសត់អត់ចំណី គ្មានអ្វី
បរិភោគក្នុងព្រឹក្សា ខំហើរចូលមកចិត្តប្រាថ្នា សូមផលអាហារបរិភោគផង ។

កាលនោះព្រះនាងនាថទិមល កំពុងអំពល់ទល់ទុក្ខហ្មង លុះឮសារិកា
ភាសាសង់ ទួនល្អងទ្រង់បែរព្រះភ័ក្រ្ត ៗ បើកព្រះនេត្រទតទៅសារិកា
ទំនាក់គោរពាប្រាសាទស្រី នាងនឹកពិតល់ឆ្ងល់សេចក្តី ទើបមានសវនីយ៍
សួរទៅថា ៗ កែវអើយព្រៃព្រះហិមពាន្ត ផលព្រឹក្សសិងមានច្រើនត្រៀប
ត្រា ម្តេចឡើយជាអត់ឃ្លានអាហារ ចូរអ្នកបរាប្រាប់យើងផង ៗ ដួង
ចិត្តទ្រង់នឹកនឹងសារិកា ទើបមានវាចាឆ្លើយតបសួរ ថាយើងមិនសត្វដូច
សត្វផង ទូលល្អងជឿចុះកុំសង្កា ៗ បងជាស្វាមីនៃវរមិត្រ នាមឈ្មោះ
សព្វសិទ្ធិកុមារ ពីម្សិលទៅលេងព្រៃព្រឹក្សា នឹងរកគីលៀនជៀនជាក់
ច្បាស់ ៗ ទៅដល់យល់ម្រើសមួយមរណា នៅក្នុងអង្គាប្របមាត់ស្រះ
បងនឹកអាព្រួចក្នុងប្រាណណាស់ ប្រែអង្គបងផ្លាស់ដូងដី ៗ ចូលរូប
ម្រើសព្រៃផលក្សយនោះ ពីព្រោះបងល្បងលងវិជ្ជា ហើយបោលចូល
ព្រៃពនាលី ប្របដើងគីរីទីបព្វតា ៗ ឯរូបបងឲ្យក្អែលៀនចាំ ថែទាំប្រ-
យ័ត្នសត្វហង្សា ពុំគួរពាក់តចិត្តមុសា ដកជីវិតវាចូលរូបបង ៗ រូបវា ១
ដុតៈភ្លើងបងបាត់ ស្រេចវាស្រូតកាត់មកតែម្តង ខ្ញុំបងទុក្ខធ្ងន់ពន់គន្ធង
ក្តុលក្តៅសៅហ្មងវេទនា ៗ ខំតែត្រាចចពុំឈរឈប់ ចាំនយប់
ងងឹតសន្ធ្យា លំបាកពេកពិតជិតមរណា ព្រោះជាបានជួបសារិ-
កាស្លាប់ ៗ

(កាលអើយកាលណោះ) សុវណ្ណកេសរល្អប្រិមប្រិយ បានស្តាប់សកុណាថ្លែងញោះទី ជឿជាចក្រីឥតសង្កា ៗ ទ្រង់ព្រះវិយោគសោកខ្សឹកខ្សួល រំជួលក្តួលក្តៅសៅទុក លើកករបង្គំទូលទៅថា ឱព្រះភស្តាម្ចាស់ប្អូនអើយ ៗ ម្តេចទុកចិត្តគេមិនត្រិះត្រាន់ ទាល់តែឥតទុកទានប៉ុណ្ណោះហើយ ឥតប្រយ័ត្នបានរូបទៅព្រៃធំយ ម៉េះហើយៈធ្វើអ្វីយកវិញបាន ៗ នាងលើកសកុណាជាស្វាមី ទូលលើសិរសើស្រីកល្យាណ ផលនេត្រស្រោកជោគអស់ប្រាណ រំពានវិយោគសោកាល័យ ៗ សព្វសិទ្ធិរិទ្ធិគ្រឿងពេជ្រក្សត្រ យល់ព្រះប្អូនវត្តសោកសង្រែង លោមថាព្រលឹងមាសថ្មើរថ្មៃ សោកក្រែទឹងក្រំជាំទុក ៗ លោមហើយដណ្តឹងសួរទៀតទៅ ហៃតៅសំឡាញ់ពេញចិន្តា យប់មិញអាចោរចិត្តបុស្សា វាមកអាសនានេះដែរឬ? ៗ ព្រះនាងស្តាប់ហើយឆ្លើយទៅថា សូមព្រះភស្តាប្រោសប្រណី អំពីវេលានាពត្រី ខ្ញុំដឹងសេចក្តីជាក់ក្នុងចិត្ត ៗ ព្រោះឃើញគិរីយោរថ្លៃកន្សែងថ្លៃកទាំងសំឡេងឬកចរិត វាមករកខ្ញុំ ៗ មិនស្ស៊ើក ខ្ញុំគិតគេចគលកែដោះស្រាយ ៗ ប្រាប់វាថាឈឺទុទរខ្លាំង ញាប់ញ័រអស់ទាំងអង្គកាយ ហើយខ្ញុំដោះខ្លួនទៅពួនឡាយ វាក៏សោយចិត្តប្រាថ្នា ៗ វាគេចទៅដេកទីងស្ងំស្ងៀម តាមចន្ទចូលចិត្តគិតចេតនា ពាក្យពិតប្រេះឯងមិនវៃទ្វីងថា កុំព្រះភស្តាព្រួយបារម្ភ ៗ ព្រះអង្គស្តាប់ហើយឆ្លើយតបថា ហៃកែវកល្យាណ៍ក្រពសួស្តីសម ប្អូនអើយជាស្រីថ្លៃឧត្តម ជាក់ចំពេញល្អក្រអំបាន ៗ មាន

ចិត្តស្លុតត្រង់ទីឯកស្តា ថាហើយសារិកាលោមកំសាន្ត កុំសោកថ្ងៃឡើយ ស្រីកល្យាណា បងនឹងគិតអានអាចិទព្វាយ ៗ ព្រឹកនេះចូរនាងទៅព្រានស្នួរ ដោយគួរដល់វាជាលែបខាយ ថាត្បិតបង់ជីងវិទូសាយ កែន្ទកាយប្រើបានប៉ុន្មានយ៉ាង ៗ ថាតាំងពិភពប្រសព្វគ្នា ពុំឃើញឫទ្ធាណោះជាតាង ឥឡូវច្បាស់ច្បងសោះអាង់ខ្នង និយាយឡើងនាងតែបានការ ៗ គង់តែវាទីងព្រមប្រាកដ ស្រីរត្នស្តាប់ហើយសោមនស្សា រៀបអស់ចំណីឲ្យសកុណា បរិភោគអាហារឆ្អែតស្កប់ស្កល់ ៗ ស្រេចទើបនាងលាក់សត្វសារិកា ក្រោមខែនសុវណ្ណាប្រសើរសល់ ពុំឲ្យអ្នកផងដឹងដើមដល់ កិច្ចកលគំនិតស្រីរត្នថ្លៃ ៗ ស្រេចពជធិតាវពង្ស បេញគង់ប្រចទខែនចរណៃ ហើយថ្ងៃងវាទុំតាំងក្រៃក្រៃ ដោយអធ្យាស្រ័យប្រាយប្រាជ្ញា ៗ ខ្ញុំពុំដែលឃើញឫទ្ធិព្រះអង្គ ស្តេចទ្រង់ប្តូកផ្លាស់ព្រះកាយា គ្រាន់តែរឮព្យួរបេស្តាគេថាស្តេចដកជីវិតបាន ៗ ចិត្តខ្ញុំចង់ឃើញផាក់ទីងក្នែក យល់ជាទីងប្តូកទៅប៉ុន្មាន បើទ្រង់អាណិតគិតរាប់អាន សូមមហាក្សត្រក្សាន្តប្រោសប្រណី ៗ កាលៀងទុច្ចរិតចិត្តមិត្រទ្រុះ នៅក្នុងរូបនោះឮក្សត្រី ថាចង់ឃើញឫទ្ធិបារមី ក្តីនក្តួចស្មារតីដោយស្នេហា ៗ ពីព្រោះគំនិតវាគិតគួនចង់បានស្រីស្ងួនទន្ទួនកល្យាណ៍ ប្លាចខ្លាំងប៉ាំងជិតបិទប្រាជ្ញា ពុំដឹងកាយាប៉ុនធូលី ៗ ទើបឆ្លើយថាហៃថ្លៃវរមិត្រ មាសគិតចង់យលកលឫទ្ធីបងនឹងប្តូរផ្លាយកាយិន្ទ្រីយ ឲ្យកែវទេពីឃើញជាក់ស្តែង ៗ ទើបបែរ

ប្រែប្រាប់ពជកាមាត្យ ថាឯងឯងចូរឃោសទៅបាត់បែង រៀបព្រះពន្លានាំ កន្ទេង ទៅទទួលតែល្បែងតែងឲ្យឆាប់ ៗ មេនាងបួនអញចេញសំដែងរិទ្ធិ ហើយឯងចូរគិតរកសត្វស្លាប់ យកមកបំរុងឲ្យមានស្រាប់ អាមាត្យបាន ស្ដាប់ស័ព្ទបញ្ជា ៗ ហើយក្រាបបង្គំពុំការង់ ពុលង់ចេញទៅហៅគ្នីគ្នា ប្រាយប្រាប់បង្គាប់អស់មុខងារ រៀបព្រះពន្លារួចស្រេច ៗ ខ្លះរត់ទៅរក សត្វទើបស្លាប់ រូតរះប្រញាប់ឲ្យឆាប់ទាន់ នរណារកបានៗ ផ្ទាន់ សឹង រត់ប្រព័ន្ធទៅម្នីម្នា ៗ ទៅឃើញតែមួយស្លាប់ថ្មី ទើបអស់សេនិយហៅ គ្នាកងារ នាំយកមកទុកមុខពន្លា ឯកស្ត្រប្រជាក្នុងផែនដី ៗ ឮថាស្ដេច ស្ដែងឫទ្ធិថ្ងៃឫទ្ធិ ដកយកជីវិតចូលរូបថ្មី សឹងផ្អើលគឹកកង់ពេញដី នាំ គ្នាប្រុសស្រីមកមើលមីរ ៗ លុះដល់មេនាងបួនដូនវេលា ក៏រលៀងនោះរ៉ា ចេញចាកទី ទេនទិព្វស្អាងស្អាតប្រាសាទមណី ហើយហៅទេវីពជកញ្ញា ៗ ថាវៃមាសស្ងួនទឹមនួនល្អង អញ្ជើញមើលបងល្បែងមើលពី ឲ្យឃើញ ជាក់ច្បាស់ទ្វេចេស្ដា ថាហើយយាត្រាចេញពុំលង់ ៗ ព្រះនាងស្ដែង ស្ដាប់ស័ព្ទអគ្គិប្រាយ ត្រេកអរសួរសព ទើបឆោមយង់ វិលចូលក្នុងទែន ទីគិម-ធ្លលតាប់គួរគង់ទៀបសារិកា ៗ នាងយកប្រអប់មាសមណីរត្ន ហើយលើកព្រះហត្ថទាំងទ្វេហារ ថ្នាក់ថ្នមចមចក្រេសកុណា ជាព្រះ ភស្ដាស្វាមីភ័ក្ដិ ៗ ដាក់ក្នុងប្រអប់សុវណ្ណា ទើបហៅស្រីគ្គារជំនិត ម្នាក់ កាន់តាមឆោមយង់អនង្គលក្ខណ៍ ៗ ចេញចាកដំណាក់ស្រេពន់

ខ្ចី ៗ ពុំឲ្យខរណាដីធំដើមដល់ កិច្ចកលយល់ធន់ជាពីរបី ស្ងួនជា
ប្រអប់ដាក់ព្រះស្រី ដូចកាលប្រក្រតីសព្វមួយជន់ ៗ លុះដល់ពន្លាទើប
ឆោមយង់ នាងឡើងពៅគង់ពុំឃ្លូវផ្សេង មន្ត្រីតូចធំក្រុមគ្រប់គន់ ប្រជា
ជនជន់ច្រើនតាន់តាប់ ៗ ជ្រៀតជ្រែកជែកគ្នាជាប្រពូន ពកូនពៅទៅ
ខ្ទន់ខ្ទប់ ចាំមើលរឿងស្ដេចស្រេចស្រាប់ គឹកកង់អឺងអាប់សព្ទកោលា ៗ
ភីលៀងពាណោចោរទុច្ចរិត រាជកដួងចិត្តបាករូបា បូលខ្មោចពពែគ្រា
នោះណា រួចសៃដីរាំពេចក្លាម ៗ ណោណោគប៉ោលផ្ទាតផ្ទះក្លៀវ
ក្លៃត ដោយហេតុវិក្យាឆ្លាស់រូបទាម ពពែសត្វស្មុគរត់ទទ្រាម មនុស្ស
ផងស៊ីឯតាមមើលជាសដឹត ៗ សុវណ្ណកេសរល្អវិលាស បើកប្រអប់
មាសធាប់ដូចចិត្ត ឯអគ្គិពន្សពោធិសត្វសិទ្ធិ ទ្រង់រិទ្ធិដកដួងហ្ឫទ័យា ៗ
ចេញពីសកុណៃរពុំលង់ បូលក្នុងរូបអគ្គព្រះរាជា ក្រោកឡើងតន្ត្រី
ព្រះបាទា ស្រែកថាពះរាចោរទុជិន ៗ អាសត្វពពែនេះពេញក្បួត
ត្រូវបទអយ្យកាជាទម្ងន់ តាមទោសរាំនោះខុសលើសលន់ មន្ត្រីគួរ
គន់គិតតាមការ ៗ ត្រាស់ក្លាងនាំនាងអគ្គមហេសី នៅស្រីព្រះស្នំ
ក្រមបរិវារ ឡើងលើប្រាសាទប្រសើរថ្លៃ ឡើងគង់អាសនា
ទៃនសុរិកាន្ត ៗ ឯអស់ចតុរង្គអង្គសេនា បានឮទន្ទ្រានមហាក្សត្រក្សាន្ត
ទឹកឆ្ងល់ពីកាលតែគ្រប់ប្រាណ ពពែនេះមានហេតុទោសអ្វី ៗ

(មានត)

# រឿងហង្សយន្ត

(តមក)

លោក អ៊ឹម-ភន បម្លងពីសាស្ត្រាស្លឹករឹត

ហាក់ហង្សច្រើនពណ៌សព្វសាយ ស្ទោមស្ទាបកែមកាយ ពិចិត្រទូវគេទ៍ នោ ៗ សរសើរកើតក្ដើជ្រះថ្លា កែវកែមសុវណ្ណ ក្រឡាបទំបញ្ចន់ ៗ ស្រាប់ស្រេចក្បូរក្បាច់អស់អគ្គ ទិទ្វាយយន្តហង្ស ស្រេចបរិបូណ៌ហើយ ណា ៗ ទើបជាងទាំងពីរនាំគ្នា យកហង្សសុវណ្ណ ទៅថ្វាយសម្ដេច ជៀស្តជ័យ ៗ ស្ដេចទតហង្សយន្តមាសថៃ សព្វព្រះហឫទ័យ ទិនជាង ទាំងពីរក្ដាត់ហោង ៗ ស្ដេចឲ្យរង្វាន់ជាងទន មាសប្រាក់កែវកង អនេកអនន្តគណនា ៗ ព្រះអង្គឲ្យយសសក្ដា ទាំងពីរស្មើគ្នា សឹង ជាចៅហ្វាយស្រុកស្រេច ៗ កាលនោះព្រះបាទសម្ដេច ព្រះអង្គ ស្ដែនះស្ដេច កឹគង់លើហង្សមាសថៃ ៗ ស្ដេចកើចខ្សែហង្សមាសថ្ងៃ ហៀវហោះវ័ងវៃ រូបហានរូបរស់វិញ្ញាណ ៗ កើចយន្តភាពផងហោះដៀន ហិចហើរមេឃមាន ប្រវ៉ាត់ឯអាកាសកង់ ៗ ខ្ទះឆ្ងៀនឆៀនឆាបព័ស្ដុផង ខ្ទះទំផ្អៀនផ្អន ចាប់ទូវបុប្ផាផលា ៗ ក្សិណនោះព្រះបាទក្សត្រា គង់យន្ត លីលា ស្ដេចផ្ដោះទៅព្រៃហិមពាន្ត ៗ សប្បាយលោះលាយដោយបាន ព្រះព្រៃហិមពាន្ត ច្រើនពណ៌អនេកគណនា ៗ ព្រះបាទប្រពាតព្រឹក្សា សម្រេចហើយណា ទើបស្ដេចឡើងគង់យន្តយាន ៗ ស្ដេចកើចខ្សែយន្ត វិលថ្កាន ទេពទិព្វពិមាន ប្រាសាទប្រសើរសោភា ៗ

## បទព្រហ្មគីតិ

ក្សណនោះរាជកុមារ រតនត្រកាលចក្រជា អ្នកទ្រង់ព្រះចិន្តា នឹងរក ព្រះមហេសី ៗ ជាបើអញបានយន្ត ហោះគយគន់សព្វទិសទី រករើសរាជ ទេពី ឲ្យបានដូចចិត្តប្រាថ្នា ៗ ទ្រង់ព្រះចិន្តាស្រេច ព្រះអង្គស្ដេចចរលីលា ទៅថ្កានព្រះមាតា ទូលបិតាទាំងពីរពង្ស ៗ អ្នកឱនព្រះសិរសី ក្រាប ជួញជិតលើកកំបង់ ដោមដាក់សិរសីផ្គង់ ថ្វាយបង្គំហើយទូលថា ៗ បពិត្រខ្ញុំក្រាបទូល ព្រះឥស្សរជាបិតា ដ្បិតខ្ញុំនឹងក្រាបលា បង់ទៅរក រៀនសិល្បសាស្ត្រ ៗ ខ្ញុំសូមហង្សយន្តណា នឹងយាត្រាដោយ អាកាស ទៅរកអាចារ្យចាស់ បេះរៀនចប់សិល្បសាស្ត្រសាយ ៗ ហើយខ្ញុំនឹងអាស្រ័យ ទីពឹងអ្នកជាបាធ្យាយ រៀនសូត្រសិល្បទាំងឡាយ ឲ្យបានដូចក្ដីប្រាថ្នា ៗ ឯព្រះបិតាស្ដាប់ បុត្រទូលតាមដោយធម៌ថា ស្ដេច យកយន្តនោះណា ឲ្យបុត្ររតនដូចបំណង ៗ ឯព្រះវរមាតា កែវឱន ផារសោកាជន់ផង ដាក់ក្នុងហង្សយន្តហោង រៀបដំណើររាជបុត្រា ៗ ពីពង្សព្រះមហាក្សត្រ ឱបបុត្ររតនហើយសោកា ទាំងពីរព្រះរាជា សឹង សោយសោកពិលាបលន់ ៗ ព្រះវររាជមាតា បន្ទូលថាឱកូនតន់ មាស អើយទុក្ខម្ដាយជូន ពីថ្ងៃនេះឯងហោងណា ៗ ឥឡូវម្ដាយនឹងឃាត់ ខាំងកូនរតនមាសពុំបាន ឲ្យខានពុំបានណា ក៏ម្ដាយថប់ថែពេកពន់ ៗ កូន អើយម្ដាយផ្ដាំបា បើយាត្រាដោយតំបន់ ចូរអ្នកមាសស្ងួនតន់ កុំ

ប្រហែលអន្តរាគ្នា ៗ កុំអ្នកគិតអាល័យ លែងដោយក្រពេកឡើយណា
សង្កាត់ឃាត់យាត្រា ឲ្យបានដល់ស្រុកទេសគេ ៗ មាសអើយម្តាយថប់
ក្រែង ខ្លាចវង្វេងពុំដឹងដៃ តំបន់ស្រុកទេសគេ ពុំបានដល់ដូចបំណង ៗ
បើបានដល់ស្រុកគេ កុំទុកយន្តនោះឡើយហោង ឲ្យអស់ទាំងមនុស្ស
ផង យល់ហង្សយន្តនោះឡើយណា ៗ មួយសោតៈបើបាន ទៅ
ដល់ឋានគ្រូអាចារ្យ បានរៀនសិល្បសាស្ត្រា បរិបូណ៌បានដូចបំណង ៗ
ចូរបោម្ចាស់ រួសក្រឡាប់វិលមកៈហោង កុំកូនស្ងួនស្នេហ៍ស្នង ទៅ
លង់ឡើយឯនាយណា ៗ អ្នកមាសចរចេញទៅ ម្តាយអ្នកនៅឯកកំព្រា
ឥតបើយល់អ្នកណា ក្រែងទឹងកូនពន្លកឡើយ ៗ ម្តាយគិត ៗ ទៅគ្រប់
គ្រប់ហើយថប់ ៗ ពុំស្បើយ នុកូនស្ងួនម្តាយអើយ អ្នកក្រឡាប់មកឆាប់
ណា ៗ ទុក្ខម្តាយធ្ងន់ដូចភ្នំ ជ្រុះរំលំលើទ្រូ សូមអ្នកឆាប់ម៉ឺម៉ា វិលវិញមក
ដោះទុក្ខម្តាយ ៗ ម្តាយផ្ទៃម្តាយផ្តាំផ្តិត កុំកូនគន់មាសពាយមាយ ទៅ
ហើយភ្លេចពាក្យម្តាយ នៅយូរលង់ក្នុងស្រុកគេ ៗ ទ្រូងម្តាយពេញសឹងទុក្ខ
ដូចគេប៉ុកពុំទំនេរ ដ្បិតកូនទៅស្រុកគេ ឥតអ្នកណាជាតីផង ៗ អ្នក
មាសស្ងួនគន់ម្តាយ រូបឆោមឆាយឥតឯគ្គង មាសអើយទើបតែម្តង នេះ
ម្តាយគឹងជាទុក្ខធ្ងន់ ៗ នាងនុននុបបុត្រា សោយសោកាពិលាបលន់
អាសូរកូនស្ងួនគន់ ដ្បិតទឹងចេញចាកឋានឆ្ងាយ ៗ ឯព្រះវរបិតា
នុបបុត្រក្សាត្រូវរូបឆោមឆាយ ទឹកព្រះនេត្រហូរខ្លាយ សស្រាក់ស្រោចព្រះ

កក្រោ ៗ ស្តេចទ្រង់ព្រះកន្សែង ហើយខំថ្លែងផ្តាំបុត្រា កូនអើយ
អាពុកបា ឥតទ្រព្យជាគ្រឿងការ ៗ ទីងឲ្យដំណើរបា បុត្រពុំអាកូនសង្សារ
មានតែពាក្យនេះណា អាពុកផ្តាំបាបុត្រថ្លៃ ៗ បាទៅឥឡូវណា ដោយ
វេហាស៍ផ្លូវក្រៃក្រ កូនកើបយន្តនោះនៃ កូនរំពៃគន់ប្រយ័ត្ន ៗ មាស
អើយឯអាកាស ផ្លូវវេហាសពុំដែលស្ងាត់ អសុរតែងរង្គាត់ ស្កាត់ទៅ
មកជាប្រក្រតី ៗ មួយសោតក្រែងគ្រុឌរាជ មានអំណាចមកយាយី រាំង
សត្វនាទី ហោះរង្គាត់ស្កាត់ទៅមក ៗ មួយសោតក្រែងឥន្ទ្រី ហើរ
យាយីរង់ក្រាប់ក ចុះចាប់ម្រឹគជងយក ជាអាហារបរិភោគ្គា ៗ
កូនអើយកុំបាធ្វេស កុំប្រហែសអង្គអាត្មា ប្រយ័ត្នឲ្យណាស់ណា
កុំបាភ្លេចណាកូនអើយ ៗ អាពុកបាថប់សល់ ឥតឯយល់អ្នក
ណាឡើយ ពីថ្ងៃនេះទៅហើយ តែងទីងស្ងាត់ឯងហោងណា ៗ
ក្រែងអ្នកទីងហោះធ្យាន ទៅហិមពាន្តឋានព្រឹក្សា បើបាយល់គុហា កុំ
កូនចុះចូលទៅជិត ៗ មាសអើយមានរាជសីហ៍ មានរិទ្ធិវៃតែងបិត
ជាឋានលំនៅនិត្យ ពឹងអាស្រ័យសត្វគុហា ៗ ចូរមាសមើលប្រយ័ត្ន
កុំកូនគេងធ្លោយឡើយណា ពោះយប់ទីងនិទ្រា បារគឈើណាគាប់គល់ ៗ
យកយន្តហង្សផ្គួផ្គាប់ បងឲ្យខ្ជាប់នាមណ្ឌល បាដេកជាសុខសល់ លើ
ហង្សយន្តនោះឯងណា ៗ មួយសោតកុំមាសថ្លៃ លេងដោយព្រៃព្រឹក្ស
អដ្ឋា ក្រែងសត្វផងពាធា កុំប្រហែសណាអ្នកអាយ ៗ បាបង្គំអាពុក

ទៅ អាពុកនៅឯងឯកាយ ស្មារតីធ្លូសកាយមាយ ឡើងឡន់ឡប់ថប់
ថៃសល់ ៗ ចូរអ្នកមាសសង្ឃាត ពោះវិឃាតឲ្យបានដល់ ទីឋាន
ទេពមណ្ឌល លំនៅគ្រូអាចារ្យផង ៗ បានរៀនសព្វសិល្បសាស្ត្រ អកិ
លាសដូចបំណង ស្រេចហើយបានវិលផ្គង ក្រឡាប់មកកុលង់ឡើយ ៗ
ឱកូនអាសូរពុំងា អាពុកជាទុក្ខពុំស្បើយ កុំបាយូរកូនអើយ រៀស
វិលវិញមកថ្វាត់ ៗ អាពុកអ្នកទីនឲ្យ បានឯងសោយរាជសម្បត្តិ ជា
ឥស្សរមហាក្សត្រ ទាំងឡាយឡើងយើងនេះណា ៗ ស្តេចឱបកដ
កុមារ ព្រះកូបាលស្តេចសោកា ផ្គាំកូនស្ងួនពុំងា ពិលាបលន់សោយ
សោកសល់ ៗ រីឯព្រះរាជា សោយសោកា ១ ណល់ សម្តេច
ព្រះទេសពល ក្រញ្ញក្រាបក្រោមព្រះបាទា ៗ ទាំងពីរព្រះអគ្គក្សត្រ បើប
បុត្រគេទំពជស្នេហា ហើយបុត្រទូញទូលថា ឱព្រះបិតាម្ចាស់ថ្លៃ ៗ កុំ
បីអម្ចាស់ខ្ញុំ ស្តេចបាម្តេព្រួយព្រះទ័យ ខ្ញុំទៅឥឡូវនៃ ពុំលង់ឡើយ
ណាអ្នកម្តាយ ៗ កូនអ្នកនឹងក្រឡាប់ វិលមកធាប់ណាអ្នកកាយ អម្ចាស់
នៅឯកាយ រួមគេក្រអគ្គគាត្តា ៗ អ្នកអើយកូនថប់ណាស់ ដ្បិតម្ចាស់
នៅកំព្រា តែពីរព្រះអង្គា ឥតឯយល់អ្នកណាឡើយ ៗ ហាក់ដូចកូន
ទុជិន ណាស់តែកពន់ណាអ្នកអើយ ឥឡូវខ្ញុំឯងនេះហើយ ទៅចោល
បង់អម្ចាស់ថ្លៃ ៗ ពាក្យអ្នកទាំងពីរផ្តាំ នោះកូនចាំ១ សព្វថ្ងៃ ជាក់ជា
អចិន្ត្រៃយ កូនកុំភ្លេចពាក្យអ្នកណា ៗ ក្សណោះនោះក្សត្របីអគ្គ

បន្ទាប់នឹងសោយសោកា សម្តេចព្រះរាជា រៀបដំណើរឲ្យបុត្ររតន៍ ៗ ឯព្រះរាជបុត្រា បង្គំលាពីរពីរក្សត្រ ស្តេចឲ្យពរបុត្ររតន៍ ចំរើនសួស្តី-មង្គល ៗ ឯអស់ទាំងអាមាត្យ មន្ត្រីជាតរត់មកដល់ សាយសព្វទាំងមណ្ឌល ជួយចំរើនពរជយា ៗ

បទមហាជយា

ជ័យ ៗ មហាព្រហ្ម សូមជួយរក្សា ចំរើនព្រះពរ ៗ
ជ័យ ៗ សម្តេចព្រះបារ–មីសូរឲ្យពរ សូមជួយរក្សា ៗ
ជ័យ ៗ ព្រះឥសូរ សូមអ្នកករុណា ចំរើនព្រះពរ ៗ
ជ័យ ៗ ពណ្ណរាយបវរ ជួយចំរើនពរ ព្រះរាជបុត្រា ៗ
ជ័យ ៗ សម្តេចឥន្ទ្រា សូមជួយរក្សា ព្រះរាជកុមារ ៗ
ជ័យ ៗ ទេពទាំងចក្រវាឡ ជួយចំរើនពរ បុត្ររតន៍ពុំងា ៗ
ជ័យ ៗ នាគីនាគា ថ្វាយពរជយា សុខសិរីទ្ធី ៗ
ជ័យ ៗ គ្រុឌរាជបក្សី ចំរើនសួស្តី ឲ្យពរមង្គល ៗ
ជ័យ ៗ យក្សយង់អសុរ ថ្វាយពរទេសពល ស្តេចលីលាចរ ៗ
ជ័យ ៗ ខុនពិទ្យាធរ ជួយចំរើនពរ ជ្រោមជ្រែងរក្សា ៗ
ជ័យ ៗ ទេសពលនេះណា ចំរើនជយា ទូវរិទ្ធិអានុភាពសព្វកាល ៗ

បទកុជន្តលីលា

នឹងថ្ងៃដំណែនដំណាល ព្រះសុវណ្ណកុមារ រតនរាជបុត្រា ៗ

ក្រញាញក្រាបបន្ទាបសិរសា ថ្វាយបង្គំលា ជនកជននី ។ ព្រះអង្គអ្នកទ្រង់សេរី ទទួលពរស្រី សុមង្គលគាប់ ។ ស្តេចទ្រង់គ្រឿងផ្ទង់ប្រដាប់ ព្រះអង្គស្រេចស្រាប់ គង់លើយន្តយាន ។ ស្តេចកើបខ្សែយន្តហោះឆក្រាន តាមអាកាសឋាន ហោះសំដៅឆាយណា ។ ព្រះបាទប្រពាតហោះសំឯកឯងរកជា តែមួយព្រះអង្គ ។ ក្រោកព្រាយចេតឆាយគ្រាប់គ្រង់ គ្រៃតជោមជុំ ដើរដោយហោះសំ ។ ស្តេចឆ្ពោះទៅឯព្រឹក្សា ហិមពាន្តទាយណា ជាសុខសប្បាយ ។ ស្តេចដល់មណ្ឌលព្រៃឆ្ងាយ ក្សត្រាតណ្ហកាយ ចរចុះសម្រាន្ត ។ ព្រះបាទប្រពាតហិមពាន្ត ព្រះអង្គក្សត្រក្សាន្ត ទតស្រះនទី ។ ព្រៃព្រឹក្សស្មោមស្មុកលាស់ខ្ចី ដុះដោយទួលទី រៀងរៀបស្រះស្រី ។ មើលមួប់ឧត្តមពិសី ទួលកំពង់ទី រីករាយសប្បាយ ។ គន្ធាពាតាជាត់ផាយ លេះលោយ លេចទៅមក ។ សត្វសត្វផ្គាត់ទៅមក ធ្មៀលធ្នាត់រេក ទៀងឆាបមច្ឆា ។ ឪនៃថ្ងៃសំដៃងពណ៌នា ឯអស់ព្រឹក្សា កំឡុងស្រះស្រី ។ ឈូកប្រាលរន្ទាលស្មើ ក្រពុំប៉ុប៉ី គន្ធាលូតលេច ។ ស្រទាប់ក៏ស្រោប់ស្រស់ស្រេច រុះរាយរដាច់ រគេតដោយទឹក ។ ជាសជឹតប្រកិតញាតញឹកលំពង់ស្មោមស្មុក លូតលាស់លាយផ្កា ។ ព្រលិតព័ន្ធព័ទ្ធលើគ្នា ជាសដោយគន្ធា ទ្រង់បុប្ផាផង ។ លំចង់ទ្រង់ផ្កាឥតគន្ធ ត្រកួនបោះទង កំពីងពួយព័ទ្ធ ។ សារាយស្មៅសាយពៃនព័ទ្ធ កញ្ឆែតពាវែណ្ឌ ពៃន

ពាក់ជ្រកជ្រៀត ។ គ្រាំធំប្រឡំត្រកៀត ដុះដាសសែមសៀត
លាស់លេចលើត្រឹប ។ ព្រឹក្សាខ្លះផ្កាខ្លះក្តិប ស្រទបស្រទាប់ រុះពេយដាស
ដាល ។ ស្រះស្រីទាទីជ្រៅជ្រាល សម្តេចភូបាល ចុះលេងគង្គា ។ ស្តែង
ស្តេចត្រេកត្រាច់លីលា ប្រពាតព្រឹក្សា ក្រសាលហឫទ័យ ។ កែវកោត
លៀបលោតលំានដ័យ ព្រីងព្រេចពោនព្រៃ ត្បូងភាពលខែ ។ ស្នែស្នាំ
ព្រាលព្រេចជ្រៃជ្រៃ ទន្សោងទន្សៃ ក្របក្រាយក្រវ៉ាន់ ។ ញញាសណ្តា
សណ្តាន់ រំលួរើកពារវ័ណ្ណ សោភសន្ទែធំ ។ ពពួលស្រស់ស្រួលសុក្រំ
ពេកពក់កំនិក្ខ ចារចន្ទន៍ក្រស្នា ។ គ្រើលក្រូងខ្លែងគង់ធំធា ទន្ទាប់ទន្ទា
ដង្កៀបក្តាមក្តុល ។ ទ្រុមសែងទ្រមែងទ្រមល់ ស្តីស្តៅស្តុកស្តុរ ក្លាស
ស្លោងស្លុលស្លាយ ។ ពន្រឹងកពងកពាយ រលួសរលាយ រលួសផ្អុងផ្អាវ
ពពេលស្លាបតែលខ្លឹងខ្លាវ បង្គៀបង្គាវ សម្បុរល្វែងល្វា ។ បេកទេស
កាកែសកណ្ណិកា ដង្កោកាំង៉ា ដុះដូចគេបារ ។ ស្ទឹកស្ទោមដើមដាម
សាខា ទ្រង់ផ្កាដោយពណ៌ ទីទៃនានា ។ ស្រលិតចំប៉ីចម្បា ក្រសាយ
សាខា ត្រសុំទៀងទាប ។ ដុះដោយជ្រុងជ្រោយទំនាប ផ្លេស្រះរំពេប
លំពង់លូតលាស់ ។ ស្ទឹកស្ទោមត្រសុំក្រែលក្រាស់ ដើមដុះធ្លុះធ្លាស់
ក្រពុំប៉ិចផ្កា ។ រុះពេយដាសដោយគាក កេសរបុប្ផា ធំធុំត្រឡប់ ។ ព្រះ
ពាយផាត់ផាយ ហាយសព្វ ហាក់ដូចអ្នកអប់ ទាំងព្រៃហិមពាន្ត ។ ចម្ប៉ា
ម្ទឹះលាក្លូតាន រំដេញមាសមាន រំដួលដុះដោយ ។ ខ្លះផ្កាប់ផ្កា រុះពេយ

ខ្ទះទើបផ្កាក្រោយ ក្រពុំប៉ុចខ្លី ។ មហាហង្សប្រយង្គមាលតី ប៉ុសនាគទ្រូង ស្រី ម្លិះរួតលខ្ទៃ ។ ផុះដេរដាសពេញហូរហៃ ខ្ទះរីកដូចតែ រំយោលរៀងពាយ ។ ហិមពាន្តទំហាទសប្បាយ វាលវែងលលាយ រលោងះស្រោងស្រឹង ។ សព្វសត្វប្រវាត់អឺអឹង គមពទ្រហឹង ត្រឹបកេសរផ្កា ។ ហែមហង្សប្រចាប់ចុងក្រឹស្នា ប្រកៀងគូវា ចឹកចាប់ផលផង ។ ពាំផ្កាក្រឹស្នាពាំងទង ហិចហើរត្រសង រកឈើទៀតទំ ។ ក្ដាំពាក់ត្រសក់ត្រសុំ ហង្សហើរទៅទំ លេងលើរុក្ខា ។ ប៉ោលតោកក្ងោកមាសណា ចាប់ចុងព្រឹក្សាតឹកល្បព្រឹក្ស ។ ដើមផងស្រោងស្រោងស្ដោមស្ទឹក បក្សីចាប់ចឹក បរិភោគផលផង ៗ សារិកាពេកធ្លៀងធ្អូង ហិចហើរត្រសង ចាប់ចុងកាកែស ។ ព្រឹក្សទ្រង់ផ្កាពិសេស ទ្រទន់ទ្រទេស បក្សីចឹកចាប់ ។ ឯសេកធ្មុកផ្ទោះធៀងធាប ទៅទំផ្អឹមផ្អាប់ ខែបទឹងសារិកា ។ កែវកល់យង់យល់សេកណា លះលែងព្រឹក្សា ផ្ទុកផ្ទោះហើរចេញ ។ សេកយល់ហើយហើរឃ្មោតខ្មាញ់ រកឈើទៀតវិញ ទន្ទាបទៀងទំ ។ ចម្ប៉ាសាខាត្រសុំ សារិកាទៅទំ ចាប់ចឹកបុប្ផា ។ លលកហើរមកម្ទីម្ទា ទៅទំពេក លើដើមរុក្ខា ។ សព្វសត្វធ្មៀលធ្មាត់ពេក ចាប់ចុងព្រឹក្សា ទំទាំងគូលេង ។ ខ្សៀវខ្វារច្ចេច្ឆាឥតក្រែង ត្រអាលអរឯង ដោយដើមព្រឹក្សា ។ ព្រះអង្គទ្រង់ស្ដេចលីលា ប្រពាតព្រឹក្សា ក្រសាលហឫទ័យ ។ ស្រាប់ស្រេចសម្ដេចជៀស្ឋជ័យ គន់យន្តមាសមៃ កើបហង្សហោះទៅ ។ ដល់ឋានពិមានលំនៅ

ស្រុកមួយនាមហៅ នគរបញ្ចាល ៗ មួយវេលានៅនោះណា មានព្រាហ្មណ៍ហោរា ចេះចប់ត្រៃវេទ ៗ ចេះធម៌ចេះសិល្បសាស្ត្រសែត ជាស្នងព្រះនេត្រព្រះបាទចក្រី ៗ ព្រាហ្មណ៍ព្រឹទ្ធតែងគិតសេចក្តី លោកាលោកិយ តម្រង់ក្សត្រថ្លៃ ៗ សម្តេចសពើជ្រៀតស្លដ័យ កើតយន្តមាសមៃ ចាប់ចុងព្រឹក្សា ៗ ឈើធំត្រសុំសាខា ខ្ពស់លើសលែងខា អស់ទាំងឈើផង ៗ ព្រះអង្គយកហង្សនោះហោង ផ្គួផ្គាប់ចាប់ចង សម្រេចហើយណា ៗ ក្សត្រក្សាន្តឈរលោនបាត ចុះពីព្រឹក្សា រៀងរូបដល់ដី ៗ ព្រះអង្គស្តេចទ្រង់ស្មើ កាន់ព្រះវិជន៍ មាលមាសសុវណ្ណ ៗ ស្តេចទ្រង់គ្រឿងក្ងង់សោភា អម្បៅផាត់នា ក្រចេះចួនចន្ទន៍ ៗ ព្រះភក្ត្រវិលក្ខណ៍សោភ័ណ ឃាក់ដូចព្រះចន្ទ ពាលពេញបូណ៌មី ៗ ស្រាប់ស្រេចសម្តេចចក្រី ព្រះអង្គចរលី ចូលកន្ទនគរ ៗ ព្រះបាទសីហនាទបេញចរ សម្តេចកូនរ ប្រពាតផ្កាផ្សប់ ៗ គន្ធផ្កាប្រការធងគ្រប់ ឈ្ញញ្ឆាយសាយសព្វ រៀងពល់រាទកយ ៗ ក្រមុំតូចធំទាំងឡាយ ដាក់ផ្កាសព្វសាយ ដុំផិតប្រក្រតី ៗ យល់អង្គស្តេចទ្រង់ស្មើ ស្រស់ស្រេចប្រិមប្រិយ លើសលែងប្រុសផង ៗ មេចមៀវឡើបខ្សៀវខ្សៀនផ្អង ទំងគ្នាឯងផង ស្ងួចឆ្លាលចរចា ៗ រើយៈមើលដំណើរផាយា កំឡោះនះណា ចំណាប់ពេកពន់ ៗ ស្រីផងផ្អៀងផ្អងយកគន់ មៀងមើលឥតធ្អន់ ដល់តិចឡើយណា ៗ ព្រះអង្គពួជពង្សក្សត្រា ស្តែងស្តេចលីលា ទឹមផ្ទះព្រាហ្មណ៍ហោង ៗ

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយអំពីល្ខោនស្បែក

អ្នកស្រី ពេជ្រ-សល់ រៀបរៀង

ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ហូតមកដល់រជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ គឺក្នុងពេល គ.ស. ១៨៥៩ មកដល់ គ.ស. ១៩២៧ នៅប្រទេសខ្មែរយើងមានល្បែងផ្សេង ៗ ប្លែក ៗ ជាច្រើន ដែលគេតែងនិយមលេងនៅជាន់នោះ ប៉ុន្តែដល់មកសម័យនេះ ល្បែងទាំងនោះ ខ្មែរយើងឈប់លេង ស្ទើរតែគេអ្នកណាស្គាល់គ្មាន តួយ៉ាងដូចល្ខោនស្បែក ដែលយើងហៅថាណាំងស្បែក ។ នៅសម័យនេះ ល្ខោនស្បែកនោះ គេឈប់លេងទៅហើយ គ្រាន់តែនៅមានគេចាំខ្លះ ដោយគេធ្លាប់បានឃើញមក ។

ហេតុនេះហើយ បានជាក្រុមជំនុំទំនៀមទម្លាប់ ខំស្រាវជ្រាវយករឿងនេះមករក្សាទុក ក្រែងអំណើះអំពីចាស់ ៗ ដែលបានចេះចាំនោះទៅ រឿងក៏វិនាសបាត់ទៅដែរ ។ ល្បែងនេះដូចមានសេចក្តីតទៅនេះ ៖

ល្ខោនស្បែកនេះ មិនមានលេងជាប្រក្រតីដូចល្ខោនធម្មតាទេ មានលេងមួយដងមួយកាលចំពោះតែមានពិធីបុណ្យធំ ៗ ដូចយ៉ាងបុណ្យចំរើនព្រះជន្ម និងបុណ្យថ្វាយព្រះភ្លើងជាដើម ហើយគេលេងតែរឿងរាមកេរ្តិ៍ ។

រូបភាពស្បែកដែលគេលេងនោះ គឺជាស្បែកគោ ឬស្បែកក្របី ដែលគេយកមកឆ្លាក់ទម្រង់ជារូបផ្សេងៗ ដូចជារូបព្រះនារាយណ៍ ព្រះឥសូរជាដើម របៀបឆ្លាក់ស្បែកនេះ ជាការពិបាកហើយយូរផង កាលបើគេឆ្លាក់បានជារូបហើយ គេយកទៅលាបពណ៌ខាត់ឡើងលើតាមរបៀប ទើបគេយកបន្ទះឫស្សីមកគាបសងខាង ធ្វើជាមេសម្រាប់កាន់ដើរទៅមកនៅពេលលេង រូបភាពស្បែកមានច្រើនយ៉ាងណាស់ មានរូបភាពស្វា រូប-ភាពហោះ រូបភាពប្រជុំពល រូបភាពជាក្បួនហែ ។ល។

ប៉ុន្តែក្នុងចំណោមរូបភាពស្បែកទាំងនោះ មានរូបភាព ៣ ជារូបភាពសំខាន់ជាងគេ គឺរូបព្រះឥសូរ ១ ព្រះនារាយណ៍ ១ និងឥសី ១ ដែលគេហៅថា "រូបភាពស្តេច" ឬថា "ស្បែកស្តេច" រូបទាំង ៣ ខាងលើនេះ កាលនឹងចាប់ធ្វើ ពួកជាងត្រូវកាន់ត្រណម ហើយចំពោះរូបព្រះ-ឥសូរ និងព្រះនារាយណ៍ គេត្រូវរើសយកស្បែកគោដែលស្លាប់ដោយអំពើខ្មោចព្រាយ ឯឥសីគេត្រូវយកស្បែកខ្លាធំ ឬខ្លាឃ្មុំមកធ្វើ ។ កាលនឹងចាប់ធ្វើរូបទាំងនេះ ជាងត្រូវស្លៀកពាក់ស ហើយត្រូវធ្វើក្នុងមួយថ្ងៃឲ្យហើយស្រេច ថែមទាំងមានរបៀបរណ្តាប់បូជាព្រះពិស្ណុការទៀតផង ។

រូបភាពស្បែកនេះ នៅពេលលេង គេត្រូវយកទៅបញ្ចាំងលើផ្ទាំងសំពត់សស្តើងទំហំប្រវែង ជា ៧ ឬ ១១ ហត្ថបួនជ្រុង ដែលចងសន្ធឹងនៅ

ខាងមុខរោង នៅខាងក្រោយផ្ទាំងសំពត់មានជើងក្រានមួយធំសម្រាប់ដុត ចន្លុះក្រាលបំភ្លឺ ដើម្បីឲ្យអ្នកមើលពីខាងក្រៅ ឃើញស្រមោលរូបភាព នោះ ។ ។

ហេតុនោះ ល្ខោនស្បែកនេះ គេលេងតែវេលាយប់ ដោយយកពន្លឺ ភ្លើងជាគ្រឿងផ្ចង់ បញ្ចាំង ។ គេជញ្ជូនកាពស្បែកនឹងគ្រឿងភ្លេងទៅរៀប ដាក់ក្នុងរោងនោះឲ្យហើយស្រេចតាំងពីវេលាថ្ងៃ ។ ដល់ពេលយប់ពួកអ្នក លេងទាំងប៉ុន្មាន គឺអ្នកចែក អ្នកចរចា គក នឹងពួកភ្លេងពិណពាទ្យក៏ទៅ ប្រជុំនៅរោងនោះដើម្បីលេង ។ មុននឹងចាប់លេងរឿង អ្នកលេងធ្វើពិធី ហោមរោងហៅ ៣ ដង ។

អ្នកក្រាបចន្លុះ អុចចន្លុះ ៣ ដើម ដើរប្រទក្សិណជើងចន្លុះ ៣ ជុំ ហើយឈ្នួលភ្លើងទៅលើគំនរអាចម៍ចន្លុះនៅក្នុងជើងក្រាន ចន្លុះក៏ឆេះឡើង អ្នកលេងគ្រប់គ្នា លុះធ្វើពិធីតាមទំនៀមចប់ហើយ ក៏ចាប់ផ្ដើមលេង រឿងស្វាសស្វាខ្មៅប្រចាប់គ្នា ។ នៅវេលានោះ គេឮសូរតែស្រឡៃនឹង ស្គរធំ ភ្លេងឯទៀតឈប់នៅស្ងៀម ។ តែដូនកាលគេមិនលេងរឿងស្វា ប្រចាប់គ្នាទេ គេលេងរឿងនាងមេខលា រាមសូរ ឬអជុន ដែលគេទុកជា រឿងចាប់ផ្ដាំខាងដើមរឿងដែរ ។

កាលលេងចប់បទហោមរោង នឹងផ្ដាំបើករោងហើយ គេក៏ចាប់លេង សាច់រឿងតទៅ ។

ចំណែកឯបទភ្លេងនោះ គេលេងដូចភ្លេងល្ខោនធម្មតា ប៉ុន្តែគេច្រើននិយមតែភ្លេងធំតូចដែលមានតែសម្ភោរ ១ ស្គរធំ ១ រនាត ១ គង ១ សាឡៃ ១ ទឹងឈឹង ១ ៗ ឯល្បែងល្ខោនស្បែកនេះ ក្នុងសម័យសព្វថ្ងៃ គេពុំសូវលេងទេ ដោយគេនិយមចូលចិត្តមើលល្បែងសម័យថ្មីទៅវិញ ។

× + ×

មានភាពល្ខោនស្បែកមួយយ៉ាងទៀត ដែលត្រូវលេងក្នុងវេលាយប់ ដោយបញ្ចាំងលើផ្ទាំងសំពត់សដែរ គឺណាំងតាលុង ដែលខ្មែរយើងហៅតែមាត់គ្រប់គ្នាថា អាយ៉ង ៗ ៗ ណាំងតាលុងនេះ មានរូបតែមួយ ៗ ប្រមាណប៉ុនកដៃប៉ុណ្ណោះ ប៉ុន្តែរូបនោះ គេធ្វើឲ្យកំរើកមាត់ដៃជើងបាន ហើយដោយអ្នកលេងចេះកំប្លែងផ្សេងៗ ក្មេងក្តី ចាស់ក្តី ចូលចិត្តមើលជាច្រើន ៗ ណាំងតាលុងមិនលេងរឿងកមកេរ្តិ៍ទេ ច្រើនលេងតែរឿងតូច ៗ ដូចរឿងព្រះជិនវង្ស រឿងព្រះសមុទ្រ ជាដើម ៗ ឯភ្លេងគេប្រើភ្លេងការក្សែដែលមានតែស្គរមួយ ចាប៉ី ១ ទ្រ ១ ឆាប ១ ទីងស្រឡៃ ១ ក្រែងសម្រាប់លេងណាំងតាលុងនេះតូចទេ ភាពស្បែកក៏តូច ផ្ទាំងសំពត់សក៏តូច អ្នកលេងក៏មានគ្នាតិច ហើយអ្នកលេងនិយាយរឿងហូរហែរតាមដំណើររឿង មិនមានអ្នកពោលជាពាក្យកាព្យដូចណាំងស្បែកទេ ៗ ដោយនៅមានមនុស្សចូលចិត្តមើលច្រើន ទើបនៅមាន

ណាំងតាលុងលេងកល់ឆ្នាំនៅព្រះរាជធានីភ្នំពេញ តែនៅមានលេងតែក្នុងព្រះរាជពិធីផ្សេង ៗ និងនៅពេលខ្លះដែលព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យឲ្យលេងដាក់តាំងដល់ប្រជារាស្ត្រ ។

ហេតុដែលខ្មែរយើងហៅណាំងតាលុងថា អាយ៉ង ៗ ទៅវិញ មកពីកាលក្នុងរជ្ជព្រះករុណានរោត្តម និងព្រះករុណាស៊ីសុវត្ថិ មានអ្នកលេងណាំងតាលុងម្នាក់ឈ្មោះ យ៉ង ប៉ិនប្រសប់កំប្លែងណាស់ អ្នកទៅមើលណាំងតាលុងចេះតែនាំគ្នាថា "ទៅមើលអាយ៉ង ទៅមើលអាយ៉ង" ឈ្មោះនោះ ក៏ជាប់មកទល់សព្វថ្ងៃ រហូតដល់ទៅមានអ្នកស្រុកខ្លះភ្លេចថា ល្បែងនោះឈ្មោះណាំងតាលុងទៅទៀត ។

ល្បែងនេះយើងពុំដឹងច្បាស់ថា មានមកតាំងពីកាលណា ឬបានចម្លងមកពីស្រុកណា ដោយពិតទេ ។ ប៉ុន្តែតាមសេចក្តីអធិប្បាយរបស់លោក René Nicolas ដែលពោលអំពីរឿងណាំងស្បែកនិងណាំងតាលុងសៀម មានសេចក្តីថា បានជាគេហៅណាំងតាលុង ព្រោះភាពណាំងបែបនោះ អ្នកស្រុកប៉ាតាលុងក្នុងប្រទេសថៃបានយកពីប្រទេសជ្វាមកលេងជាដំបូង ។ លោកបានពោលទៀតថា នៅភាគប្រទេសថៃ ក៏មានលេងណាំងដែរ ថា ណាំងនោះគេបានចម្លងមកពីស្រុកជ្វា នៅស្រុកជ្វាគេហៅថា "វ៉ាយ៉ាំង" ហើយថាជ្វាក៏បានចម្លងមកពីប្រទេសឥណ្ឌាទៀតដែរ ។ នៅប្រទេស

ជ្វាមានល្ខោនស្បែកនេះពីរបែប មួយបែបមានជារូបភាពដាច់ ៗ គ្នា មួយបែបទៀត ដែលជ្វាហៅថា "វ៉ាយ៉ាងបេបែរ" គឺមានភាពស្បែកធំជាតួមនុស្សអង្គុយ ឬរោះ ជាភាពប្រជុំពល ៗ ល ៗ ដូចជាល្ខោនស្បែកហើងពិត ៗ ឯរបៀបធ្វើពិធីហោមរោង របៀបលេង មានអ្នកពោលរឿងទៀតក៏ដូចគ្នា ៗ ឃើញដូច្នេះ យើងអាចសន្និដ្ឋានបានថា ខ្មែរចម្លងភាពល្ខោននេះមកពីប្រទេសឥណ្ឌៀ អំពីជ្វា ព្រោះមានទំនៀមជាច្រើនទៀតរបស់ខ្មែរ ដែលក្លាយមកពីឥណ្ឌៀ ពីជ្វា ដូចជារឿងរាមកេរ្តិ៍មកពីឥណ្ឌៀ រឿងអេណាវមកពីជ្វា ៗ

សព្វថ្ងៃនៅប្រទេសកម្ពុជា គេមានរក្សាភាពស្បែកនេះទុកនៅឡើយ នៅក្នុងឃុំព្រះកដច្រេញ ឯការទម្លុះស្បែកជារូបភាពផ្សេង ៗ ល្អ ៗ មាននៅក្នុងខេត្តសៀមរាបនៅឡើយ កាលតាំងពិព័រណ៍អន្តរជាតិឆ្នាំ ១៩៥៦ គេបានអាំងនាំយកអ្នកជំនាញការឆ្លាក់ស្បែក មកធ្វើបង្ហាញដល់បរទេសផង ៗ ជាងឆ្លាក់មិនឆ្លាក់ត្រឹមតែភាពល្ខោនស្បែក ឆ្លាក់ធ្វើជាគំរបចង្កៀងតាំងផ្ទះជារូបល្អ ៗ សម្រាប់ព្យួរនៅជញ្ជាំងផ្ទះផង ៗ

# ការវាងវៃនៃបបក

ភិក្ខុ ម៉ែន-រៀម រៀបរៀង

ត្រូវគារវៈអារ្យជនដោយប្រតិបត្តិ
គួរកំចាត់ជនក្លៀវក្លាដោយទំលាយ
ជនថោកថយដោយឲ្យវត្ថុកាយ (១)
សត្រូវស្មើកាយត្រូវកំចាយដោយអង់អាច ។

## ដំណើររឿង

បទព្រហ្មគីតិ

ដើម្បីថ្លែងបញ្ជាក់ ភាសិតដាក់នៅខាងលើ ខ្ញុំសូមប្រែសេរី ពីដំណើររឿងបបក ។ ដកចេញពីសំស្ក្រឹត តាមច្បាប់ពិតខ្ញុំរៀនមក ជាបែបគួររៀនយក ប្រៀបធៀបរកសុខឲ្យប្រាណ ។

ដំណាលពីបបក មួយនៅជ្រកព្រឹក្សស្ថាន ជាសុខស្រួលក្សេមក្សាន្ត មានឈ្មោះថា « បតុរកៈ » ។ ថ្ងៃមួយវាយាត្រា ស្វែងអាហារតាមចិត្តស្ម័គ្រ ជាលាភបតុរកៈ បានជួបជាក់ដំរីមួយ ។ គាយហោងនៅក្នុងព្រៃ អពោកក្រែតតតិតព្រួយ បបកដើរមួយៗ ប្រទក្សិណដំរីស្លាប់ ។ ប៉ុន្តែវាមិនហ៊ាន ទីងទំលាយស្បែកឲ្យធ្លាប់ ព្រោះស្បែកនោះសែនជាប់ ដូចយើងធ្លាប់ដឹងស្រាប់ ។

(១) វត្ថុកាយ=វត្ថុមិនមែនជាដុំកំភួន, វត្ថុបត្តិបវត្ថុ ។

ពេលនោះមានរាជសីហ៍ ចរណាលីដោយស្វាហាប់ ស្វះស្វែងដើររកចាប់ - សត្វស្រាប់តែដល់ទីនោះ ។ ចចកឃើញកាលណា ព្រួយចិត្តភ័យផិតពោះ ទើបវៃបែរមុខ ត្ពាះ ស្តីពេះទៅសីហា ។ បពិត្រលោកអារ្យៈ ចាំឯកអគ្គលើម្រឹគា ខ្ញុំនេះជាតាសា អារក្ខាបាទម្ចាស់ៗ ស្វះស្វែងរកអាហារ ជួបគជសារចិត្តអរណាស់ បំរុងទុកជូនម្ចាស់ ដើម្បីផ្សះក្តីស្រេកឃ្លាន ។ បើម្ចាស់មកដល់ហើយ កុំកន្តើយសូមប្រោសប្រាណ ទទួលដោយរាប់អាន ទានចំណានពីតាសា ។

រាជសីហ៍មានចិត្តអរ ថ្លែងអំណរតបវិញថា ចចកចូរប្រាប់ការណ៍អញនេះណាជាស្តេចម្រឹគ ។ មិនដែលស៊ីសត្វណា ដែលតាសាជូនល្ងាចព្រឹក ពោះបើឃ្លានពន្លឹក ដាច់បាយទឹកក៏មិនខ្វី ។ អញស៊ីតែសត្វណា ដែលប្រហារដោយរាជសីហ៍ ខ្លួនឯងនេះទើបអញពី ស្វាប់ថ្វាឆ្ងាញ់ពីសា ។ តែឯងជូនអញហើយ ចចកអើយអញជ្រះថ្លា ប្រគល់ឯងវិញក៏ ចូរភោក្តាម្នាក់ឯងចុះ ។

ចចកឮដូច្នោះ បាត់ផិតពោះលែងទញ្ញគុះ រៀបពាក្យមិនឲ្យខុស ស្តីពេះតបវិញថា ។ ចរិយានេះសែនឆើត សមកំណើតអគ្គរាជា ជាធំក្នុងព្រៃក្បា ឥតសត្វណាប្រៀបស្មើបាន ។

រាជសីហ៍ស្តីរួចស្រេច តែគេចបាត់សាតដាន ក្នុងទីរហោស្ថាន តាមលំនាំស្វែងអាហារ ។ ក្រោយសីហាទៅបាត់ ខ្លាមួយធាត់ធំអស្ចារ្យ

ចចកឃើញតក្កមា ព្រួយចិន្តាខ្លាចក្ស័យប្រាណ ។ វាគិតថាពជសីហ៍ កាចអប្រិយអញបោកបាន ទៅបាត់មិនប៉ុន្មាន ខ្លាក្លាហានមកដល់ទៀត ។ ម្ដងនេះអញលេងខ្លា តាមប្រាជ្ញាឲ្យរបាលមៀត កុំឲ្យវាជ្រៀតបៀត តាមស្មៀតគឺត្រូវទំលាយ ។ គិតស្រេចបនចចក បែរមុខរកខ្លាកែកាយ ចរចាដោយពក្រាយ ពាក្យលែបខាយស្ដីទៅថា ។

បពិត្រលោកតាស្វៈ សូមជ្រាបជាក់សភាពការណ៍ ដំរីនេះឯងណា ស្លាប់ដោយស្នាដៃពជសីហ៍ ។ ប្រើខ្ញុំឲ្យរក្សា លោកយាត្រាទៅនទី ដំរះ កាយឥន្ទ្រិយ រួចទើបស៊ីជាខាងក្រោយ ។ ពេលទៅលោកបានប្រាប់ ឲ្យ ខ្ញុំស្លាប់កុំឲ្យឆ្ងាយ ថាឯងកុំបណ្ដោយ ឲ្យអ្នកណាមកស៊ីបាន ។ ព្រោះ ដៀតពីថ្ងៃមុន អញឆ្ងាយស៊ីនខុសមួយបាន សំឡាប់ដំរីបាន ខ្លាក្លាហាន ចូលមកស៊ី ។ ស៊ីក្បាលដំរីអស់ រួចវាផ្ទោះចេញបាត់ទី ដោយសារអញ វក់វី ក្នុចសម្ដីថៃរក្សា ។ ធ្វើសាច់ឲ្យជាដែល នៅសល់ក្រែលឲ្យសីហា អញក្ដៅចិត្តខ្លាចផ្សា នឹងខ្លោចកាខ្លាចដ្រៃ ។ អញត្រូវតែបំផ្លាញ ខ្លា ឲ្យលាញអស់ពីព្រៃ សំឡាប់ឲ្យក្ស័ណក្ស័យ ឲ្យស្គាល់ដៃពជសីហា ។ ដូច្នេះប្អូនចចក បើខ្លាមកត្រូវយាត្រា ទៅប្រាប់អញឆាប់ពី ដោយវាថា ដ៏ស្ងប់ស្ងាត់ ។

ចចកស្ដីរួចស្រេច វាគេចមុខធ្វើមធ្យ័ត ប្រាប់ខ្លាពីវិបត្តិ ឲ្យខ្លាខ្វាត់ ដោយថែមថា ។ ខ្ញុំគិតខ្លាចលោកស្លាប់ ខ្ញុំមិនប្រាប់ហេតុការណ៍ ដែល

លោកបរយាត្រា ឲ្យសីហាដឹងខ្លួន ។ ដូច្នេះជាបណា រាជសីហានៅ ឯព្រៃ - ស៊ូងនោះត្រូវលោកបរ កុំទំនេររត់ឲ្យឆាប់ ។ ទើបរួចជីវិតបាន បើមិនចក្ខានមុខតែស្លាប់ ដូច្នេះសូមប្រញាប់ ផាយឲ្យបាត់កុំបង្អង់ ! ។

ខ្លាភ្ញាក់ភ័យខ្លាំងណាស់ ស្ទើរហើសមិនការង់ ក្ដួយអើយខ្លួនមាលង់ ដោយក្ដីល្ងង់មិនជ្រាបការណ៍ ។ សូមក្ដួយជួយមាជង ឲ្យបានចុងមរណា សូមកុំប្រាប់សីហា មាសុំលាក្ដួយសិនហើយ ! ។ លាក្ដាមខ្លាផាយក្ដុក លឿនត្រដែតតតយើតឡើយ ដោយសារភ័យឥតស្បើយ មិនព្រងើយវា គេចបាត់ ។

ចចកសែនរីករាយ មុខពព្រាយព្រោះខ្លាខ្លាត ដោយប្រុះជួវកំបាត់ ផុតវិបត្តិជីវិតវា ។ លេចមុខឯពានរ មួយមកឈរជ្ជរេក ចចកឃើញបង ស្វា ត្រិះរិះថាបងស្វានេះ ។ វាមានធ្មេញមុតល្អ ត្រូវអញលដោយ បំណោះ បំភាន់ដោយបញ្ឆោះ ឲ្យស្វាគ្រេះហែកដំរី ។ គិតហើយវា ញញឹម មុខបំប្រឹមចេញសំដី ក្ដួយអើយចុះហេតុអ្វី ស្មៀមវាហីមុខ ក្រៀមម៉្លេះ ? ។ មាខានឃើញយូរហើយ នែក្ដួយអើយចូលមកណេះ ក្ដួយឯងបេះតែវេះ មាឯនេះចេះតែនឹក ! ។ មើបទៅគ្រួសារយើង មា នឹកឡើងសែនរពុក សុខទុក្ខពេលល្ងាចព្រឹក រៀងបាយទឹកយ៉ាងណា ទៅ ? ។ មាមើលទៅមុខក្ដួយ ថែបដូចព្រួយចិត្តមួម៉ៅ ឃ្លានបាយឬ

ទឹកហៅ? កុំសោកសៅហ្មងអី? ។ ជារបស់នៃកេសរ លោកប្រើមាមក់ ចាំទទ់ រក្សាដោយសម្ដី ក្មួយឯងស៊ីមួយផ្អែតចុះ! ។ កុំភ័យកុំបារម្ភ ក្មួយឯងនឹងឲ្យពេញពោះ ផ្អែតហើយសឹមវិលផ្ទះ ទៅគោះក្បៀកដេកសប្បាយ ។ ចំណែកឯខ្ញុំមា ចាំការពារពីចម្ងាយ បើលេចឃើញរូបកាយ សីហាផាយមកមាប្រាប់ ។

ពានរឮដូច្នោះ ក៏យញ័រពោះឆ្លើយប្រញាប់ អៃយ៉ា! ស៊ីហើយស្លាប់ ឃ្លានជិតឆាប់គំម៉ិនដែរ ។ លោកពូសូមមេត្តា កុំវាចាឲ្យក្មួយប្រែជាទុក្ខដោយសារតែ តែពីរឿងដែលស៊ីលន់ ។ ព្រោះគាស់តពោលថា ក្តីសុខាបានគង់វង់ ព្រោះមានជីវិតគង់- ទ្រង់លង់យូរពប់រយឆ្នាំ ។ ដូចជានាងសីតា ជួបភស្ដាគួរប្រចាំ ព្រោះនាងរស់យូរឆ្នាំ តាមចំណាំអាយុវែង ។ ហេតុនេះខ្ញុំមិនអាច ធ្វើល្ហល្ហាចឥតគិតក្រែង ដឹកនាំខ្លួនប្រាណឯង ឲ្យគម្ដែងពជសីហ៍ឡើយ ។

ចចកបន្ទិស្ដា ដោយវាចាថាក្មួយអើយ! មានៅជិតបង្កើយ កុំព្រួយឡើយមាការពារ ។ កាលណាពង់សីហ៍មក មាលែលកឲ្យទាន់ការ ប្រាប់ក្មួយឲ្យយាត្រា ផុតមរណាដោយសុខសាន្ត ។ ហេតុនេះក្មួយកុំភ័យ មិនក្សយទេកុំខកខាន បរិភោគឲ្យស្កប់ប្រាណ ទើបយើងមានកំឡាំងដែរ ។

ចចកបន្ទំខ្លាំង ស្ទាក់កាំងព្រោះគ្នាល្មើ ស្មានថាគេអើពើ មក លើខ្លួនដោយពិត ៗ ក៏ផ្តើមហែកទំលាយ ស្បែកឲ្យធ្លាយបានដូចចិត្ត ប្រាថ្នាខិតចូលជិត ដោយប្រុងគិតស៊ីឲ្យឆ្អែត ៗ ចចកឃើញដូចចិត្ត សាច់ប្រណីតក្រហមឆ្អែត វាមិនបានបណ្តែត - បណ្តោយឲ្យស្វាស៊ីទេ ៗ ទើបស្រែកបំភ័យថា ខែក្អួយស្វាចូរិះរេ ផាយទៅកុំទំនេរ ព្រោះម្ចាស់គេមកវិញហើយ ៗ ផាយទៅឲ្យប្រញាប់ រត់ឆាប់ៗកុំព្រងើយ តែឃើតផុងខ្លួនហើយ ទុក្អួយអើយគិចលោស្ទាប់ៗ

សន្តានចិត្តបងស្វា យើងរាល់គ្នាដឹងត្រាប់ គាត់នេះភ័យខ្លាចឆាប់ សត្វអក័ត្បគេបោកប្រើ ៗ ត្បថាពជស៊ីហ៍មក ស្ទុះលាន់ព្រក(១) លឿនដូចហោះ ផាយបាត់ឥតលាគ្នើ ធ្វើដំណើរបាត់ទៅអីយ ៗ

---

(១) ពាក្យត្រឹមត្រូវ គឺ ព្រោក វិញទេ ។

ចប់

x x x

# កណ្ឌទី ៣៦

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

បើសំបុកនោះធ្លុះធ្លាយអន្តរាយទៅវេលាណា ពងនោះក៏ត្រូវធ្លាក់បែកទៅវេលានោះ មិនអាចនឹងគង់នៅបាន ដូចបិតាយើងដែលដល់នូវសេចក្ដីស្លាប់ ដោយសារទោសគ្រោះនេះ ខ្លួនយើងជាបុត្រនឹងរើរត់ឲ្យផុតទៅបាន ថាដូច្នោះ មិនទាន់ផុតមាត់ ទទួលទាហានចូចូចូលមកព័ទ្ធជុំវិញផ្ទះ ចូលចាប់យកបុត្រនឹងភរិយាខុងយុងទាំងអស់គ្នា ទៅជូនចូចូ ។ ក៏ឲ្យយកទៅប្រហារជីវិតអស់គ្មានសល់ ហើយឲ្យយកសពខុងយុងទៅដោតផ្ចាលនូវផ្លូវបំបែក មិនឲ្យមនុស្សនាំគ្នាយកជាតួយ៉ាងតទៅទៀត ។

ខណៈឈីស៊ុប ដែលជាសំឡាញ់គ្នានឹងខុងយុង ដឹងថាចូចូឲ្យយកសពខុងយុងទៅផ្ចាលដូច្នោះ ក៏ដើរទៅមើល ឃើញសពហើយ ក៏

ទបទ្ទួញយំអាណិត មានមនុស្សឃើញ ក៏ទៅប្រាប់ចូឆ្វ ៗ ខឹងណាស់ បង្គាប់ពាហានឲ្យទៅចាប់យកខ្លួនឈីស៊ុបទៅសម្លាប់ចេញទៀត ៗ ស៊ុនហុកក៏និយាយទន់ចូឆ្វថា ដែលលោកនឹងឲ្យយកខ្លួនឈីស៊ុបទៅសម្លាប់ទៀតនោះមិនគួរទេ ព្រោះឈីស៊ុបនេះជាមនុស្សស្រឡាញ់រាប់អានគ្នានឹងខុងយ៉ុងក៏មែន តែជានឹងបានដឹងឃើញចិត្តជាមួយផងនឹងខុងយ៉ុងក៏ទេ ពីដើមក៏បាននិយាយរំពុកខុងយ៉ុងថា ខ្លួនខុងយ៉ុងជាមនុស្សអាក្រក់គាបសាហាវគ្មានអធ្យាស្រ័យសោះ បើប្រព្រឹត្តដូច្នេះយូរទៅ នឹងមានភ័យដល់ខ្លួន ឈីស៊ុបនិយាយដូច្នោះ ខ្ញុំបាទក៏បានឮនឹងត្រចៀក ដែលមកទ្ទួញយំអាឡោះអាល័យខុងយ៉ុងនោះ ព្រោះគិតថាជាមិត្តភក្តិនឹងគ្នា ៗ ចូឆ្វបានស្តាប់ក៏សោយកំហឹង ទើបឲ្យឈីស៊ុបយកសពខុងយ៉ុងទៅបញ្ចុះតាមត្រូវការ លុះចូឆ្វសម្លាប់ខុងយ៉ុងចេញដូច្នោះហើយ ក៏ចាត់ឲ្យស៊ុនហុកទៅរក្សាស្រុកហ៊ូគោ ហើយបើលើកទ័ព ៥០ ម៉ឺន ទៅវាយស្រុកស៊ុនគៀ ៗ ទទួលឡៅប៉ៀវហៅហាយស្រុកកេងដីវឈើធូនថែមម្ដងទៀត ក៏ឲ្យហៅឡៅពីចូលទៅប្រាថ្នានឹងផ្ដាំផ្ញើការរាជការទាំងពួង ៗ ឡៅពី, គួនអ៊ូ, លៀវហ៊ុយ ក៏នាំគ្នាទៅរកឡៅប៉ៀវឯស្រុកកេងដីវ ៗ

ឡៅប៉ៀវឃើញមុខឡៅពីត្រេកអរណាស់ ក៏និយាយថា ខ្លួនយើងសព្វថ្ងៃនេះ ដូចដើមឈើក្បែរប្រាំងរាប់ថ្ងៃខែតែនឹងរលំចុះ ដែលយើងឲ្យហៅប្អូនមកនេះ ប្រាថ្នានឹងផ្ញើស្រុកកេងដីវឲ្យប្អូន ព្រោះកូនបងទាំង

២ នាងជម្រះប្រាជ្ញាទន់ខ្សោយណាស់ ប្រសិនបើ បងអស់បុណ្យក្ស័យទៅ ហើយ កូននោះនឹងរក្សាស្រុកទេសបានដោយក្រក្រៃពេកណាស់ ខ្លួនប្អូនជាចាស់ មានជម្រះប្រាជ្ញា ចូរជួយរក្សាស្រុកទេស កុំឲ្យអន្តរាយបានទៅអ្នកដទៃឡើយ ។

ឡៅពីបានស្ដាប់ក៏ទទួលគំនាប់ហើយយំសោកាឆ្លើយថា ខ្លួនខ្ញុំបាទសព្វថ្ងៃនេះ មានសេចក្ដីសុចរិតត្រង់នឹងលោក ដោយផ្ទៃកតញ្ញូមិនបានប្រាថ្នាការអ្វីសោះ ទោះបីលោកអស់បុណ្យទៅហើយក្ដី ខ្ញុំបាទនឹងជួយទំនុកបំរុងកូនលោកទាំង ២ តទៅ ។ កាលឡៅបឿននិយាយផ្ដែផ្ដាំគ្នានឹងឡៅពីមិនទាន់ផុតមាត់ មានបំរើសេះម្នាក់ចូលមកជំរាបថា កងទ័ពចូចូលើកមកដល់ហើយៗ ឡៅពីក៏លានាំគួនអ៊ូ,ទៀវហ៊ុយ ត្រឡប់ទៅស្រុកស៊ុនអៀវិញ ។

ឯឡៅបឿនបានឮដំណឹងសឹកសង្គ្រាមមកដល់ដូច្នោះ ក៏រឹតតែតក់ស្លុតខ្លាំងឡើងទៀត ជម្ងឺនោះក៏កាន់តែធ្ងន់ចុះ កាលឡៅបឿនបរបាផ្ដែផ្ដាំឡៅពីនោះ នាងឈួហ៊ូយជាភរិយាឡៅបឿនលបស្ដាប់ដំណើរទាំងអស់ ក៏នឹកខឹងខ្លាំងណាស់ថា ឡៅបឿនស្រឡាញ់រាប់អានឡៅពីច្រើន ដល់លើកស្រុកទេសប្រគល់ឲ្យឡៅពី មិនមានសេចក្ដីអាណិតដល់បុត្ររបស់ខ្លួន ទើបឲ្យឈួម៉ីនិងទៀវអ៊ុនទាំង ២ នាក់ជាទីទុកចិត្ត ឲ្យនៅរក្សាទ្វារផ្ទះ កំដាប់ត្រួតត្រាមិនឲ្យនរណាម្នាក់ ចូលមក-ចេញបាន ។

ឯឡៅគីជាបុត្រឡៅបឿន ដែលទៅឈរស្រុកកាំងហេនោះ លុះ

ឮថាបិតាឈឺធ្ងន់ក៏ស្រូតរូតទៅសួរ លុះឡើងទៅដល់មាត់ទ្វារ ឈួម៉,ទៀវអ៊ុន ឃាត់ហាមមិនឲ្យឡៅគីចូលទៅជួប ថាខ្លួនអ្នកនេះបិតាប្រើឲ្យទៅឈររក្សាស្រុកកាំងហៃ ហើយមិនបានហៅឲ្យមកទេ ដែលអ្នកមកពេលទីកន្លែងដូច្នេះ ប្រសិនបើស៊ុនគ្វនដឹង ទ្រង់លើកទ័ពមកវាយយកស្រុកកាំងហៃនោះជាអសារឥតការ មួយទៀតបិតាអ្នកឈឺធ្ងន់ បើអ្នកនឹងចូលទៅឥឡូវនេះ ក៏ឃើញថាបិតាអ្នកនឹងខឹងថាលះបង់ទីកន្លែង ពេលនោះក៏នឹងជាស្លុងឡើងទៀតៈ លើសកំឡាំង គង់នឹងដល់សេចក្តីស្លាប់ ដូចជាអ្នកមកធ្វើឲ្យបិតាអ្នកអស់ជីវិតឆាប់ទៅទៀត ។ ឡៅគីបានស្តាប់ដូច្នោះ ក៏អង្គុយយំសោកអាណិតបិតាណាស់ នៅតែពីក្រៅទ្វារ នឹងចូលទៅសួរគេពុំបានហើយក៏ឡើងសេះត្រឡប់ទៅស្រុកកាំងហៃវិញ ។

ឯឡៅប៉ៀវកាន់តែឈឺជាប់ គាំងចិត្តគិតដល់ឡៅគីជាបុត្រច្បងមិនឃើញចូលមក លុះដល់ខែភទ្របទ ៣ កើត រោគកំរើកខ្លាំងស្រែកបានតែពាក្យ ១ មាត់ ក៏ដាច់ខ្យល់ស្លាប់ នាងឈួហ៊ូយិនឃើញថាឡៅប៉ៀវមរណភាពហើយ ក៏ឲ្យឈួម៉ទៀវអ៊ុនចូលទៅសរសេរសំបុត្រ ជាបណ្តាំឡៅប៉ៀវទុក ១ ច្បាប់ សេចក្តីថា បើប្រសិន យើងអស់បុណ្យវាសនាកាលណា ត្រូវឲ្យឡៅចងទទួលរក្សាខេត្តស្រុកកេងជីវតទៅចុះ នាងឈួហ៊ូយិនក៏ឲ្យហៅនាម៉ឺនមុខមន្ត្រីចូលមកប្រជុំប្រឹក្សាគ្នា ហើយយកសំបុត្រនោះចេញមកបង្ហាញមន្ត្រីទាំងអស់មើល រួចក៏តាំងឡៅចងឡើង

ជាចៅហ្វាយស្រុកគេទីជំនួសបិតា ហើយទើបចាត់ចែងតែងការសេព
ឡៅប៉ៀវតាមប្រវេណី ។

ខណៈឡៅចង់អាយុបាន ១៤ ឆ្នាំ មានដម្រេះប្រាជ្ញាឆ្លៀវឆ្លាត
ណាស់និយាយនឹងមន្ត្រីខ្ញុំពជការពាំងពួងថា បិតាខ្ញុំមរណភាពទៅហើយ
ឡៅពីជាមាខ្ញុំ នឹងឡៅគីជាបងក៏នៅមានជីវិតរស់នៅឡើយ ដែលអ្នក
កល់គ្នាមកតាំងខ្ញុំជាធំនោះមិនគួរទេ បើប្រសិនឡៅពី នឹងឡៅគីដឹងនឹង
មានសេចក្តីតូចចិត្ត លើកកងទ័ពមកធ្វើអន្តរាយយើង អ្នកទាំងពួងនឹង
រិះគិតប្រការម្តេច ? ។ លឺគុយដែលជានាម៉ឺនខាងក្រសួងរដ្ឋបាលឆ្លើយថា
ដែលលោកមានប្រសាសន៍នេះគួរណាស់ ត្រូវតាមទំនៀមទម្លាប់ច្បាប់
ប្រវេណីពីបុរាណមក ហើយឲ្យអញ្ជើញឡៅពីមកជួយរិះគិតការក្សាស្រុក
ទេស នឹងបានជួយគ្នាការពារស៊ុនគួនឌីងប៉ូធ្លូតទៅ ។

ឈួម៉បានឮដូច្នោះ ក៏ស្រែកគំហកឲ្យលឺគុយថា ឡៅប៉ៀវជិតស្លាប់
បានសរសេរសំបុត្របណ្តាំជាសំគាល់ទុកថា យើងពល់គ្នាសុទ្ធតែជាមន្ត្រី
ធំ ត្រូវជួយគ្នារិះគិតទំនុកបំរុងស្រុកទេសបុំណ្ណោះមិនបានឬ ? ចាំឲ្យមាន
សំបុត្រទៅអញ្ជើញឡៅគីឡៅពីមកប្រយោជន៍អ្វី ? អ្នកទាំង ២ នោះមាន
ដំរេះប្រាជ្ញាយ៉ាងណាទៅ ? ។ លឺគុយឮដូច្នោះក៏ទាល់គំនិតស្រែកដេរឈួម៉
ថា ឯងជាមនុស្សមិនមានអធ្យាស្រ័យអ្វីសោះ មិនធ្វើតាមទំនៀមទម្លាប់

(នៅមានត)

## ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

# ពិធីប្រគេនព្រហ្មទានចំពោះសមណនិស្សិត

លោក ភ៉យ-ប៊ុក រៀបរៀង

កាលពីថ្ងៃសៅរ៍ទី ១៦ និងថ្ងៃអាទិត្យទី ១៧ ឧសភា ១៩៥៩ សមាគមមិត្តពុទ្ធិកវិទ្យាល័យ បានធ្វើពិធីបុណ្យព្រហ្មទានមួយ ចំពោះសមណនិស្សិតចំនួន ៤០ រូប ដែលបានចូលសិក្សានៅពុទ្ធិកមហាវិទ្យា-ល័យព្រះសីហនុរាជ តាំងពីថ្ងៃទី ៨ ឧសភា នៅឯពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ថ្ងៃសៅរ៍ទី ១៦ ឧសភា ១៩៥៩ ពេលម៉ោង ៧-៣០នាទី ពួកពុទ្ធ-មាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ បាននិមន្ត-អញ្ជើញមកជួបជុំនៅឯពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ខាងបព្វជិតមានសមណនិស្សិតពុទ្ធិក-មហាវិទ្យាល័យព្រះសីហនុរាជទាំង ៤០ រូប ខាងគ្រហស្ថមានលោក ភ៉យ-លុត ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ លោក ភ៉យ ប៊ុក ប្រធានសមា-គមមិត្តពុទ្ធិកវិទ្យាល័យ និងអស្សរជនឯទៀតជាច្រើន ។

ពេលម៉ោង ៨ យប់ បាននិមន្តសមណនិស្សិតទាំង ៤០ រូប ចម្រើនព្រះបរិត្ត លំដាប់តមកព្រះមហា ប៉ាង-ខាត់បានសំដែងធម៌ទេសនា លុះចប់ធម៌ទេសនាហើយ បានថ្វាយកុសលពលី ដែលកើតអំពីព្រហ្មទានទាំងធម្មទានចំពោះព្រះមហាក្សត្រទាំងពីរព្រះអង្គ និងសម្ដេចព្រះឧបយុវរាជ

សូមព្រះអង្គប្រកបដោយសិរីសួស្តីជ័យមង្គលគ្រប់ចំពូក ព្រមទាំងពពួកពុទ្ធបរិស័ទជាម្ចាស់ព្រហ្មទាន ។

ថ្ងៃអាទិត្យទី ១៧ ឧសភា ១៩៥៩ ពេលម៉ោង ៣ រសៀល សម្តេចព្រះពុទ្ធជិន្ទស្តេចសោភ័ណ ស្តេចយាងមកជាព្រះអធិបតីនៃពិធីបុណ្យនេះៗ ទាំងបព្វជិត មានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក គណៈធម្មយុត្ត ព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា ព្រះពុទ្ធាគណៈបានានុក្រម និងសមណនិស្សិតទាំង ៤០ រូប ។ ខាងគ្រហស្ថ មានសហជីវិនឌុប-ហែល ប្រធានរដ្ឋសភា សហជីវិនទឹម ឌុង រដ្ឋលេខាធិការក្រសួងឃោសនាការនិងទេសចរណ៍ សហជីវិន អ៊ុច-វ៉ែន អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក អៀង-គុណសាគី អគ្គលេខាធិការពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត លោក ពៃ-ល្អក់ ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ លោក ពៃ-ប៊ុកប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យនិងឥស្សរជនឯទៀតជាច្រើនៗ

ម៉ោង ៤ លោក ពៃ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ បានថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមក្រាបបង្គំទូលសម្តេចព្រះពុទ្ធជិន្ទស្តេចសោភ័ណ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

សូមនមស្ការ ចំពោះសម្តេចព្រះសង្ឃនាយក ព្រះថេរានុត្ថេរៈទាំងឡាយ សូមថ្វាយទ្រង់ សូមជំរាបឯកឧត្តម លោកអ្នកទាំងឡាយ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ តាងនាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះសម្តេចដែលទ្រង់ស្តេចយាងមកជាព្រះអធិបតី ក្នុងឱកាសបុណ្យព្រហ្មទាននេះ ទុកជាព្រះរាជកិត្តិយសដ៏ប្រសើរចំពោះសមាគមមិត្តពុទ្ធិកវិទ្យាល័យ ។

សូមថ្លែងនូវអំណរដ៏ក្រៃលែង ចំពោះសម្តេចព្រះសង្ឃនាយក ទាំងពីរគណៈ ព្រះថេរានុត្ថេរៈ ទ្រង់ ឯកឧត្តម លោកអ្នកទាំងឡាយ ដែលបានឆ្លៀតពេលឱកាសដ៏ប្រសើរ និមន្ត ស្តេចយាង អញ្ជើញមកកាន់ពិធីបុណ្យនេះ ដើម្បីលើកទឹកព្រះទ័យនៃសមណនិស្សិត ៤៥ រូប ដែលបានចូលទៅបន្តវិជ្ជាជាន់ខ្ពស់ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ តាំងពីថ្ងៃទី ៨ ឧសភា មក ។

ពិធីបុណ្យនេះ ជាភ័ស្តុតាងនៃការអបអរសាទរ ចំពោះសមណ-និស្សិតទាំងឡាយ ដែលបានសិក្សានូវពុទ្ធិកបឋមសិក្សាអស់រយៈវេលា ៣ ឆ្នាំ បានព្យាយាមចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បំពេញនូវមធ្យមសិក្សាខាងព្រះពុទ្ធសាសនា អស់រយៈវេលា ៤ ឆ្នាំ, ឥឡូវនេះបាននិមន្តចូលមកសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដើម្បីនឹងបំពេញនូវឧត្តមសិក្សាខាងព្រះពុទ្ធសាសនាតទៅទៀត ។

ព្រោះហេតុដូច្នេះ ព្រហ្មទានដែលស្ថិតនៅចំពោះព្រះភក្ត្រ ព្រះតេជ-ព្រះគុណ ទ្រង់ ឯកឧត្តម លោកអ្នកទាំងឡាយ ទុកជាគ្រឿងជំនួយ

សម្រាប់ជួយញ៉ាំងព្រះវិន័យសមណនិស្សិត ឲ្យមានវីរិយភាព ដ៏មាំមួន នឹងពលភាពខ្លាំងក្លាឡើងតាមលំដាប់ ។

ព្រហ្មទាននេះ ដែលកើតឡើងដោយបសាទសទ្ធានៃពុទ្ធមាមកជនទាំងឡាយ ទាំងប្រុស-ស្រី សម្រាប់យកមកបូជាចំពោះសមណនិស្សិតនេះ ជានិមិត្តរូបដែលគ្មានបំណងអ្វីក្រៅពីអង្វរព្រះវិន័យក្រុមសមណនិស្សិត សូមឲ្យនិមន្តបន្តវិជ្ជាព្រះពុទ្ធសាសនាទៅថ្នាក់ឧត្តមវិជ្ជា ដោយប្រឹងប្រែងតទៅទៀត ព្រោះជាវិជ្ជាព្រះពុទ្ធសាសនាខាងពុទ្ធិកបឋមសិក្សា ពុទ្ធិក-មធ្យមសិក្សា នឹងពុទ្ធិកឧត្តមសិក្សា ជាវិជ្ជាប្រសើរបំផុត សម្រាប់បេ-នាព្រះតេជ-គុណជាសមណនិស្សិតទាំងឡាយឲ្យទៅជាបណ្ឌិត វិញ្ញូ-ជន ដែលជាមេជាងយ៉ាងជំនាញខាងការកសាងព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅអនាគត បើព្រះពុទ្ធសាសនាចម្រើន ប្រទេសជាតិក៏ចម្រើនតាមលំដាប់ឡើងដែរ ។ ព្រោះហេតុដូច្នេះ ពុទ្ធបរិស័ទទាំងឡាយអាចទុកព្រះតេជ-គុណសមណនិស្សិតទាំងឡាយ ជាវេជ្ជនៃព្រះពុទ្ធសាសនាសម្រាប់ញ៉ាំងពុទ្ធចក្រឲ្យវិលទៅកាន់វឌ្ឍនភាពនឹងសន្តិភាព ។ វេជ្ជនៃព្រះពុទ្ធសាសនាជាអ្នកជួយឧបត្ថម្ភខាងពុទ្ធចក្រ ដូចជាវេជ្ជនៃជាតិជាអ្នកជួយជ្រោមជ្រែងខាងអាណាចក្រដែរ ។ ពុទ្ធចក្រនឹងអាណាចក្រត្រូវប្រស្រ័យគ្នាទៅវិញទៅមក ទើបតួនេះគឺប្រទេសកម្ពុជាអាចប្រព្រឹត្តទៅបានស្រួលៗ

សមាគមមិត្តពុទ្ធិកវិទ្យាល័យ មិនមែនទើបតែនឹងធ្វើបុណ្យព្រហ្មទានកឋិនថ្ងៃនេះទេ គឺបានធ្វើមកតាំងពីឆ្នាំ ១៩៥០ រៀងរាបដរាបមក អាក់ខានធ្វើកឋិនឆ្នាំ ១៩៥៧-៥៨ ដោយសមាគមជាប់មានកិច្ចរវល់ផ្សេង ៗ មិនអាចឆ្លៀតឱកាសនឹងធ្វើបាន ។ ថ្ងៃនេះ ជាអភិលក្ខិតសម័យដ៏មានជោគជ័យសិរីមង្គលសួស្តី ព្រោះសមាគមបានបាត់បង់ធ្វើការកុសលគឺ មានចែកប្រគេននូវព្រហ្មទានដល់ព្រះករុណាទាំងឡាយ ជាសមណនិស្សិតទុកជាកល្យាណកិច្ចមួយដ៏វិសេសវិសាល ក្នុងព្រះពុទ្ធសាសនា ។

លំដាប់តពីនេះទៅ ទូលព្រះបង្គំជាខ្ញុំ - ខ្ញុំព្រះករុណា - ខ្ញុំបាទ សូមទានព្រះបរមឱកាសប្រស្រ័យរំលឹក ចំពោះព្រះសង្ឃជាសមណនិស្សិតដូចតទៅនេះ :

ព្រះតេជ-គុណជាសមណនិស្សិតទាំងឡាយ សូមព្រះអង្គជ្រាបថា : ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា និងពុទ្ធិកឧត្តមសិក្សាជាទ្រឹស្តីនៃពុទ្ធសាសនា ត្រូវយកទ្រឹស្តីនេះទៅអនុវត្តន៍ថែមទៀត ។ ព្រោះការចេះដឹងជាការប្រសើរមែនពិតហើយ ប៉ុន្តែបើមិនប្រតិបត្តិតាមការចេះដឹង ក៏មិនបានផលល្អដែរ ដូចពុទ្ធភាសិត ១ អទ្ទើក្នុងធម្មបទខុទ្ទកនិកាយពោលថា:

ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ ជាដើម ប្រែថា : ទុកជាចេះដឹងច្រើនយ៉ាងណា តែមិនប្រតិបត្តិ

ឲ្យបានល្មមតាមចំណេះ ជាការមិនមានផលប្រយោជន៍ប្រសើរប៉ុន្មានដែរ។

ម្យ៉ាងទៀត ក្នុងពេលនេះ ប្រទេសយើងបានឯករាជ្យពេញលក្ខណៈ បើមានវរសមណ ចំនួនជាច្រើនអង្គ ដើម្បីប្រស្រ័យទាក់ទងនឹងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាជាការប្រសើរបំផុត ។ សមាគមមានសេចក្តីសង្ឃឹមទុកចិត្ត លើព្រះតេជព្រះគុណសមណនិស្សិតពុទ្ធិក-មហាវិទ្យាល័យនេះថា ៈ នឹងបានជាបណ្ឌិតសម្រាប់ជួយដោះស្រាយនូវបញ្ហាដ៏ស្មុគ្រស្មាញក្នុងព្រះពុទ្ធសាសនា ។

ក្នុងឱកាសនេះ សមាគម សូមប្រមូលកល្យាណកុសលដែលកើតមកពីបុណ្យព្រហ្មទាននេះថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតនឹងសម្តេចព្រះមហាក្សត្រិយានី សូមអភិបាលរក្សាព្រះចក្រីទាំងពីរព្រះអង្គ ទ្រង់គង់ជាសុខក្នុងសិរីរាជសម្បត្តិ អស់កាលមួយរយព្រះវស្សា ប្រាសចាកព្រះរោគាពាធគ្រប់ប្រការ ប្រកបដោយនូវជោគជ័យសិរីសួស្តីគ្រប់ទិវារាត្រី ព្រមទាំងព្រះរាជវង្សានុវង្សកុំបីឃ្លាត សូមថ្វាយសម្តេចព្រះឧបយុវរាជជាព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គជាសះស្បើយព្រះរោគាពាធឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមថ្វាយសម្តេចព្រះរាជកនិដ្ឋាស្នេហ៍សោភ័ណ សូមឲ្យទ្រង់ប្រកបដោយសុខមាលភាព នឹងព្រះមង្គលគ្រប់ប្រការ សូមប្រគេនជូន ចំពោះព្រះថេរានុត្ថេរៈទាំងឡាយ ព្រមទាំងឥស្សរជននឹងពុទ្ធមាមកជនជាម្ចាស់ព្រហ្មទានឲ្យបានប្រកបដោយអាយុ វណ្ណ សុខ ពល បដិភាណ

សមគួរតាមសេចក្តីប្រាថ្នា ។ សូមឲ្យប្រទេសកម្ពុជា ប្រាសចាក អសន្តិសុខគ្រប់ប្រការ សូមឲ្យបានប្រកបនូវវឌ្ឍនភាព សម្បូណ៌ភាព សន្តិភាព តាំងពីសម័យបច្ចុប្បន្នរហូតដល់អនាគត ជាភិយ្យោភាពតទៅ ៗ

លំដាប់តមក ព្រះពោធិវង្ស អគ្គាធិការ នៃពុទ្ធិកសិក្សា បានថ្លែងនូវសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយក ព្រះថេរានុត្ថេរៈទាំងឡាយ

សូមថ្វាយព្រះពរសម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណ

សូមចំរើនពរ ឯកឧត្តម ទាំងអស់លោក

ខ្ញុំព្រះករុណា អាត្មាភាព មានបីតិសោមនស្សជាក្រៃលែង ចំពោះសម្តេច ទ្រង់ ឯកឧត្តម ទាំងអស់លោកទាំងឡាយ ដែលបានស្តេចមក និមន្តមក អញ្ជើញមក ជាព្រះអធិបតីភាព ទីជាកិត្តិយស ក្នុងឱកាសពិធីប្រគេនព្រហ្មទានដល់សមណនិស្សិតទាំងឡាយក្នុងវេលានេះ ។

អម្បាញ់មិញនេះ លោកប្រធាននៃសមាគម បានថ្លែងសេចក្តីរៀបរាប់អំពីការផ្តើមធ្វើព្រហ្មទាន ថ្វាយប្រគេនជូនសព្វគ្រប់ហើយ ។ អាត្មាភាព អ្នកកាន់កាប់ផ្ទាល់ក្នុងពុទ្ធិកសិក្សានេះ មានអំណរណាស់ ចំពោះកល្យាណកម្ម ដែលសមាគមមិត្តពុទ្ធិកវិទ្យាល័យបានផ្តើមធ្វើ ព្រោះអំពើនេះនឹងអាចប្រព្រឹត្តទៅ :

១ – ដើម្បីជាកិត្តិយស ចំពោះពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ដោយមហាវិទ្យាល័យនេះ បានបង្កើតឡើង ៤ ឆ្នាំហើយ ពុំបានបើកទ្វារបញ្ចូលនិស្សិតឲ្យសិក្សានៅឡើយ ទើបតែនឹងបើកទ្វារ ឲ្យមានការសិក្សាពីថ្ងៃទី ៨ ឧសភា ១៩៥៩ នេះ គិតទៅទើបនឹងបានត្រឹម ៨ ថ្ងៃប៉ុណ្ណោះ ៗ ការសិក្សាក្នុងពេលដ៏ខ្លីត្រឹម ៨ ថ្ងៃប៉ុណ្ណោះ បាននាំឲ្យសមាគមនឹកលើកឃើញ ហើយបានចាត់ការបំពេញកល្យាណកម្ម គឺព្រហ្មទានប្រគេនដល់សមណនិស្សិតភ្លាម ៗ អាត្មាមានអំណរដោយមានសង្ឃឹមថា ប្រសិនបើការសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនេះ ប្រព្រឹត្តទៅដោយសុខស្រួលវែងទៅក្នុងអនាគត ប្រាកដជានឹងមានសមាគមឯទៀតក្រៅពីសមាគមមិត្តពុទ្ធិកវិទ្យាល័យ ឬនឹងមានក្រុមពុទ្ធមាមកជនឯទៀត មានចិត្តជ្រះថ្លាជួយផ្តល់ ឬជួយបំពេញកិច្ចការទាំងឡាយ ដើម្បីឲ្យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានដំណើរជឿនលឿនទៅមុខ ទៅជួបនឹងវឌ្ឍនភាពយ៉ាងទូលំទូលាយ សមតាមគោលបំណងរបស់មហាវិទ្យាល័យពុំខាន ៗ

២ - ដើម្បីនឹងបានញុំាងសមណនិស្សិត ឲ្យមានកំឡាំងព្យាយាមខំសិក្សាទៅក្នុងអនាគត ដោយហេតុថា សមណនិស្សិតទាំងឡាយគង់មានសេចក្តីគិតឃើញចំពោះទឹកចិត្តជ្រះថ្លា ការឧបអរសាទរ នៃពុទ្ធមាមកជនទាំងឡាយ ៗ

រីឯព្រហ្មទានមួយៗ មិនមែនជាវត្ថុគាបញ្ចាំងជីវភាពនៃសមណនិស្សិត ១ រូប ៗ ឲ្យសម្រេចដល់អវសានបានក៏ពិតមែន ប៉ុន្តែសមណនិស្សិតគប្បី

តែដឹងដល់ទឹកចិត្តជ្រះថ្លានៃពុទ្ធមាមកជន ដែលខំបាត់បែងធ្វើឲ្យកើតជាព្រហ្មពានឡើង ៗ ទឹកចិត្តជ្រះថ្លានេះជាសមុដ្ឋាន នាំឲ្យផុះផុលកុសលធម៌ឯទៀតៗ ចំពោះព្រះពុទ្ធសាសនា ៗ សមណនិស្សិតទាំងឡាយដែលសម្បូណ៌ដោយការសិក្សា នឹងអាចដឹកលំទុកនូវសេចក្ដីជ្រះថ្លារបស់ពុទ្ធមា-មកជនក្នុងគ្រាត្ត៍ៗ ឲ្យឋិតនៅដល់កល្បាវសាន ៗ

លំដាប់តពីនេះ អាត្មាភាព សូមព្រះពរពានឱកាសបន្តិច ដើម្បីប្រ-ស្រ័យចំពោះសមណនិស្សិតទាំងឡាយ ដែលនៅក្នុងទីចំពោះមុខនេះ ៗ

អស់លោកទាំងឡាយ !

ការសិក្សាថ្នាក់ពុទ្ធិកមហាវិទ្យាល័យ ដែលលោកទាំងឡាយទើបនឹងបានចាប់ផ្ដើមឡើងពីថ្ងៃទី៨ ខែសីហានោះ ឥឡូវនេះបាន ៨ ថ្ងៃហើយ សូមលោកទាំងឡាយ ខំប្រឹងបំពេញកិច្ចសិក្សាក្នុងពុទ្ធិក បក្សានេះ ឲ្យដល់ទីបំផុត ៗ ឯកិច្ចសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនោះមានបីផ្នែក: ផ្នែកទី១ ហៅថាវរសិក្សាត្រូវសិក្សាកំណត់ ៣ ឆ្នាំ ត្រូវប្រឡងចេញម្ដង លោកអង្គណាមានវិជ្ជានឹងសមត្ថភាពគ្រប់គ្រាន់នឹងអាចទទួលសញ្ញាបត្រវរសិក្សាបាន ៗ ផ្នែកទី ២ ហៅថា ឧត្ដមសិក្សាជាន់ដំបូង សមណនិស្សិតដែលបានទទួលសញ្ញាបត្រវរសិក្សារួចហើយ ត្រូវបន្តការសិក្សាទៅទៀតកំណត់កាលសិក្សា ៤ ឆ្នាំ ត្រូវប្រឡងចេញម្ដងទៀត លោកណាមានវិជ្ជានឹងសមត្ថភាពគ្រប់គ្រាន់ នឹងអាចទទួលសញ្ញាបត្រជាន់ដំបូងបាន ហៅ

ជាពុទ្ធិកបរិញ្ញា ត្រូវនឹងភាសាបារាំងថា (Licence Bouddhique) ផ្នែកទី៣ ហៅថា ឧត្តមសិក្សាជាន់បំផុត សមណនិស្សិតក្រោយដែលបានទទួលសញ្ញាបត្រឧត្តមសិក្សាជាន់ដំបូងហើយ បើនៅមានព្យាយាម ទំនងអាចបំពេញកិច្ចសិក្សា ៣ ឆ្នាំតទៅទៀតបាន ក្រោយការសិក្សា ៣ ឆ្នាំ ទំនងត្រូវប្រឡងម្ដងទៀត ដោយពិធីតែងអត្ថបទធ្វើជាសៀវភៅវែង ៗ ។ បើលោកណាមានសមត្ថភាពគ្រប់គ្រាន់ ទំនងអាចទទួលសញ្ញាបត្រឧត្តមសិក្សាជាន់បំផុត ។ សញ្ញាបត្រនេះ ទំនងអាចប្រសិទ្ធឲ្យសមណនិស្សិតដែលបានទទួលនោះមាននាទីជាមហាបណ្ឌិត ត្រូវនឹងភាសាបារាំងថា (Doctorat Bouddhique) ។ កាលវេលាដែលត្រូវសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនេះរួមទាំងអស់កំណត់ ១០ ឆ្នាំ បើគិតរួមពេលវេលាដែលសិក្សាក្នុងពុទ្ធិកបឋមសិក្សា ៣ ឆ្នាំ ក្នុងពុទ្ធិកមធ្យមសិក្សា ៤ ឆ្នាំផងត្រូវជា ១៧ឆ្នាំគត់ ។ អស់លោកទាំងឡាយដែលបានសិក្សារួចមក ៧ ឆ្នាំហើយ ត្រូវចូលមកសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យតទៅទៀត បើទោះបីមានឧបសគ្គដោយសេចក្ដីលំបាកយ៉ាងណា ក៏គួរខំប្រឹងឲ្យបានចប់ក្នុងផ្នែកសិក្សានីមួយ ៗ ព្រោះការសិក្សាខាងព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាយើងនេះ តាំងពីបុរាណមក ក៏ពុំមានចារឹកទុកក្នុងប្រវត្តិសាស្ត្រថា មានមហាវិទ្យាល័យដូចជាក្នុងសម័យនេះឡើយ ។ សម័យនេះប្រទេសកម្ពុជាបានឋិតនៅក្នុងឋានៈជាប្រទេសឯករាជ្យ ព្រះករុណាជាអម្ចាស់ជីវិត ក៏ទ្រង់ជាអគ្គពុទ្ធសា-

សន្ទុបត្ថម្ភ អាស្រ័យគុណសម្បត្តិនេះ ទើបព្រះពុទ្ធសាសនាបានឡើងឋានៈទៅជាសាសនារបស់រដ្ឋ ។ តាំងពេលវេលាដ៏ប្រសើរដូច្នេះ គួរអស់លោកតាំងចិត្តប្រកបដោយសេចក្ដីព្យាយាមក្លាហាន កុំរួញរាឡើយ ត្រូវខំសិក្សារៀនសូត្រឲ្យពេញសមត្ថភាពគ្រប់គ្នា ។ ក្នុងពេលកំពុងសិក្សា សូមអស់លោកកុំបណ្ដោយចិត្តឲ្យជិតដាប់នឹងអារម្មណ៍ទាំងឡាយ ដែលនាំឲ្យការសិក្សាថយក្រោយ ត្រូវបណ្ដុះចិត្តឲ្យស្រឡាញ់ការសិក្សាតែម្យ៉ាង ការសិក្សាបែបនេះ នឹងនាំអស់លោកឲ្យបានទទួលជោគជ័យយ៉ាងប្រសើរ ឲ្យបានទទួលនូវលទ្ធផលល្អ គឺការប្រឡងជាប់ពេញលេញ ។ ការប្រឡងជាប់ពេញលេញនោះ នឹងអាចនាំយកនូវសុភមង្គលមកប្រគេនលោក ក្នុងអនាគតសមតាមប្រាថ្នាបាន ។

ម្យ៉ាងទៀត ក្នុងសកលលោកសព្វថ្ងៃនេះ ប្រទេសទាំងឡាយដែលមានព្រះពុទ្ធសាសនាដូចប្រទេសយើងដែរ គេកំពុងតែមានការខ្វល់ខ្វាយបណ្ដុះបណ្ដាលព្រះសង្ឃ អប់រំព្រះសង្ឃ ឲ្យមានការប្រឡងជាប់ច្រើនឡើង ទាំងផ្នែកសាសនា ទាំងផ្នែកលោក ដើម្បីឲ្យព្រះសង្ឃទាំងឡាយមានសមត្ថភាពបរិបូណ៌ អាចបំពេញករណីយកិច្ចជាមុខនាទីរបស់ខ្លួន គួរដល់ការគោរពបូជានៃពុទ្ធសាសនិកជនទូទៅផង អាចជួយផ្សាយពង្រីកព្រះពុទ្ធសាសនាឲ្យទូលំទូលាយទៅក្នុងលោកផង ។

ឯប្រទេសកម្ពុជាយើង ក៏ដូចគ្នានឹងប្រទេសឯទៀតដែរ ពុទ្ធសាស-

និកជនទាំងឡាយ ដែលយកចិត្តទុកដាក់គោរពព្រះពុទ្ធសាសនាតែងមាន សង្ឃឹមលើអស់លោកជានិស្សិតថ្មីនៃពុទ្ធិកមហាវិទ្យាល័យ ជាទីដ៏មានការក្ដីស្វាងច្រើន ដោយមានការចេះដឹងច្រើន ហើយនឹងអាចគ្រោងអនាគតនៃព្រះពុទ្ធសាសនាឲ្យបានឲ្យបានគង់វង់ ព្រមទាំងអាចជួយផ្សាយពង្រីកព្រះពុទ្ធសាសនា ឲ្យរីកទូលាយឡើងពុំខាន ។

ទីបំផុតនេះ អាត្មាភាព សូមរំលឹកគុណព្រះរតនត្រ័យ សូមសំបូងសម្រួងអស់ពួកទេវតា ដែលស្រឡាញ់ព្រះពុទ្ធសាសនា សូមឲ្យជួយអភិបាលរក្សាព្រះមហាក្សត្រ សម្ដេចព្រះឧបយុវរាជ ជាប្រមុខរដ្ឋាភិបាល ព្រះរាជវង្សានុវង្ស រដ្ឋាភិបាល នាម៉ឺនបព្វមុខមន្ត្រីគ្រប់ឋានៈ និងប្រជាពលរដ្ឋ ព្រមទាំងពុទ្ធសាសនិកជនទាំងឡាយ ឲ្យបានជួបប្រទះតែនឹងសេចក្ដីសុខក្សេមក្សាន្តទីដ៏សុភមង្គលគ្រប់យ៉ាង ជានិច្ចនិរន្តរ៍ កុំបីឃ្លាត ។

ម៉ោង ៤.៣០ នាទី លោកជា-ទន់ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បានសូត្រព្រហ្មទេយ្យតាមលំដាប់ព្រហ្មទាន ទាំងពីលេខ១ រហូតដល់លេខ ៤៥ ។ សម្ដេចព្រះរាជកនិដ្ឋាស្នេហ៍ សោភ័ណ ទ្រង់បានថ្វាយព្រះព្រហ្មទានទី ១ របស់ព្រះអង្គ ចំពោះសមណនិស្សិតព្រះនាម ហ៊ុន-ម៉ន វត្តសារាវ៉ន ដែលបានប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សា ជាប់លេខ ១ ។

លំដាប់តមក លោកជួប-ហៃល ប្រធានរដ្ឋសភា ក៏បានប្រគេនព្រហ្មទានលេខ២ រូប លោកទឹម-ដុន រដ្ឋលេខាធិការក្រសួងឃោសនាការ លោកអ៊ុប-វ៉ែន អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងឥស្សរជន ក៏បានប្រគេនព្រហ្មទានទី ៣ ៤ តាមលំដាប់ហូរហែ រហូតដល់ព្រហ្មទានទី ៤០ ៗ រូបហើយ សមណនិស្សិតទាំង ៤០ រូបក៏បានសូត្រជយន្តោ ៗ

ពិធីធ្វើព្រហ្មទាននេះ បានបញ្ចប់នៅម៉ោង ៦ ល្ងាច ក្រោយដែលសម្តេចព្រះរាជកនិដ្ឋាស្នេហ៍សោភ័ណ ទ្រង់ស្តេចយាងវិលត្រឡប់ទៅកាន់ព្រះដំណាក់វិញ ៗ

ព្រហ្មទានសំរាប់លើកទឹកចិត្ត សមណនិស្សិតគ្រប់រូប
ឱ្យខំបន្តការសិក្សា នៅក្នុងមហាវិទ្យាល័យ ៗ
ព្រះសីហនុរាជឧត្តម ដែលបានរៀបចំតាមសម័យ
ផ្លូវលោកផ្លូវធម៌ប្រសើរថ្លៃ អប់រំនិស្ស័យជាបណ្ឌិត ៗ

–បិង-វិង–

# បុណ្យនមស្ការព្រះសក្យមុនីចេតិយ

តាប - ពិន រៀបរៀង

ថ្ងៃពេញបូណ៌មី ខែពិសាខ ជាថ្ងៃដែលព្រះចន្ទពេញវង់ ផ្កាយរស្មីភ្លឺត្រចះ មេឃខៀវស្រឡះ ដេរដាសដោយតារាករ ជាបរិវារ គួរឲ្យកើតសោមនស្សរីករាយជ្រះថ្លាជាអនេក ៗ ថ្ងៃនេះ ជាមហាកិលក្ខិតកាល ដែលពុទ្ធបរិស័ទនៅទ្វីបអាស៊ីអាគ្នេយ៍ ស្ទើរតែទាំងអស់ ទីដ៏នៅតំបន់ខ្លះៗ នៃទ្វីបអឺរ៉ុប ទ្វីបអាមេរិក មានសេចក្ដីជ្រះថ្លានាំគ្នាកាន់គ្រឿងសក្ការបូជា មានទៀនធូបទឹកផ្កាឈើជាដើម ដើរត្រសង់ទៅកាន់វត្តអារាមឬព្រះស្តូប ព្រះចេតិយ ឬគ្រឹះស្ថានពុទ្ធិកសមាគម ដែលមានដំកល់ព្រះពុទ្ធរូប ដើម្បីធ្វើពិសាខបូជា រំលឹកដល់ថ្ងៃដែលព្រះសក្យមុនីគោតមបរមសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ប្រសូត ទ្រង់បានត្រាស់ដឹង និងទ្រង់រំលត់ខន្ធចូលកាន់ព្រះនិព្វាន ។

គ្រប់តែវត្តអារាម នៅប្រទេសកម្ពុជា ពុទ្ធបរិស័ទបានរៀបគ្រឿងសក្ការៈធ្វើវិសាខបូជា នាថ្ងៃពេញបូណ៌មីខែពិសាខ ជាមហាឱឡារិកអធិកអធ័មរៀងរាល់ឆ្នាំ ។

ក្នុង ព.ស. ២៤៩៩ គ.ស.១៩៥៦ ប្រទេសកម្ពុជាបានសាងព្រះចេតិយ ១ នៅមុខស្ថានីយរថយន្តស្វ័យយាន ក្រុងភ្នំពេញ ជាទីប្រតិស្ឋានព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្ពុទ្ធ ដែលសម្ដេចព្រះនរោត្តម

សីហនុ ទ្រង់បានមកពីប្រទេសសិរីលង្កា រាជការបានធ្វើបុណ្យឆ្លងព្រះ
ចេតិយនោះ ជាមហោឡារិកហៅថា "បុណ្យព.ស.២៥០០" រួចហើយ ។

ក្រោយពីបុណ្យ ព.ស. ២៥០០ មក មានព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤-១-៥៨ ទ្រង់ព្រះរាជកំណត់ទុកបុណ្យនមស្ការព្រះសក្យមុនីចេតិយនោះ ជាបុណ្យផ្លូវការ បុណ្យជាតិ ត្រូវធ្វើនៅថ្ងៃ ១៥ កើត និងថ្ងៃ ១ រោច ខែពិសាខ រៀងរាល់ឆ្នាំតទៅ ។

ចំពោះបុណ្យនមស្ការព្រះសក្យមុនីចេតិយ នៅ ព.ស. ២៥០២ គ.ស. ១៩៥៩ នេះ មានកម្មវិធីដូចតទៅ ៖

## ថ្ងៃទី ១

ថ្ងៃ១៥កើត ខែពិសាខ ព.ស.២៥០២ (២២-៥-៥៩)

ពេលរសៀលម៉ោង ១៧ ៣០ ជួបជុំព្រះសង្ឃ ព្រះរាជវង្សានុវង្ស ប្រធានសភាទាំង២ នាយករដ្ឋមន្ត្រី សមាជិករាជរដ្ឋាភិបាល សមាជិកសភាទាំង២ មន្ត្រីគ្រប់តំណែង ទាំងទាហាន ទាំងស៊ីវិល ព្រមទាំងឧបាសក ឧបាសិកា និមន្ត ស្តេចយាង អញ្ជើញដល់ រង់ចាំគោរពព្រះ-រាជតំណាងស្តេចយាងដល់ ដោយមានក្រុមឧត្តមប្រឹក្សានៃព្រះរាជា និងព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែ ។

ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមភ្លេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ធ្វើគារវកិច្ចតាមទម្លាប់ ។

សម្តេចក្រុមព្រះ ព្រះរាជតំណាង ស្តេចឡើងគង់លើព្រះពន្លា ។

- ពិធីបង្ហូតទង់ជាតិ ទង់សាសនា ដោយសិស្សប្រុសម្នាក់ស្រីម្នាក់ ។
- ចម្រៀងបទនគររាជ ដោយសិស្សប្រុសស្រីច្រើននាក់ ដូចតទៅនេះ

ចម្រៀងបទនគររាជ

សូមពួកទេពតារក្សាមហាក្សត្រយើង
ឲ្យបានរុងរឿងដោយជ័យមង្គលសិរីសួស្តី
យើងខ្ញុំព្រះអង្គសូមជ្រក ក្រោមម្លប់ព្រះបារមី
នៃព្រះនរបតីវង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរបុរាណថ្កើងថ្កាន ។

ប្រាសាទសិលា តាំងនៅកណ្ដាលព្រៃ
គួរឲ្យស្រមៃនឹកដល់យសស័ក្ដិមហានគរ
ជាតិខ្មែរដូចថ្មគង់វង់នៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមានយូរអង្វែងហើយ ។

គ្រប់វត្តអារាមឮតែសូរស័ព្ទធម៌
សូត្រដោយអំណរនឹកដល់គុណពុទ្ធសាសនា
ចូរយើងជាអ្នកជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេព្ដាផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរជាមហានគរ ។

បន្ទាប់ពីនោះ ថ្វាយបទសរភញ្ញ ដោយសិស្សប្រុសស្រីច្រើននាក់ :

## ទំនុកសរភញ្ញ

នមស្ការព្រះពុទ្ធគុណ

សូមថ្វាយបង្គំ ទសករប្រណម្យ
ចំពោះត្រង់ ព្រះពុទ្ធជាម្ចាស់
គឺព្រះមានជោគ លោកទ្រង់ត្រាស់
ដឹងច្បាស់នូវ ធម៌ទាំងឡាយ
ឥតមានសេសសល់ សោះឡើយ ។
យើងខ្ញុំវន្ទា ដល់ព្រះសម្មា-
ដែលទ្រង់ចូល និព្វានទៅហើយ
ទុកសាសនាឲ្យ សត្វបានស្បើយ
ចូនត្រើយត្រាណ គ្រាន់ផុតពីទុក្ខា
ដោយសារសាសនាព្រះអង្គ ។
យើងខ្ញុំព្រះករុណា ទាំងអស់ពល់គ្នា
សូមលើកហត្ថបង្គំ ឆ្ពោះត្រង់
ដល់គុណខ្ពង់ខ្ពស់នៃព្រះអង្គ ដែលទ្រង់ព្រះបរិព្វានទៅ
ទុកសាសនានូវជាកេរ្តិ៍ ។

-ព្រះសង្ឃ គ្រហស្ថ ក្រោកឈរបែរព្រះភក្ត្រ-មុខ គោរពព្រះ

សក្យមុនីចេតិយ ទៅពេលដែលថ្វាយបង្គំសរភញ្ញ ។

- សុន្ទរកថាសំដែងសេចក្ដីគោរពចំពោះព្រះសក្យមុនីចេតិយ ដោយលោកអ្នកឧកញ៉ាពិតក្កិសាសនៈ រដ្ឋលេខាធិការក្រសួងធម្មការ (អ៊ីង-ហុនសាធ) ថ្លែងក្នុងនាមនៃព្រះរាជរដ្ឋាភិបាល ។

សុន្ទរកថា

សូមទ្រង់ព្រះមេត្តាប្រោស,

សូមក្រាបបង្គំទូលសម្ដេចក្រុមព្រះជាព្រះរាជតំណាង នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះមហាក្សត្រិយានី

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល ទូលបង្គំជាខ្ញុំ សូមព្រះរាជទានទទួលនូវអំណរយ៉ាងជ្រាលជ្រៅ ចំពោះព្រះករុណាថ្លៃវិសេស ដែលទ្រង់សព្វព្រះហឫទ័យ ស្ដេចយាងមកជាព្រះរាជាធិបតីក្នុងពិធីបុណ្យឧទ្ទិសព្រះបរមសារីរិកធាតុ ដែលប្រតិស្ឋានក្នុងព្រះសក្យមុនីចេតិយ នាថ្ងៃនេះ ក្នុងព្រះឋានៈជាព្រះរាជតំណាង នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងតាំងពីព្រះអង្គ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ព្រះបរមសារីរិកធាតុ ដែលដំកល់ក្នុងព្រះសក្យមុនីចេតិយនេះ គឺជាព្រះបរមអដ្ឋិធាតុនៃព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ដែលសម្ដេចព្រះឧបយុវរាជទ្រង់បានទទួលផ្ទាល់ព្រះអង្គនៅប្រទេសសិរីលង្កា ហើយទ្រង់បានដង្ហែចូលមកប្រទេសកម្ពុជា មុនដំបូងដំកល់ទុកក្នុងព្រះបរមរាជវាំង ។

លុះដល់ក្នុងឱកាសបុណ្យពុទ្ធសករាជ ២៥០០ សម្ដេចទ្រង់ព្រះមេត្តាប្រោសឲ្យមានពិធីដង្ហែព្រះបរមសារីរិកធាតុ មកប្រតិស្ឋានដំកល់ទុកក្នុងព្រះសក្យមុនីចេតិយនេះ នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៩៥៧ ដើម្បីជាទីគោរពនមស្ការបូជា នៃពុទ្ធសាសនិកជនទូទៅ ។ លំដាប់តមកព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យលេខ ៧៣-ន.ស ចុះថ្ងៃទី ២៤ មករា ១៩៥៨ កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើត និងថ្ងៃ ១ រោច ខែពិសាខរៀងរាល់ឆ្នាំតទៅ ហើយត្រូវទុកពិធីបុណ្យនេះជាពិធីបុណ្យជាតិ ដោយការចាត់ចែងរៀបចំក្រោមព្រះរាជាធិបតីភាព នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះមហាក្សត្រិយានី ។

ដោយអាស្រ័យការអនុវត្តន៍ ប្រកបដោយសេចក្ដីគោរពតាមព្រះរាជក្រឹត្យខាងលើនេះ ក្រសួងធម្មការបានរួបរួមជាមួយក្រសួងរដ្ឋមន្ត្រីនានា និងរាជការក្រុង ព្រមទាំងសមាគមព្រះពុទ្ធសាសនា ដោយមានការឧបត្ថម្ភពីព្រះបរមរាជវាំងផង បានចាត់ចែងធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនី

ចេតិយ កាលពីក្នុងឆ្នាំ ១៩៥៨ មុនហើយជាលើកដំបូង ។ ឥឡូវក្នុងថ្ងៃនេះ ជាលើកទីពីរ ។

សូមទ្រង់ព្រះមេត្តាប្រោស ,

ទូលបង្គំជាខ្ញុំ សូមព្រះរាជវរោកាស ថ្វាយនូវគារវភាពចំពោះព្រះបរមសារីរិកធាតុនៃព្រះអរហំ.សម្មាសម្ពុទ្ធ និងព្រះគុណដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ មានសេចក្តីដូចតទៅនេះ ៖

បពិត្រព្រះសក្យមុនីសម្ពុទ្ធបរមគ្រូ,

ថ្ងៃនេះ ជាថ្ងៃ ១៥ កើតខែពិសាខ ជាថ្ងៃដែលពុទ្ធបរិស័ទទាំងឡាយតែងរឭកឃើញដល់ព្រឹត្តិការណ៍ជាអស្ចារ្យ របស់ព្រះអង្គឥតដែលភ្លេចសោះឡើយ ។ ថ្ងៃនេះ, ពួកពុទ្ធបរិស័ទបានកំណត់ទុកថាជាថ្ងៃសុភមង្គលដ៏ប្រសើរ ។

បពិត្រព្រះភគវន្តមុនី ,

ព្រះអង្គទ្រង់បរិនិព្វានទៅ ២៥០២ ឆ្នាំហើយ ប៉ុន្តែព្រះពុទ្ធសាសនាជាទ្រព្យរបស់ព្រះអង្គ ដែលព្រះសង្គីតិកាចារ្យបានរួបរួមចារឹកទុកមក បានឋិតនៅដោយពេញលេញ ឥតវិនាសបាត់បង់ សូម្បីតែបន្តិចបន្តួចឡើយ. ទាំងព្រះគុណរបស់ព្រះអង្គ ដែលមានច្រើនជាអនេកអនន្តនោះ ក៏ដិតជាប់នៅជានិច្ចក្នុងសន្តានចិត្តនៃពុទ្ធបរិស័ទទូទៅ ។

សាសនធម៌របស់ព្រះអង្គ, កាលក្រោយដែលព្រះអង្គបរិនិព្វានទៅ,

បានមកប្រតិស្ឋានទៅប្រទេសកម្ពុជា  អស់រយកាលជាង ២០០០ ឆ្នាំ ហើយ ៗ ដោយអាស្រ័យសទ្ធាជ្រះថ្លា នឹងការគោរពប់អាននៃព្រះមហាក្សត្រខ្មែរទាំងឡាយ តាំងពីបុរាណកាលរហូតដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ព្រមទាំងប្រជាជាតិខ្មែរទាំងឡាយ, ទើបពុទ្ធសាសនារបស់ព្រះអង្គ អាចមានថេរភាព នឹងវឌ្ឍនភាពរុងរឿងជាដរាបរៀងមក ។

បពិត្រព្រះបរមគ្រូ ,

ថ្ងៃនេះ ជាថ្ងៃប្រកបដោយសិរីសួស្តីជ័យមង្គលដ៏ប្រសើរ, ព្រះរាជតំណាងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី ព្រះសង្ឃពុទ្ធសាសនិក ព្រះរាជវង្សានុវង្ស តួមក្រុមប្រឹក្សាព្រះរាជាសភាទាំងពីរ គណៈរដ្ឋមន្ត្រី មន្ត្រីគ្រប់ឋានៈ ទាំងទាហាន-ស៊ីវិល នឹងប្រជារាស្ត្រទាំងឡាយ បានស្តេចមក អញ្ជើញមកជួបជុំគ្នាទីនេះប្រារព្ធធ្វើពិធីនមស្ការបូជាចំពោះព្រះអង្គ ដែលប្រកបដោយព្រះមហាករុណាទិគុណដ៏ទូលំទូលាយ ។

ក្នុងវិសាខនេះ ក្រសួងធម្មការ សូមរំលឹកចំពោះគុណព្រះរតនត្រ័យ គឺ ព្រះគុណរបស់ព្រះអង្គ នឹងព្រះធម៌ព្រមទាំងព្រះសង្ឃ សូមជួយអភិបាលរក្សាព្រះករុណាជាម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ សម្តេចព្រះបិតាឯករាជ្យជាតិ នឹងព្រះរាជវង្សានុវង្ស ព្រមទាំងប្រជាពលរដ្ឋខ្មែរទូទៅ

ឲ្យបានសេចក្ដីសុខប្រកបដោយសេចក្ដីចំរើនរុងរឿងជាកិយោគាពតទៅ ។

សូមព្រះករុណាជាម្ចាស់ជីវិតពាំងពីព្រះអង្គ ទ្រង់មានព្រះជន្មាយុ ជានិរយវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជាពលរដ្ឋទៅ !

សូមសម្ដេចព្រះវរយុវរាជ ទ្រង់បានទទួលព្រះសុខភាពដ៏បរិបូណ៌ ឡើងវិញយ៉ាងឆាប់រហ័ស ដើម្បីទ្រង់បំពេញព្រះពលិកម្មគ្រប់បែបគ្រប់ យ៉ាង ជូនជាតិ-សាសនា - ព្រះមហាក្សត្រិយ៍ !

សូមពិភពលោកទាំងមូល បានប្រកបដោយសន្តិភាព ប្រាសចាក សឹកសង្គ្រាមកុំបីឃើញឃ្លាតឡើយ !

ជយោ ព្រះពុទ្ធសាសនា !

ជយោ កម្ពុជរដ្ឋ !

បន្ទាប់ពីនេះ ពិធីនមស្ការជាតុឡាវិក ដោយលោក ចាប.ពិន នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកនាំដូចតទៅនេះ :

សូមទ្រង់ព្រះមេត្តាប្រោស,

សូមព្រះរាជទានក្រាបបង្គំទូលសម្ដេចក្រុមព្រះ ជាព្រះរាជតំណាងព្រះ ករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្ដេចព្រះមហាក្សត្រិយានី

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

វេលានេះ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកនាំពុទ្ធបរិស័ទនមស្ការព្រះសក្យ មុនីចេតិយ សូមសម្ដេចជាអម្ចាស់ទ្រង់ព្រះមេត្តាប្រោសទទួល ព្រមទាំង

ពុទ្ធបរិស័ទទាំងអស់ទទួលតាមទាំងបាលីទាំងសម្រាយ ១ សង្កាត់ម្តង ៗ ដូចតទៅនេះ ៖

## ពាក្យនមស្ការព្រះបរមសារីរិកធាតុ

មាយវស្សានិ សម្ពុទ្ធោ ភគវា យោ តថាគតោ
សមសីត្យាយុកកាលេ បរិនិព្វាយិ សោ មុនិ
តស្ស សារីរិកា ធាតុ អម្ហាកំ បមុខេ ឋិតា
តថាគតោ ច សោ សត្ថា ធរមានោវ តិដ្ឋតិ
សក្ការេហាភិបូជេម តំ នមស្សាម សាទរំ
សាធុ នោ ភគវា ធាតោ សព្វញ្ញូ សន្តិនាយកោ
ឥមេ ឧលិន្ទសក្ការេ អនុកម្បាយ គណ្ហាតុ
ទីឃរត្តំ ហិតាយេវ សុខាយម្ហាក សព្វទា ។

"ព្រះតថាគត ភគវន្តមុនី អង្គណា ទ្រង់បានត្រាស់ហើយ (ឋិតនៅ) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំគត់ ; (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់គង់ព្រះធរមាននៅឡើយ ស្តេចយាងមកគង់ក្នុងទីនេះ យើងខ្ញុំ, សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយ

គោរព, សូមព្រះគតវន្តមុនី សព្វញ្ញុពុទ្ធ បរមលោកនាថ ដែលតែងតែប្រោសប្រទានសន្តិសុខ ដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយ របស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការៈបូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គឲ្យបានហិតប្រយោជន៍នឹងសេចក្តីសុខ សព្វកាលវេលាយូរអង្វែងរៀងទៅហោង។" ។

បន្ទាប់ពីនេះ ពិធីហែប្រទក្សិណព្រះសក្យមុនីចេតិយ បូជាផ្កាកម្រង ដោយសម្តេចក្រុមព្រះ ជាព្រះរាជតំណាង ព្រមទាំងវរជន ដោយមានលោក តាប-ពិន ជាអាចារ្យនាំព្រះរាជដំណើរ ។

ព្រះសង្ឃ-មន្ត្រី-ពុទ្ធបរិស័ទចេញពីវេទិកាមកឈរគោរពព្រះសក្យមុនីចេតិយ តាមទីកន្លែងដែលគណៈកម្មការរៀបចំ ប្រគេន-ជូនកន្ទេលនោះ ។

-សម្តេចក្រុមព្រះជាព្រះរាជដំណាងស្តេចយាងឡើងកាន់ព្រះពន្លាវិញ ។
-ព្រះសង្ឃត្រឡប់មកគង់លើវេទិកាដែរ ។
-ចំរើនពុទ្ធជ័យមង្គលគាថា ដោយព្រះសង្ឃ ២០០ អង្គ ។
-សម្តេចក្រុមព្រះជាព្រះរាជតំណាងស្តេចយាងត្រឡប់ ។

បន្ទាប់ពីនេះទៅ បើកឱកាសឲ្យពុទ្ធបរិស័ទគ្រប់ប្រទេស ចូលធ្វើសក្ការៈបូជា រហូតដល់ម៉ោង ២០-៣០ ។

ម៉ោង ២១,០០ បិទទ្វារព្រះសក្យមុនីចេតិយ ជាកិច្ចបញ្ចប់បុណ្យថ្ងៃទី ១ ។

ថ្ងៃទី ២

ថ្ងៃ១កើត ខែពិសាខ ព ស ២៥០២ (២៣-៥-៥៨)

ពេលព្រឹកម៉ោង ៨-៣០ ជួបជុំព្រះសង្ឃ ព្រះរាជវង្សានុវង្ស ប្រធានសភាទាំង ២ នាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល សមាជិកសភាទាំង២ មន្ត្រីគ្រប់តំណែង ទាំងទាហាន ទាំងស៊ីវិល ព្រមទាំងឧបាសកឧបាសិកានិមន្ត ស្តេចយាង-អញ្ជើញដល់ រង់ចាំគោរពសម្តេចក្រុមព្រះជាព្រះរាជតំណាង ។

ម៉ោង ៨-៤៥ សម្តេចក្រុមព្រះជាព្រះរាជតំណាងស្តេចយាងដល់ ។

- ឧត្តមក្រុមប្រឹក្សានៃព្រះរាជា និងព្រះរាជបរិពារៈផ្ទាល់ព្រះអង្គតាមហែ ។

- ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមភ្លេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ធ្វើគារវកិច្ចតាមទម្លាប់ ។

- សម្តេចក្រុមព្រះជាព្រះរាជតំណាងស្តេចយាងគង់លើព្រះពន្លា ។

- ពិធីសមាទានសីល ដោយលោក ចាប-ពិន ជាអាចារ្យអារាធនា ។

ម៉ោង ៩-១០ ព្រះរាជពិធីដាក់បាត្រព្រះសង្ឃ ៨០ អង្គ ។

-សម្តេចក្រុមព្រះជាព្រះរាជតំណាង ស្តេចឡើងគង់លើព្រះពន្លា ។

-ព្រះសង្ឃទទួលចង្ហាន់ហើយ និមន្តត្រឡប់មកគង់លើវេទិកាវិញ ។

-ស្វាធ្យាយធម៌ ដោយព្រះសង្ឃ ។

-ពិធីដាក់ទង់ជាតិ ទង់សាសនា ។

-បំរៀងបទនគររាជ
-ថ្វាយបទសរភញ្ញ } ដោយសិស្សប្រុស-ស្រីដូចពីល្ងាចថ្ងៃពេញបូណ៌មី

ព្រះសង្ឃគ្រហស្ថ ក្រោកឈរបែរព្រះភ័ក្ត្រ-មុខគោរពព្រះសក្យមុនីចេតិយ ។

ម៉ោង ១០-០០ សម្តេចក្រុមព្រះជាព្រះរាជតំណាង ទ្រង់ស្តេចយាងត្រឡប់ ។

ចប់ពិធីបុណ្យឆមស្ការព្រះសក្យមុនីចេតិយប៉ុណ្ណេះ ។

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អជីណ៌ នបុំ. ការមិនរលាយអាហារ ។

អជីយិតា ស្រ្តី. ភាវនៃកិរិយាបំផ្លាញមិនបាន, ភាវនៃកិរិយាមិនផិភ ។

អជីវ គុ. ដែលឥតជីវិត ។

អជីវន នបុំ. កិរិយាមិនរស់, សេចក្ដីស្លាប់ ។

អជីវិត នបុំ. កិរិយាមិនមានជីវិត ។

អជុគុប្ស គុ. ដែលមិនស្អប់ខ្ពើម ។ *អជុគុប្សិត* គុ. ដែលមិនគួរស្អប់ខ្ពើម, ដែលឥតគៈទ្ធាះ ។

អជេយ គុ. អជេយ, ដែលមិនគប្បីចាញ់ ។

អជ្ញ គុ. ដែលមិនដឹង (សត្វ, ជាតុផ្សេងៗ): ល្ងង់ខ្លៅ, សំពីក, ភ្លើ ។ — *តា* ស្រ្តី. ភាវនៃកិរិយាមិនដឹង, ភាវនៃបុគ្គលល្ងង់ខ្លៅ ។

អជ្ញាត គុ. ដែលមិនដឹង, ដែលមិនបេះ ។ –*កុត្ត* គុ. ដែលបរិភោគដោយមិនដឹងខ្លួន ឬ ដោយមិនមានសម្បជញ្ញៈ ។ – *លិបរូមិ* ឬ –*លិបរាមិ* ក្រិ. វិ. ដោយកិរិយាចង់បានមិនបញ្ជាក់ ។

អជ្ញាតិ បុំ. ការមិនមែនជាសាច់ញាតិ ។

(នៅមានត)